unesco

ការអប់រំ សម្រាប់ ការអភិវឌ្ឍ ដោយចីរភាព

ផែនទីបង្ហាញផ្លូវ

#ESDសម្រាប់ឆ្នាំ២០៣០

#ESDfor2030

Education 2030

ផ្នែកអប់រំរបស់យូណេស្កូ

ការអប់រំ គឺជាអាទិភាពសំខាន់ជាងគេរបស់យូណេស្កូ ព្រោះថាការអប់រំគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងជាមូលដ្ឋានគ្រឹះសម្រាប់កសាងសន្តិភាព និងជំរុញការអភិវឌ្ឍដោយចីរភាព។ យូណេស្កូគឺជាទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ ដែលផ្តោតលើការងារអប់រំ ហើយផ្នែកអប់រំរបស់យូណេស្កូ គឺជាអង្គភាពដឹកនាំការងារអប់រំនៅកម្រិតសកល និងកម្រិតតំបន់, ពង្រឹងប្រព័ន្ធអប់រំជាតិ និងឆ្លើយតបចំពោះបញ្ហាប្រឈមដែលកំពុងកើតមាននៅក្នុងសកលលោក តាមរយៈការផ្តល់សេវាអប់រំ ដោយផ្តោតជាពិសេសលើសមភាពយេនឌ័រ និងទ្វីបអាហ្វ្រិក។

របៀបវារៈអប់រំជាសកលឆ្នាំ ២០៣០

យូណេស្កូ ក្នុងនាមជាទីភ្នាក់ងារឯកទេស ខាងការអប់រំរបស់អង្គការសហប្រជាជាតិ មានភារកិច្ចដឹកនាំ និងសម្របសម្រួលរបៀបវារៈអប់រំឆ្នាំ ២០៣០ ដែលជាផ្នែកមួយនៃចលនាសកលសំដៅលុបបំបាត់ភាពក្រីក្រ តាមរយៈការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពចំនួន ១៧ ត្រឹមឆ្នាំ ២០៣០។ ការអប់រំដែលសំខាន់ និងចាំបាច់ដើម្បីសម្រេចគោលដៅទាំងនេះត្រូវបានចាត់ទុកថាជាគោលដៅមួយដែរ គឺគោលដៅទី ៤ ដែលមានគោលបំណង *"ធានានូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"*។ ក្របខ័ណ្ឌសកម្មភាពស្តីពីការអប់រំឆ្នាំ ២០៣០ ដាក់ចេញនូវការណែនាំអំពីការអនុវត្តគោលដៅ និងការប្តេជ្ញាចិត្តប្រកបដោយមហិច្ឆតានេះ។

unesco
United Nations
Educational, Scientific
and Cultural Organization

Education 2030

បោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០២២ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ
អាសយដ្ឋាន អគារលេខ ៧, place de Fontenoy, 75352 ទីក្រុងប៉ារីស 07 SP, ប្រទេសបារាំង
រក្សាសិទ្ធិ © UNESCO 2022
ISBN 9 789230 001575

CC BY SA

ឯកសារនេះផ្តល់ជូនក្នុងទម្រង់អាជ្ញាប័ណ្ណ Open Access under the Attribution ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) License (http://creativecommons.org/licenses/by-sa/3.0/igo/)។ តាមរយៈការប្រើប្រាស់ខ្លឹមសារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ អ្នកប្រើប្រាស់ទទួលយកកាតព្វកិច្ច ដែលត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌស្តីពីការប្រើប្រាស់របស់បណ្ណាសារបើកទូលាយរបស់យូណេស្កូ (http://www.unesco.org/open-access/terms-use-ccbysa-en)។

ចំណងជើងដំបូង៖ *Education for Sustainable Development: A Roadmap.* បោះពុម្ពផ្សាយដំបូងនៅក្នុងឆ្នាំ ២០២០ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ (UNESCO) អាសយដ្ឋាន អាគារលេខ ៧, place de Fontenoy, 75352 ទីក្រុងប៉ារីស 07 SP, ប្រទេសបារាំង។

ឈ្មោះដែនដី ឬប្រទេសដែលប្រើប្រាស់នៅក្នុងឯកសារនេះ មិនបង្ហាញពីការយល់ឃើញអ្វីមួយរបស់យូណេស្កូពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេសដែនដី ទីក្រុង ឬតំបន់ណា ឬអាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬតំបន់ណានោះឡើយ គឺពាក់ព័ន្ធនឹងការកំណត់ព្រំដែនរបស់ប្រទេសដែនដី ទីក្រុង ឬតំបន់ណានោះឡើយ។ គំនិតនិងយោបល់ដែលលើកឡើងនៅក្នុងឯកសារនេះ គឺជាគំនិតយោបល់របស់អ្នកនិពន្ធ។

គំនិត និងយោបល់ទាំងនេះ មិនមែនជាគំនិតយោបល់របស់យូណេស្កូ ហើយក៏ពុំចងកាតព្វកិច្ចអ្វីមួយរបស់អង្គការនេះនោះដែរ។

បកប្រែដោយ៖ Big Text International
ចេនាក្រាហ្វិចដោយឈ្មោះ Aurélia Mazoyer និង Olivier Marie
រូបភាពសម្រាប់ទំព័រគំរបមុខដោយ Aurélia Mazoyer និង Olivier Marie
បោះពុម្ពដោយយូណេស្កូ

រូបភាព (ត្រង់ទំព័រ ២២-២៣, ទំព័រ ៥៤)៖ https://thenounproject.com/
រូបភាព Government ដោយ Rflor អាចរកបានក្រោម CC BY
រូបភាព Reading ដោយ Vectors Market នៅក្នុងបណ្តុំរូបភាព Vector Icons អាចរកបានក្រោម CC BY
រូបភាព Teacher ដោយ Gregor Cresnar នៅក្នុងបណ្តុំ Business៖ Solid Vol. 6 អាចរកបានក្រោម CC BY
រូបភាព Successful young man ដោយ Gan Khoon Lay នៅក្នុង Freelancer And Self Employed អាចរកបានក្រោម CC BY
រូបភាព Community ដោយ ProSymbols នៅក្នុងបណ្តុំ People Group And Community Symbols Glyph Icons អាចរកបានក្រោម CC BY
បោះពុម្ពនៅក្នុងប្រទេសបារាំង

CLD 381.20

unesco

ការអប់រំ សម្រាប់ ការអភិវឌ្ឍ ដោយចីរភាព

ផែនទីបង្ហាញផ្លូវ

#ESDសម្រាប់ឆ្នាំ២០៣០

#ESDfor2030



អារម្ភកថា

ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ដែលបានសាយភាយពេញផែនដីក្នុងឆ្នាំ ២០២០ មិនត្រឹមតែជាវិបត្តិសុខភាពសកលប៉ុណ្ណោះទេ វាគឺជាវិបត្តិដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់យើង និងជាវិបត្តិដែលបង្ហាញឱ្យឃើញពីភាពផុយស្រួយនៃការពឹងផ្អែកទៅវិញទៅមករបស់យើងជាមួយនឹងធម្មជាតិ។ យើងបានដឹងថា នៅពេលដែលព្រៃឈើរងការបំផ្លិចបំផ្លាញ មិនត្រឹមតែសត្វព្រៃប៉ុណ្ណោះទេដែលរងគ្រោះថ្នាក់ ប្រព័ន្ធអេកូឡូស៊ីក៏ត្រូវចុះខ្សោយ ហើយមនុស្សកាន់តែប្រឈមនឹងជំងឺឆ្លងដែលគេមិនធ្លាប់ស្គាល់ ហើយដែលបង្កការគំរាមកំហែងដល់ជីវិតរបស់ពួកគេ។

សីតុណ្ហភាពជាមធ្យមរបស់ផែនដីកើនឡើងប្រមាណ ១°C ចាប់តាំងពីចុងសតវត្សរ៍ទី ១៩ មក ដោយការឡើងកំដៅភាគច្រើន កើតនៅក្នុងរយៈពេល ៣៥ ឆ្នាំចុងក្រោយនេះ។ របាយការណ៍ស្តីពីជីវចម្រុះដែលរៀបចំឡើងដោយវេទិកាវិទ្យាសាស្ត្រ គោលនយោបាយអន្តររដ្ឋាភិបាលស្តីពីសេវាជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី (IPBES)[9] ឆ្នាំ២០១៩ បានព្រមានថា មានសត្វ និងរុក្ខជាតិ ១ លានប្រភេទ ប្រឈមនឹងការផុតពូជ ហើយការបាត់បង់បែបនេះព្រមទាំងបរាជ័យក្នុងការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងបង្កមហន្តរាយមកលើ មនុស្សក៏ដូចជាមកលើធម្មជាតិ។ ខណៈពេលដែលចំនួនប្រជាជន នៅក្នុងសកលលោក និងកើនពី ៧,៧ ពាន់លាននាក់ ដល់ ៩,៧ ពាន់លាននាក់ត្រឹមឆ្នាំ ២០៥០ ហើយធនធានធម្មជាតិកំពុងរងការគំរាមកំហែងដោយសារតែសកម្មភាពរបស់មនុស្ស យើងកំពុងប្រឈមនឹងសមរភូមិ ដើម្បីអាយុជីវិតរបស់យើង នេះបើតាមសម្តីរបស់អគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ លោក António Guterres។

ដើម្បីការរស់រានរបស់យើង យើងត្រូវរៀនរស់ជាមួយគ្នា ប្រកបដោយចីរភាព លើផែនដីនេះ។ យើងត្រូវធ្វើការផ្លាស់ប្តូររបៀបគិត និងរបៀបធ្វើសកម្មភាព ក្នុងនាមជាបុគ្គលម្នាក់ៗ និងក្នុងនាមជាសង្គមទាំងមូល។ ដូច្នេះការអប់រំក៏ត្រូវធ្វើការផ្លាស់ប្តូរផងដែរ ដើម្បីកសាងពិភពលោកប្រកបដោយសន្តិភាព និងចីរភាព ដើម្បីការរស់រាន និងវិបុលភាពរបស់មនុស្សជំនាន់នេះ និងជំនាន់ក្រោយ ។

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) កើតចេញពីភាពចាំបាច់ ដែលការអប់រំត្រូវឆ្លើយតបចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងចីរភាពដែលកំពុងបន្តកើនឡើង។ ESD ប្រើប្រាស់វិធីសាស្ត្រគរុកោសល្យបែបនវានុវត្តន៍ ផ្តោតលើការធ្វើសកម្មភាពជាក់ស្តែងដើម្បីផ្តល់លទ្ធភាពឱ្យអ្នកសិក្សាអភិវឌ្ឍន៍ចំណេះដឹង និងការយល់ដឹងក៏ដូចជាធ្វើសកម្មភាព ដើម្បីប្រែក្លាយសង្គមនេះឱ្យទៅជាសង្គមដែលកាន់តែមានចីរភាព។

ផ្អែកលើទសវត្សរ៍របស់អង្គការសហប្រជាជាតិ ស្តីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) (២០០៥-២០១៤) និងផែនការសកម្មភាពសកលស្តីពីESD(២០១៥-២០១៩)ក្របខ័ណ្ឌថ្មីមួយដែលមានឈ្មោះថា ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពសម្រាប់ឆ្នាំ ២០៣០ (ESD for 2030) ត្រូវបានអនុម័តដោយកិច្ចប្រជុំលើកទី ២០៦ នៃគណៈកម្មាធិការប្រតិបត្តិរបស់យូណេស្កូ និងមហាសន្និបាតលើកទី ៤០ របស់យូណេស្កូ និងត្រូវបានទទួលស្គាល់ដោយមហាសន្និបាតលើកទី ៧៤ របស់អង្គការសហប្រជាជាតិ។

ESD សម្រាប់ឆ្នាំ ២០៣០ ត្រូវបានរៀបចំឡើងផ្អែកតាមកម្មវិធីសកម្មភាពសកល (GAP) ដែលមានគោលបំណងតម្រង់ទិសពង្រឹងការអប់រំ និងការសិក្សា ដើម្បីរួមចំណែកដល់គ្រប់សកម្មភាពទាំងអស់ដែលលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។ កម្មវិធីនេះផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង លើការរួមចំណែកនៃការអប់រំដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព។ ESD សម្រាប់ឆ្នាំ ២០៣០ រួមចំណែកផ្ទាល់ដល់គោលដៅSDGទី៤ការអប់រំប្រកបដោយគុណភាព និងបរិយាបន្នជាពិសេសចំណុចដៅ ៤.៧ ក៏ដូចជា SDG ដទៃទៀតដែលមានបំណងផ្តល់ការអប់រំដែលឆ្លើយតប ដោយចាត់ទុកការទទួលខុសត្រូវ សម្រាប់មនុស្សជំនាន់ក្រោយថាជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងនេះ។

ដើម្បីអនុវត្តសកម្មភាពជាក់លាក់ សំដៅនាំមកនូវការផ្លាស់ប្តូរ ផែនទីបង្ហាញផ្លូវនេះបង្ហាញពីសកម្មភាព និងអន្តរាគមន៍ជាក់លាក់ ដែលអាចរៀបចំ និងទទួលបានការគាំទ្រពីរដ្ឋជាសមាជិក និងតួអង្គពាក់ព័ន្ធ ដូចជា អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ នៅថ្នាក់តំបន់ និងថ្នាក់សកលជាដើម។

ESD ២០៣០ លេចចេញជារូបរាង នៅពេលចាប់ផ្តើមទសវត្សរ៍សកម្មភាព (Decade of Action) ដើម្បីពន្លឿនវឌ្ឍនភាព ឆ្ពោះទៅសម្រេច SDG ទាំងអស់។ បច្ចុប្បន្ននេះគឺជាពេលដែលប្រព័ន្ធអប់រំទាំងអស់ត្រូវដឹកនាំការផ្លាស់ប្តូរជាវិជ្ជមានដែលចាំបាច់ដើម្បីឱ្យពិភពលោករបស់យើង ធ្វើដំណើរទៅមុខតាមផ្លូវដែលកាន់តែផ្តល់នូវភាពយុត្តិធម៌ និងចីរភាព ព្រោះថាអនាគតរួមគ្នារបស់ យើងពឹងអាស្រ័យលើសកម្មភាពដែលយើងទាំងអស់គ្នាធ្វើ នាពេលបច្ចុប្បន្ននេះ។

Stefania Giannini

អគ្គនាយករងទទួលបន្ទុកផ្នែកអប់រំរបស់យូណេស្កូ

[9] https://ipbes.net/global-assessment

© Jacaranda Designs, Chanuka Express, Nairobi, Kenya

មាតិកា

អារម្ភកថា iii

សេចក្តីសង្ខេប ៣

១. ការអំពាវនាវជាបន្ទាន់ ឱ្យមានការធ្វើសកម្មភាព ៥

១.១. តើយើងនៅទីណា ៦

១.២. តើចាំបាច់ត្រូវធ្វើអ្វីខ្លះ ៨

២. ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព សម្រាប់ឆ្នាំ ២០៣០ ១១

២.១. អ្វីទៅដែលហៅថាការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព សម្រាប់ឆ្នាំ ២០៣០ ១២

២.២. គោលដៅ និងវត្ថុបំណង ១៤

២.៣. លក្ខណៈសំខាន់ៗ ១៦

៣. សកម្មភាពជា អាទិភាព ២៥

ការជំរុញគោលនយោបាយ ២៦

ការផ្លាស់ប្តូរជាវិជ្ជមាននៃបរិយាកាសរៀនសូត្រ ២៨

កសាងសមត្ថភាពអ្នកអប់រំ ៣០

ផ្តល់ភាពអង់អាច និងកៀរគរយុវជន ៣២

ពន្លឿនសកម្មភាពនៅមូលដ្ឋាន ៣៤

៤. ការអនុវត្ត ៣៧

៤.១. ការអនុវត្ត ESD របស់ឆ្នាំ ២០៣០ នៅកម្រិតប្រទេស ៣៨

៤.២. កសាងភាពជាដៃគូ និងជំរុញការសហការ ៤០

៤.៣. ការអប់រំផ្សព្វផ្សាយ ដើម្បីជំរុញឲ្យមានការធ្វើសកម្មភាព ៤២

៤.៤. ការតាមដានបញ្ហា និងនិន្នាការនានា ៤៤

៤.៥. ការកៀរគរធនធាន ៤៦

៤.៦. ពិនិត្យតាមដានវឌ្ឍនភាព ៤៨

៤.៧. ការធ្វើផែនការសម្រាប់រយៈពេល ១០ ឆ្នាំទៀត ៥២

ឧបសម្ព័ន្ធ ៥៣

ក. សង្ខេបមួយទំព័រស្តីពីក្របខ័ណ្ឌការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព សម្រាប់ឆ្នាំ ២០៣០ ៥៤

ខ. ក្របខ័ណ្ឌសម្រាប់អនុវត្តការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD ក្រោយឆ្នាំ ២០១៩៖ ESD សម្រាប់ឆ្នាំ ២០៣០ ៥៥

គ. កថាខណ្ឌមួយចំនួនដែលត្រូវបានដកស្រង់ចេញពីសេចក្តីសម្រេចលេខ ៧២/២២២ (២០១៧) របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព នៅក្នុងក្របខ័ណ្ឌនៃរបៀបវារៈអភិវឌ្ឍន៍ចីរភាពឆ្នាំ ២០៣០ ៦៦

ឃ. កថាខណ្ឌមួយចំនួនដែលត្រូវបានដកស្រង់ចេញពីសេចក្តីសម្រេចលេខ ៧៤/២២៣ (២០១៩) របស់មហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព នៅក្នុងក្របខ័ណ្ឌនៃរបៀបវារៈអភិវឌ្ឍន៍ចីរភាពឆ្នាំ ២០៣០ ៦៦

ង. ប្រវត្តិ ESD ដោយសង្ខេប ៦៧

"យើងកាន់តែសួរសំណួរថា ចុះប្រសិនបើអ្វីដែលមនុស្សកំពុងរៀន មានភាពឆ្លើយតបពិតប្រាកដចំពោះជីវិតរបស់ពួកគេ ចុះប្រសិនបើអ្វីដែលពួកគេរៀនជួយធានាបាននូវការរស់រៀននៃភពផែនដីរបស់យើង។ ការអប់រំសម្រាប់ការភអិវឌ្ឍដោយចីរភាព អាចផ្តល់នូវចំណេះដឹង ការយល់ដឹង និងសកម្មភាព ដែលផ្តល់ភាពអង់អាចឱ្យមនុស្សអាចធ្វើការផ្លាស់ប្តូរខ្លួនឯង និងសង្គមទាំងមូលជាវិជ្ជមាន។

Stefania Giannini អគ្គនាយករងទទួលបន្ទុកផ្នែកអប់រំរបស់យូណេស្កូ

© Guillaume Bression/Sipa for UNESCO GREEN CITIZENS

សេចក្តីសង្ខេប

យូណេស្កូ គឺជាទីភ្នាក់ងារសហប្រជាជាតិ ដែលដឹកនាំការងារអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) ចាប់តាំងពីទសវត្សរ៍អប់រំរបស់អង្គការសហប្រជាជាតិ (២០០៥-២០១៤) មក ESD ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាផ្នែកមួយដ៏សំខាន់នៃរបៀបវារៈឆ្នាំ ២០៣០ ជាពិសេសគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤ (SDG 4) និងជាផ្នែកមួយដ៏សំខាន់ ដើម្បីជួយដល់ការសម្រេចគោលដៅ SDG ដទៃទៀត។

ផែនទីបង្ហាញផ្លូវនេះ បង្ហាញពីបញ្ហាប្រឈមបន្ទាន់ចំពោះមុខដែលផែនដីកំពុងជួបប្រទះ និងបង្ហាញពីជំហានបន្ទាប់ ដែលយូណេស្កូកំពុងអនុវត្តជាការឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ តាមរយៈការអប់រំ ដោយបង្ហាញលម្អិតពីចំណុចផ្តោត និងសកម្មភាពថ្មីៗ។ ជាការបន្តពីកម្មវិធីសកម្មភាពសកល (GAP) (២០១៥-២០១៩) ដែលរួមចំណែកដល់របៀបវារៈឆ្នាំ ២០៣០ និងគោល ដៅទាំង ១៧ ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព៖ ក្របខ័ណ្ឌឆ្ពោះទៅការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព (ហៅកាត់ថា *ESD សម្រាប់ឆ្នាំ ២០៣០*) ត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើនការរួមចំណែកនៃអប់រំ ដល់ការកសាងពិភពលោក ដែលកាន់តែមានយុត្តិធម៌ និងចីរភាព។ *ESD សម្រាប់ឆ្នាំ ២០៣០* និងពន្លឿនសកម្មភាព ជុំវិញសកម្មភាពជាអាទិភាពចំនួន ៥ ជាមួយនឹងការបន្តគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ ESD ដើម្បីសម្រេចគោលដៅ SDG ទាំង ១៧ ប្រកបដោយជោគជ័យ និងការផ្លាស់ប្តូរជាវិជ្ជមានរបស់បុគ្គល និងសង្គមទាំងមូលដែលចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមបន្ទាន់ដែលពាក់ព័ន្ធនឹងចីរភាព។

ឯកសារបោះពុម្ពផ្សាយនេះ បង្ហាញយ៉ាងច្បាស់ពីអ្វីដែល រដ្ឋជាសមាជិកត្រូវធ្វើ ពាក់ព័ន្ធនឹងសកម្មភាពជាអាទិភាពនីមួយៗ។ សម្រាប់**សកម្មភាពទី ១** ស្តីពីគោលនយោបាយត្រូវមានការបញ្ចូល ESD ទៅក្នុងគោលនយោបាយនៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងការអប់រំ និងការអភិវឌ្ឍដោយចីរភាព។ សម្រាប់**សកម្មភាពជាអាទិភាពទី ២** ស្តីពីបរិបទនៃការអប់រំ និងបណ្តុះបណ្តាលទាមទារឱ្យមានការយកចិត្តទុកដាក់ ដើម្បីជំរុញឱ្យមានការប្រើប្រាស់អភិក្រមស្ថាប័នទាំងមូល សំដៅជានាយ៉ាងណាឱ្យយើងអាចរៀនពីអ្វីដែលពាក់ព័ន្ធនឹងការរស់នៅរបស់យើង និងប្រើប្រាស់អ្វីដែលយើងរៀនក្នុងការរស់នៅរបស់យើង។

នៅក្នុង**សកម្មភាពទី ៣** ស្តីពីការកសាងសមត្ថភាពអ្នកអប់រំមានការផ្តោតការយកចិត្តទុកដាក់លើការផ្តល់ឱ្យអ្នកអប់រំ នូវចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទា ដែលចាំបាច់ ដើម្បីធ្វើអន្តរកាលឆ្ពោះទៅរកចីរភាព។ **សកម្មភាព អាទិភាពទី ៤** ផ្តោតលើយុវជនត្រូវទទួលស្គាល់ថាយុវជន គឺជាតួអង្គសំខាន់ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងចីរភាព និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដែលពាក់ព័ន្ធនានា។ **សកម្មភាពជាអាទិភាពទី ៥** ស្តីពីសកម្មភាពដែលត្រូវអនុវត្តនៅថ្នាក់មូលដ្ឋាន គូសបញ្ជាក់ពីសារៈសំខាន់នៃសកម្មភាពដែលត្រូវ អនុវត្តនៅក្នុងសហគមន៍ ព្រោះថាសហគមន៍នេះឯង គឺជាទីកន្លែង ដែលសកម្មភាពនាំមកនូវការផ្លាស់ប្តូរប្រកបដោយអត្ថន័យទំនងជាកើតមានជាងគេ។

ផែនទីបង្ហាញផ្លូវនេះរៀបរាប់ពីវិស័យសំខាន់ៗ សម្រាប់អនុវត្តក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ផងដែរ។ **គំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* នៅតាមប្រទេសនីមួយៗ** និងដឹកនាំការបញ្ជ្រាប ESD ទៅក្នុងការអប់រំ និងអភិវឌ្ឍដោយចីរភាព។ ក្របខ័ណ្ឌថ្មីនេះ មានគោលបំណងលើកទឹកចិត្តឱ្យមានការដឹកនាំពីរដ្ឋជាសមាជិក និងតួអង្គពាក់ព័ន្ធមកពីសហគមន៍អប់រំនិងអភិវឌ្ឍន៍ដោយចីរភាពតាមរយៈ**ការបង្កើតបណ្តាញ *ESD សម្រាប់ឆ្នាំ ២០៣០* (ESD-Net)** នៅថ្នាក់សកល និងថ្នាក់តំបន់។ កិច្ចខិតខំប្រឹងប្រែងអប់រំ **ផ្សព្វផ្សាយ និងស្វែងរកការគាំទ្រ** រួមនឹងការផ្តល់រង្វាន់ ESD ពីយូណេស្កូ-ជប៉ុន នឹងត្រូវពង្រឹងផងដែរ លើសពីនេះ ក៏នឹងមានការអនុវត្តក្របខ័ណ្ឌនេះឈរលើមូលដ្ឋានភស្តុតាង តាមរយៈការតាមដានពីបញ្ហា និងនិន្នាការនានានៅក្នុងវិស័យអប់រំ និងការអភិវឌ្ឍដោយចីរភាព និងការកៀរគរធនធានតាមរយៈការប្រើប្រាស់ឱ្យបានពេញលេញនូវជំនាញអន្តរវិស័យ របស់យូណេស្កូក៏ដូចជាដៃគូចម្រុះនានាដទៃទៀតគួរពង្រឹងបន្ថែមទៀតផងដែរ។ មិនមានការខិតខំប្រឹងប្រែងផ្សេងៗ ដើម្បីធ្វើការ**តាមដានវឌ្ឍនភាព**ក្នុងគោលបំណងសម្រេចចំណុចដៅ ៤.៧ នៃ SDG ឱ្យបានត្រឹមឆ្នាំ ២០៣០។

Oleg Senkov/ Shutterstock.com

១.

ការអំពាវនាវជាបន្ទាន់ឱ្យមានការធ្វើសកម្មភាព

១.១. តើយើងនៅទីណា

ស្ថានភាពបន្ទាន់ផ្នែកអាកាសធាតុនាពេលបច្ចុប្បន្ន ក៏ដូចជាវិបត្តិដទៃទៀត ដែលពាក់ព័ន្ធនឹងចីរភាពបរិស្ថាន គឺជាផលវិបាកនៃឥរិយាបថរបស់មនុស្ស។ សកម្មភាពជាសមូហភាពរបស់មនុស្ស បាននាំឱ្យមានការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីរបស់ផែនដី ក្នុងកម្រិតមួយដែលបង្កការគំរាមកំហែងដល់ការរស់រានរបស់យើងទាំងអស់គ្នា។ ការផ្លាស់ប្តូរនេះកាន់តែមានសន្ទុះឆាប់រហ័ស កើតឡើងជាគំហុកអាចមើលឃើញ និងពិបាកនឹងផ្លាស់ប្តូរត្រឡប់ទៅវិញជារៀងរាល់ថ្ងៃ។ ក្នុងចំណោមកំណើនសីតុណ្ហភាព ១°C នៅក្នុងសកលលោកទាំងមូល ២ ភាគ ៣ នៃកំណើននេះកើតឡើងនៅក្នុងរយៈពេល ១០០ ឆ្នាំ ចុងក្រោយចាប់តាំងពីឆ្នាំ ១៩៧៥ មកខណៈពេលដែលបរិមាណថាមពលកកើតឡើងវិញ និងថាមពលដែលមិនកកើតឡើងវិញ ដែលត្រូវបានទាញយកមកប្រើប្រាស់ជារៀងរាល់ឆ្នាំនៅក្នុងសកលលោកទាំងមូល កើនឡើងទ្វេដង ចាប់តាំងពីឆ្នាំ ១៩៨០ មក។[២]

មានភស្តុតាងបង្ហាញយ៉ាងជាក់ច្បាស់ថា ការផ្លាស់ប្តូរយ៉ាងគំហុកដែលមិនធ្លាប់មានកន្លងមក កំពុងតែកើតមាននាពេលបច្ចុប្បន្ន ហើយមនុស្សជាតិ គឺជាអ្នកដែលទទួលខុសត្រូវដោយផ្ទាល់។

គណៈកម្មាធិការអន្តរជាតិផ្នែកការប្រែប្រួលអាកាសធាតុ (IPCC) ព្រមានថា ដើម្បីទប់ស្កាត់ផលប៉ះពាល់នៃការកើនឡើងកម្តៅផែនដីនៅត្រឹម ១,៥°C រហូតដល់ចុងសតវត្សនេះ បើធៀបនឹងសេណារីយ៉ូ ២°C ដែលត្រូវបានចាត់ទុកថាជាគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ យើងចាំបាច់ "ត្រូវធ្វើការផ្លាស់ប្តូរឱ្យបានលឿន និងគ្រប់ជ្រុងជ្រោយ ក្នុងកម្រិតដែលមិនធ្លាប់មានកន្លងមកក្នុងគ្រប់សកម្មភាពទាំងអស់នៅក្នុងសង្គម។[៣]"

នេះមានន័យថា យើងមិនត្រឹមតែជាការឆ្លើយតបចំពោះបញ្ហាប្រឈមផ្នែកបរិស្ថានប៉ុណ្ណោះទេ ថែមទាំងត្រូវធ្វើការកែសម្រួលឡើងវិញ នូវបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងសង្គម និងសេដ្ឋកិច្ច ដូចជាវិសមភាពដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយនឹងមូលហេតុដែលនាំឱ្យមានបញ្ហាទាំងនេះ និងផលប៉ះពាល់នៃបញ្ហាទាំងនេះ។

អ្វីដែលយើងដឹង អ្វីដែលយើងជឿ និងអ្វីដែលយើងធ្វើចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ អ្វីដែលយើងបានដឹងកន្លងមក ពុំបានត្រៀមខ្លួន ដើម្បីទប់ទល់ និងបញ្ហាប្រឈមនេះឡើយ។

ស្ថានភាពបែបនេះមិនអាចមកបន្លាយពេលទៀតនោះឡើយ ហើយឱកាសក៏កំពុងរលាយបាត់ទៅបន្តិចម្តងៗយ៉ាងឆាប់រហ័ស។

យើងត្រូវរៀនរស់នៅតាមបែបផ្សេង និងត្រូវចាត់ទុករឿងនេះ ថាជារឿងបន្ទាន់ដែលត្រូវធ្វើ។

រូបភាពទី ១. តើយើងទៅកៀកនឹង ១,៥°C កម្រិតណា?

ក្នុងឆ្នាំ ២០១៧ ការកើនឡើងកម្តៅ ដែលបង្កឡើងដោយមនុស្សដល់ប្រមាណ ១°C លើសពីកម្រិតមុនឧស្សាហកម្ម។

ការប្រែប្រួលនៃសីតុណ្ហភាពក្នុងសកលលោកទាំងមូល ធៀបនឹង ១៨៥០-១៩០០ (°C)



នៅក្នុងឆ្នាំ ២០១៧ កម្តៅដែលបង្កឡើងដោយសារមនុស្សកើនឡើងជិតដល់ប្រមាណ ១°C ខាងលើកម្រិតមុនឧស្សាហកម្ម។ ក្នុងអត្រាដូចបច្ចុប្បន្ននេះ សីតុណ្ហភាពនៅក្នុងសកលលោកទាំងមូលឡើងដល់ ១,៥°C នៅឆ្នាំ ២០៤០។ សេណារីយ៉ូ ១,៥°C ដែលបង្ហាញនៅ ទីនេះ ទាមទារឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលត្រូវចាប់ផ្តើមធ្វើជាបន្ទាន់ និងត្រូវកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច ឱ្យនៅសូន្យត្រឹមឆ្នាំ ២០៥៥។

ប្រភព៖ FAQ ១.២ រូបភាពទី ១ នៅក្នុងជំពូកទី ១ ដកស្រង់ចេញពី Allen, M.R., O.P. Dube, W. Solecki, F. Aragón-Durand, W. Cramer, S. Humphreys, M. Kainuma, J. Kala, N. Mahowald, Y. Mulugetta, R. Perez, M. Wairiu, and K. Zickfeld, 2018: Framing and Context. In: Global Warming of 1.5°C។ របាយការណ៍ពិសេសរបស់ IPCC ស្តីពីផលប៉ះពាល់នៃកើនឡើងកម្តៅផែនដីក្នុងកម្រិត 1,5°C ខាងលើកម្រិតមុនឧស្សាហកម្ម និងកន្លងនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅក្នុងសកលលោកទាំងមូល ក្នុងបរិបទនៃការពង្រឹង ការឆ្លើយតបជាសកលចំពោះការគំរាមកំហែង ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍ ដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្រ [Masson-Delmotte, V., P. Zhai, H.-O. Pörtner, D. Roberts, J. Skea, P.R. Shukla, A. Pirani, W. Moufouma-Okia, C. Péan, R. Pidcock, S. Connors, J.B.R. Matthews, Y. Chen, X. Zhou, M.I. Gomis, E. Lonnoy, T. Maycock, M. Tignor, and T. Waterfield (eds.)]. In Press.

[២] https://earthobservatory.nasa.gov/world-of-change/DecadalTemp
[៣] https://www.ipcc.ch/sr15/

យើងកំពុងស្ថិតនៅក្នុងសមរភូមិ ដើម្បីជីវិតរបស់យើង។ ប៉ុន្តែវាជាសមរភូមិដែលយើងអាចទទួលជ័យជម្នះ។
Stefania Giannini អគ្គនាយករងទទួលបន្ទុកផ្នែកអប់រំរបស់យូណេស្កូ
Kolidzei/Shutterstock.com

១.២. តើចាំបាច់ត្រូវធ្វើអ្វីខ្លះ

ដើម្បីបោះជំហានទៅរកអនាគតប្រកបដោយចីរភាព យើងចាំបាច់ត្រូវគិតឡើងវិញ ពីអ្វីដែលយើងបានរៀន កន្លែងដែលយើងរៀន និងរបៀបដែលយើងរៀន ដើម្បីអភិវឌ្ឍចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទា ដែលផ្តល់លទ្ធភាពឱ្យយើងទាំងអស់គ្នាអាចធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ក៏ដូចជាធ្វើសកម្មភាពជាលក្ខណៈបុគ្គល និងជាសមូហភាព ដើម្បីឆ្លើយតបចំពោះស្ថានភាពបន្ទាន់នៅក្នុងមូលដ្ឋាន នៅក្នុងប្រទេស និងនៅក្នុងសកលលោកទាំងមូល។

តើយើងត្រូវធ្វើយ៉ាងណា ដើម្បីត្រៀមអ្នកសិក្សានៅគ្រប់វ័យទាំងអស់ សម្រាប់សមរភូមិ ដើម្បីជីវិតរបស់យើង ដូចដែលត្រូវបានលើកឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ?

ការអប់រំសម្រាប់អភិវឌ្ឍន៍ដោយចីរភាព (ESD) គឺជាក្របខ័ណ្ឌដ៏រឹងមាំ ដើម្បីសម្រេចគោលដៅនេះ។

ESD ផ្តល់ឱ្យអ្នកសិក្សានូវចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទា ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ និងធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ ដើម្បីបូរណភាពបរិស្ថាន ប្រសិទ្ធភាពសេដ្ឋកិច្ច និងសង្គមប្រកបដោយយុត្តិធម៌ ដែលផ្តល់ភាពអង់អាចដល់មនុស្សគ្រប់យេនឌ័រទាំងអស់ ទាំងជំនាន់នេះ និងទាំងជំនាន់ក្រោយ ហើយក្នុងពេលជាមួយគ្នាគោរពភាពចម្រុះនៃវប្បធម៌របស់ពួកគេ។

ESD គឺជាដំណើរការរៀនសូត្រពេញមួយជីវិត និងជាផ្នែកមួយដ៏សំខាន់នៃការអប់រំប្រកបដោយគុណភាព ដែលធ្វើឱ្យកាន់តែប្រសើរនៅផ្នែកបញ្ញា សង្គម ចិត្ត និងឥរិយាបថ នៅក្នុងការរៀនសូត្រ។ ESD មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន និងគ្រប់ដណ្តប់លើខ្លឹមសារ និងលទ្ធផលនៃការសិក្សា វិធីសាស្រ្តគរុកោសល្យ និងបរិយាកាសរៀនសូត្រផងដែរ។

ESD ត្រូវបានទទួលស្គាល់ថាជាកត្តាមួយដ៏សំខាន់ ដើម្បីជួយដល់ការសម្រេចគោលដៅ SDG ទាំងអស់ និងសម្រេចគោលបំណងដែលបានដាក់ចេញ តាមរយៈការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម។

ការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម៖ ជួយដល់ការសម្រេច SDG ដើម្បីឈានទៅកសាងពិភពលោកមួយកាន់តែមានចីរភាព។

វិធីសាស្រ្តគរុកោសល្យ និងបរិយាកាសរៀនសូត្រ៖ ប្រើប្រាស់វិធីសាស្រ្តគរុកោសល្យបែបសិស្សមជ្ឈមណ្ឌល ដែលមានលក្ខណៈអន្តរកម្ម ក្នុងទម្រង់ជាការអនុវត្តគម្រោង។ ធ្វើការផ្លាស់ប្តូរគ្រប់ទិដ្ឋភាពទាំងអស់ នៃបរិយាកាសរៀនសូត្រ ដោយប្រើប្រាស់អភិក្រមដែលមានការចូលរួមពីគ្រប់ផ្នែកទាំងអស់របស់ស្ថាប័ន ក្នុងការអនុវត្ត ESD ដើម្បីជួយឱ្យសិស្សអាចយកអ្វី ដែលពួកគេបានរៀនទៅប្រើប្រាស់នៅក្នុងការរស់នៅ និងទទួលបានមេរៀនពីការរស់នៅរបស់ពួកគេមកវិញ។

លទ្ធផលនៃការសិក្សា៖ ផ្តល់ភាពអង់អាចឱ្យមនុស្សទទួលខុសត្រូវចំពោះមនុស្សជំនាន់នេះ និងមនុស្សជំនាន់ក្រោយ និងរួមចំណែកយ៉ាងសកម្ម ដល់ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម។

ខ្លឹមសារនៃការសិក្សា៖ បញ្ចូលបញ្ហាដែលពាក់ព័ន្ធនឹងចីរភាព ជាពិសេសបញ្ហាដែលត្រូវបានដាក់ចេញនៅក្នុងគោលដៅ SDG ទាំង ១៧ ដូចជាការប្រែប្រួលអាកាសធាតុជាដើម ទៅក្នុងការរៀនសូត្រគ្រប់ប្រភេទទាំងអស់។

មហាសន្និបាតអង្គការសហប្រជាជាតិ បានគូសបញ្ជាក់ជាថ្មីថា ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព គឺជាសមាសភាគមួយដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព ផ្តោតលើការអប់រំប្រកបដោយគុណភាព និងជាកត្តាមួយដ៏សំខាន់ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់ផ្សេងទៀត។

សេចក្តីសម្រេចលេខ ៧២/២២២ (២០១៧) របស់មហាសន្និបាតអង្គការសហប្រជាជាតិ

ប្រទេសកាន់តែច្រើនលើកឡើងថា ESD ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយអប់រំ ការបណ្តុះបណ្តាលគ្រូ និងកម្មវិធីសិក្សារបស់ខ្លួន។ ប៉ុន្តែ ជារឿយៗ ESD ត្រូវបានគេបកស្រាយជាលក្ខណៈចង្អៀតថាផ្តោតតែទៅលើបញ្ហាតាមប្រធានបទមួយចំនួនប៉ុណ្ណោះ ចៀសជាងបកស្រាយថាវាជាអភិក្រមគ្រប់ជ្រុងជ្រោយ ដែលផ្តោតលើខ្លឹមសារនៃការសិក្សាគរុកោសល្យ និងលទ្ធផលនៃការសិក្សា ដើម្បីនាំមកនូវការផ្លាស់ប្តូរឥរិយាបថជាមូលដ្ឋាន សំដៅឈានទៅសម្រេចការអភិវឌ្ឍប្រកបដោយចីរភាព។

រូបភាពទី២.ភាគរយនៃប្រទេសដែលឆ្លុះបញ្ចាំងគោលការណ៍នៃអនុសាសន៍ដែលផ្តល់ដោយយូណេស្កូឆ្នាំ១៩៧៤ទៅក្នុងគោលនយោបាយស្តីពីការអប់រំ ការអប់រំគ្រូ និងកម្មវិធីសិក្សារបស់ខ្លួន ២០១២-២០១៦



ប្រភព៖ របាយការណ៍ស្តីពីការពិនិត្យតាមដានការអប់រំជាសកលឆ្នាំ ២០១៩ (UNESCO, 2018) ទំព័រ ២០៥

រូបភាពទី ៣. ភាគរយនៃការលើកឡើងពីការរៀនសូត្រ សង្គម និងចិត្ត និងឥរិយាបថដោយខ្លឹមសារនៃ ESD



ប្រភព៖ ឯកសារដែលមានចំណងជើងថា ការពិនិត្យមើលខ្លឹមសារអប់រំឱ្យកាន់តែជិតស្និទ្ធ៖ ពិនិត្យលើទិដ្ឋភាពនៃការសិក្សា *ESD និង GCE* (UNESCO, 2020) ទំព័រ ២៦

ឧទាហរណ៍ ការសិក្សាដែលធ្វើឡើងដោយយូណេស្កូ កាលពីពេលថ្មីៗ ដែលពិនិត្យមើលឯកសារគោលនយោបាយរបស់ប្រទេសចំនួន ១០ បង្ហាញថា ESD ភាគច្រើនមានទំនាក់ទំនងជាមួយនឹងការបង្រៀន ចំណេះដឹង វិទ្យាសាស្ត្រ ដែលផ្តោតលើបរិស្ថាន។ ការបង្រៀនបែបនេះគឺមិនគ្រប់គ្រាន់ ក្នុងការប្រើប្រាស់អានុភាពនៃការអប់រំ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានឱ្យអស់សក្តានុពលនោះឡើយ។

តើយើងអាចផ្តល់ការលើកទឹកចិត្តដល់អ្នកសិក្សាដោយរបៀបណា ដើម្បីឱ្យពួកគេអាចធ្វើសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីចីរភាព សំដៅសម្រួចអនាគតបែបផ្សេង សម្រាប់យើងទាំងអស់គ្នា មុនពេលដែលវាយឺតពេល?

ដើម្បីធានាថាបុគ្គលម្នាក់ៗអាចយល់អំពីបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងចីរភាព និងពីភាពពាក់ព័ន្ធនៃបញ្ហាប្រឈមទាំងនេះ ជាមួយនឹងតថភាពដែលនៅជុំវិញពួកគេ និងធ្វើសកម្មភាព ដើម្បីនាំមកនូវការផ្លាស់ប្តូរ។

ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងប្រព័ន្ធសេដ្ឋកិច្ច និងសង្គម នាពេលបច្ចុប្បន្នតាមរយៈការផ្សព្វផ្សាយពីគុណតម្លៃផ្សេងៗ និងវិធីសាស្ត្រដែលត្រូវបានកែសម្រួលឱ្យស្របតាមបរិបទនីមួយៗ។

ដើម្បីឆ្លើយតបចំពោះឱកាស និងហានិភ័យថ្មីៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព ដែលបានពីបច្ចេកវិទ្យាថ្មីៗ

ការអប់រំចាំបាច់ត្រូវមានការផ្លាស់ប្តូរ។

ក្របខ័ណ្ឌសកលថ្មី ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់យូណេស្កូ ដែលមានឈ្មោះថា ESD សម្រាប់ឆ្នាំ ២០៣០ អញ្ជើញឱ្យអ្នកចូលរួមនៅក្នុងបេសកកម្មបន្ទាន់នេះ។

Ivan Smuk/ Shutterstock.com

២.

ការអប់រំសម្រាប់ការអភិវឌ្ឍ ដោយចីរភាព សម្រាប់ឆ្នាំ ២០៣០

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព៖ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ចីរភាព (ហៅកាត់ថា ESD សម្រាប់ឆ្នាំ ២០៣០) គឺជាក្របខ័ណ្ឌសកលសម្រាប់អនុវត្ត ESD ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០៣០។

២.១. អ្វីទៅដែលហៅថាការអប់រំ សម្រាប់ការ អភិវឌ្ឍដោយចីរភាព សម្រាប់ឆ្នាំ ២០៣០

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព៖ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ចីរភាព (ហៅកាត់ថា *ESD សម្រាប់ឆ្នាំ ២០៣០*) គឺជាក្របខ័ណ្ឌសកលសម្រាប់អនុវត្ត ESD ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០៣០។

SED សម្រាប់ឆ្នាំ ២០៣០ ត្រូវបានរៀបចំឡើងផ្អែកតាមមេរៀនដែលទទួលបានពីការអនុវត្តកម្មវិធីសកម្មភាពសកលស្តីពី ESD (GAP២០១៥-២០១៩) ជាការឆ្លើយតបចំពោះការផ្តល់សារៈសំខាន់កាន់តែខ្លាំងលើ ESD ដើម្បីឱ្យខ្លឹមសារនៃការសិក្សាកាន់តែរួមចំណែកដល់ការរស់រាន និងវិបុលភាពរបស់មនុស្សជាតិ។

ESD សម្រាប់ឆ្នាំ ២០៣០ គូសបញ្ជាក់ពីការរួមចំណែកនៃវិស័យអប់រំដល់ការសម្រេចគោលដៅ SDG។ ក្របខ័ណ្ឌនេះមានគោលបំណងពិនិត្យលើគោលបំណង និងគុណតម្លៃនៃការអប់រំ និងធ្វើការតម្រង់ទិសការអប់រំ និងការសិក្សានៅគ្រប់កម្រិតទាំងអស់ ឱ្យរួមចំណែកដល់ការសម្រេចការអភិវឌ្ឍដោយចីរភាព ព្រមទាំងពង្រឹងការអប់រំ និងការរៀនសូត្រក្នុងគ្រប់សកម្មភាពទាំងអស់ ដែលលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។ ដោយសារតែពេលវេលាដែលនៅសេសសល់ ដើម្បីសម្រេចគោលដៅ SDG នៅមានតិចតួចបំផុតជាការសំខាន់ណាស់ដែលត្រូវពន្លឿន ESD ក្នុងទសវត្សរ៍ សកម្មភាព[៤] ដើម្បីសម្រេចគោលដៅទាំងនេះ។

បន្ទាប់ពីកម្មវិធី GAP ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ត្រូវបានអនុម័តដោយមហាសន្និបាតយូណេស្កូក្នុងសម័យប្រជុំលើកទី៤០ និងបានទទួលការទទួលស្គាល់ពីមហាសន្និបាតអង្គការសហប្រជាជាតិក្នុងសម័យប្រជុំលើកទី ៧៤ ក្នុងឆ្នាំ ២០១៩។

[៤] https://www.un.org/sustainabledevelopment/decade-of-action/

ការអប់រំ សម្រាប់ការអភិវឌ្ឍ
ដោយចីរភាព៖ ឆ្ពោះទៅ
សម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព
(ESD សម្រាប់ឆ្នាំ ២០៣០)គឺជាក្របខ័ណ្ឌ
សកលសម្រាប់អនុវត្ត ESD ពីឆ្នាំ ២០២០-
២០៣០។

narikan/Shutterstock.com

២.២. គោលដៅ និងវត្ថុបំណង

ESD គឺជាសមាសភាគមួយដ៏សំខាន់នៃគោលដៅ SDG និងជាពិសេសចំណុច ៤.៧ និងត្រូវបានរៀបចំឡើងផ្អែកតាមចក្ខុវិស័យដែលត្រូវបានដាក់ចេញនូវទសវត្សរ៍អប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់អង្គការសហប្រជាជាតិ (២០០៥-២០១៤) និងកម្មវិធី GAP (២០១៥-២០១៩)។

ខណៈពេលដែល ESD រួមចំណែកដល់ SDG ទាំង ១៧ ក្របខ័ណ្ឌនេះនៅតែមានភាពពាក់ព័ន្ធ និងរបៀបវារៈអប់រំសកល ដែលត្រូវបានដាក់ចេញនៅក្នុង SDG ទី ៤ ដែលក្នុងនោះ ESD ត្រូវបានគូសបញ្ជាក់ជាពិសេស។ ESD គឺជាធាតុផ្សំមួយដ៏សំខាន់នៃការអប់រំប្រកបដោយគុណភាព។ សមត្ថភាពដែលមានលក្ខណៈអន្តរវិស័យ ដែលផ្តោតលើទិដ្ឋភាពសមត្ថភាពពុទ្ធិ (cognitive) ចិត្តសង្គម និងឥរិយាបថ មានភាពពាក់ព័ន្ធជាពិសេស ជាមួយនឹងគ្រប់ផ្នែកទាំងអស់នៃការអប់រំ។

ការគូសបញ្ជាក់ជាពិសេសលើសមត្ថភាពមួយចំនួនដែលពាក់ព័ន្ធនឹងការយល់ពីស្ថានភាពអ្នកដទៃ សាមគ្គីភាព និងការផ្តួចផ្តើមធ្វើសកម្មភាព អាចជួយសម្រេចគោលដៅ SDG ទី ៤ ក្នុងការកសាងអនាគតដែលការអប់រំរួមចំណែក មិនត្រឹមតែដល់ការសម្រេចជោគជ័យរបស់បុគ្គលម្នាក់ប៉ុណ្ណោះនោះទេ ថែមទាំងដល់ការរស់រាន និងវិបុលភាពជាសមូហភាពរបស់សហគមន៍សកលផងដែរ។ កម្មវិធីនេះ ក៏នឹងជួយរបៀបវារៈអប់រំសកលឱ្យងាកចេញពីការផ្តោតតែមួយមុខលើការចូលរៀន និងគុណភាព ដែលត្រូវបានវាស់វែង តាមរយៈលទ្ធផលនៃការសិក្សា ទៅរកការបង្កើនការយកចិត្តទុកដាក់លើខ្លឹមសារនៃការសិក្សា និងការរួមចំណែកនៃខ្លឹមសារទាំងនេះ ដល់ការធានាបាននូវចីរភាពរបស់មនុស្ស និងភពផែនដី។ ដូច្នេះ ESD បានជួយភ្ជាប់ទំនាក់ទំនងរវាង SDG ទី ៤ ជាមួយនឹង SDG ដទៃទៀត។

គោលដៅ

SDG សម្រាប់ឆ្នាំ ២០៣០ មានគោលបំណងកសាងនៅពិភពលោកមួយកាន់តែយុត្តិធម៌ និងមានចីរភាពតាមរយៈការពង្រឹង ESD និងរួមចំណែកដល់ការសម្រេច SDG ទាំង ១៧។

វត្ថុបំណង

ដើម្បីបញ្ចូល ESD និង SDG ទាំង ១៧ ឱ្យបានពេញលេញទៅក្នុងគោលនយោបាយបរិយាកាសនៃការសិក្សា ការកសាងសមត្ថភាពអ្នកអប់រំ ការលើកកម្ពស់ភាពអង់អាច និងការកៀរគរយុវជន និងការអនុវត្តសកម្មភាពនៅនឹងមូលដ្ឋាន។

ចំណុចដៅ SDG ៤.៧

ចំណុចដៅ SDG ៤.៧ គឺជាចំណុចដៅមួយ ក្នុងចំណោមចំណុចដៅសំខាន់ៗ នៅក្នុង SDG ដែលផ្តោតការយកចិត្តទុកដាក់លើគោលបំណង និងគុណភាពនៃការអប់រំ។

ចំណុចដៅ SDG ៤.៧៖

ត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឱ្យអ្នកសិក្សាគ្រប់រូបទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពជាអាទិ៍ តាមរយៈការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព និងរបៀបរស់នៅនៃការរស់នៅប្រកបដោយចីរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាព និងអហិង្សា ភាពជាប្រជាពលរដ្ឋសកល និងការយល់ពីលក្ខណៈចម្រុះរបស់វប្បធម៌ និងការរួមចំណែកនៃវប្បធម៌ចំពោះការអភិវឌ្ឍដោយចីរភាព។

ចំណុចដៅ ៤.៧

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព និងភាពជាប្រជាពលរដ្ឋសកល

> ESD សម្រាប់ឆ្នាំ ២០៣០ នឹងជំរុញឱ្យមានការបញ្ជ្រាបការអភិវឌ្ឍដោយចីរភាព និង SDG ទៅក្នុងការអប់រំ និងការសិក្សា ក៏ដូចជាធានាយ៉ាងណាឱ្យមានការបញ្ជ្រាបការអប់រំ និងការសិក្សា ទៅក្នុងគ្រប់សកម្មភាពទាំងអស់ ដែលលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព និងគោលដៅ SDG។

HappyChildren/Shutterstock.com

២.៣. លក្ខណៈសំខាន់ៗ

កិច្ចខិតខំប្រឹងប្រែងជាសកល ដែលដឹកនាំដោយអ្នកធ្វើគោលនយោបាយ អ្នកអប់រំ អ្នកសិក្សា[៥] អ្នកអនុវត្តការងារ និងយុវជនតាមរយៈកម្មវិធី GAP ទសវត្សរ៍ ESD របស់អង្គការសហប្រជាជាតិ ក៏ដូចជាកម្មវិធីដទៃទៀតបានសម្រេចនូវវឌ្ឍនភាពជាច្រើននៅក្នុងគ្រប់តំបន់ទាំងអស់របស់ពិភពលោក។ ផ្អែកតាមមេរៀនដែលទទួលបានទាំងនេះ កម្មវិធី ESD សម្រាប់ឆ្នាំ ២០៣០ ធ្វើការឆ្លើយតបចំពោះបញ្ហាប្រឈមថ្មីៗ ដែលកំពុងកើតមាននាពេលបច្ចុប្បន្ន ជាពិសេសតាមរយៈមុខងារសំខាន់ចំនួន ៣ ដូចជាការយកចិត្តទុកដាក់លើតួនាទីនៃវិស័យអប់រំ ដើម្បីសម្រេច SDG ទាំង ១៧, ការផ្តោតការយកចិត្តទុកដាក់លើការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានធំៗ, និងការយកចិត្តទុកដាក់លើការដឹកនាំរបស់រដ្ឋជាសមាជិក។

ការយកចិត្តទុកដាក់លើតួនាទីរបស់វិស័យអប់រំក្នុងការសម្រេចគោលដៅ SDG ទាំង ១៧

មុខងារសំខាន់ទី ១ នៃកម្មវិធី *ESD សម្រាប់ឆ្នាំ ២០៣០* គឺការផ្តោតការយកចិត្តទុកដាក់លើតួនាទីរបស់វិស័យអប់រំ ក្នុងការសម្រេចគោលដៅ SDG ទាំង ១៧ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា។ សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៧២/២២២ (២០១៧) កត់សម្គាល់ថា ESD គឺជាសមាសភាគមួយដ៏សំខាន់នៃគោលដៅ SDG ទី ៤ ស្តីពីការអប់រំ ហើយគឺជាកត្តាមួយដ៏សំខាន់ ដែលជួយដល់ការសម្រេចគោលដៅ SDG ទាំងអស់ផ្សេងទៀត ខណៈពេលដែលសេចក្តីសម្រេចលេខ ៧៤/២៣៣ (២០១៩) ធ្វើការពង្រឹងបន្ថែមលើចំណុចនេះតាមរយៈការអំពាវនាវឱ្យប្រទេសនានា កែលម្អការអនុវត្ត ESD របស់ខ្លួន។

ដូច្នេះ តើ ESD អាចជួយដល់ការសម្រេចគោលដៅ SDG ទាំង ១៧ ដោយរបៀបណា?

- ✓ **ESD បង្កើនការយល់ដឹងអំពីគោលដៅទាំង ១៧ នៅតាមគ្រឹះស្ថានអប់រំ៖** ESD បង្កើនការយល់ដឹងរបស់អ្នកសិក្សា និងសាធារណៈជនទូទៅអំពីអ្វីទៅដែលហៅថាគោលដៅ SDG និងថាតើគោលដៅទាំងនេះមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះជាមួយនឹងជីវិតរបស់បុគ្គលម្នាក់ៗ និងជីវិតនៅក្នុងសង្គមទាំងមូល។
- ✓ **ESD បង្កើនការយល់ដឹងសំខាន់ៗ អំពី SDG ទៅតាមបរិបទ៖** ជារឿយៗការអភិវឌ្ឍដោយចីរភាពទាមទារឱ្យមានការរក្សាតុល្យភាពរវាងការយល់ឃើញ និងអាទិភាពផ្សេងៗគ្នា។ ESD នាំឱ្យមានការសួរសំណួរអំពីភាពប្រទាំងប្រទើសរវាង SDG ផ្សេងៗនឹងផ្តល់ឱ្យអ្នកសិក្សានូវឱកាសឈ្វេងយល់ពីសកម្មភាពដែលត្រូវធ្វើ ដើម្បីឱ្យមានតុល្យភាព ដោយប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន។
- ✓ **ESDកៀរគរសកម្មភាពដើម្បីឈានទៅសម្រេចគោលដៅSDG៖** កិច្ចខិតខំប្រឹងប្រែងនៅក្នុង ESD មានគោលបំណងឆ្លើយតបចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពជាពិសេសគោលដៅ SDG។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបន្តកៀរគរសកម្មភាព ដើម្បីឈានទៅសម្រេចការអភិវឌ្ឍដោយចីរភាពនៅក្នុងបរិបទនៃការអប់រំ ជាពិសេសនៅតាមសហគមន៍ តាមរយៈការប្រើប្រាស់អភិក្រមទូទាំងស្ថាប័ន ដើម្បីអនុវត្ត ESD។

---

[៥] "អ្នកសិក្សា" សំដៅលើសិស្សនៅតាមសាលារៀនក្នុងប្រព័ន្ធ និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET), សិក្ខាកាមនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលរបស់ ក្រុមហ៊ុនឯកជន, អ្នកដែលចូលរួមនៅក្នុងកម្មវិធីសិក្សាពេញមួយជីវិត, និងក្នុងគ្រឹះស្ថាន និងស្ថានភាពសិក្សាក្រៅប្រព័ន្ធ និងអ្នកដែលស្ថិតនៅក្រៅគ្រឹះស្ថានអប់រំ។ "អ្នកអប់រំ" រួមមានគ្រូបង្រៀន អ្នកបណ្តុះបណ្តាល អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋាន មាតាបិតា និងសមាជិកគ្រួសារ។

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព មានគោលបំណងបង្កើនចំណេះដឹង ការយល់ដឹង និងសកម្មភាព *ដើម្បី៖*

ផ្តោតសំខាន់លើការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានធំៗ

ESD ត្រូវផ្តោតលើការផ្លាស់ប្តូរជាវិជ្ជមានធំៗ ដែលចាំបាច់ ដើម្បីសម្រេចការអភិវឌ្ឍដោយចីរភាព និងដាក់ចេញនូវអន្តរាគមន៍អប់រំ ដែលឆ្លើយតប។ ការផ្លាស់ប្តូរជាវិជ្ជមានធំៗ មានន័យថាជាការផ្លាស់ប្តូរសកម្មភាពរបស់បុគ្គលម្នាក់ៗ រួមនឹងការរៀបចំរចនាសម្ព័ន្ធសង្គមឡើងវិញ ដូច្នេះ ESD ចាំបាច់ត្រូវតាមដានការផ្លាស់ប្តូរជាវិជ្ជមានដើម្បីឈានទៅសម្រេចតាមទិសដៅ ដែលកាន់តែផ្តល់ភាពយុត្តិធម៌ និងចីរភាព។

តើមានចំណុចឆ្លុះបញ្ចាំងសំខាន់ៗអ្វីខ្លះ ដែលផ្តល់ជាព័ត៌មានដល់ការរៀបចំកម្មវិធី *ESD សម្រាប់ឆ្នាំ ២០៣០*?

- ✓ **សកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន៖** ការផ្លាស់ប្តូរសំខាន់ៗដែលចាំបាច់ ដើម្បីកសាងនូវអនាគតប្រកបដោយចីរភាពចាប់ផ្តើមចេញពីបុគ្គលម្នាក់ៗ។ ESD ត្រូវផ្តោតការយកចិត្តទុកដាក់លើរបៀបដែលអ្នកសិក្សាម្នាក់ៗ អនុវត្តសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីលើកកម្ពស់ចីរភាព ហើយក៏ផ្តល់សារៈសំខាន់ដល់ការផ្តល់ឱកាសឱ្យអ្នកសិក្សាបានឃើញពីតថភាព និងដឹងពីរបៀបដែលពួកគេអាចមានឥទ្ធិពលលើការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមដើម្បីឈានទៅកសាងអនាគតប្រកបដោយចីរភាព។ ការអនុវត្ត ESD ប្រៀបបីដូចជាការអនុវត្តភាពជាប្រជាពលរដ្ឋដូច្នោះដែរ។
- ✓ **ការផ្លាស់ប្តូររចនាសម្ព័ន្ធ៖** ESD ត្រូវយកចិត្តទុកដាក់ចំពោះមូលហេតុ ដែលចាក់ឫសគល់យ៉ាងជ្រៅ ដែលនាំឱ្យមានការអភិវឌ្ឍដែលពុំមានចីរភាព។ ចាំបាច់ត្រូវមានការរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព ហើយ ESD គួរលើកទឹកចិត្តឱ្យអ្នកសិក្សា ឈ្វេងយល់គុណតម្លៃនានា ដែលជាគុណតម្លៃផ្សេងខុសពីគុណតម្លៃនៅក្នុងសង្គម ដែលផ្តល់តម្លៃដល់ការប្រើប្រាស់ ក៏ដូចជាការមានទស្សនៈជុំវិញរបៀបឆ្លើយតបចំពោះ ESD នៅក្នុងបរិបទនៃភាពក្រីក្រ និងភាពងាយរងគ្រោះធ្ងន់ធ្ងរ។
- ✓ **បច្ចេកវិទ្យានាពេលអនាគត៖** ESD ត្រូវឆ្លើយតបចំពោះឱកាស និងបញ្ហាប្រឈមនានា ដែលកើតឡើងដោយសារការរីកចម្រើនផ្នែកបច្ចេកវិទ្យា។ បញ្ហា "ចាស់ៗ" មួយចំនួននឹងត្រូវដោះស្រាយតាមរយៈបច្ចេកវិទ្យាប៉ុន្តែទន្ទឹមគ្នានេះក៏កើតមាននូវបញ្ហាប្រឈម និងហានិភ័យថ្មីៗ ផងដែរ។ ការគិតពិចារណាបែបល្អិតល្អន់ និងគុណតម្លៃចីរភាពកាន់តែមានភាពពាក់ព័ន្ធដូច្នេះការបង្រៀនអំពី ESD ក៏អាចកាន់តែជួបនូវការលំបាកជាមួយនឹងការយល់ខុសថាបច្ចេកវិទ្យាអាចដោះស្រាយបញ្ហាចីរភាពបានមួយភាគធំ។

(.........) ការផ្លាស់ប្តូរជាវិជ្ជមានទាមទារឱ្យមានការរំខានក្នុងកម្រិតមួយ ដែលក្នុងនោះមនុស្សសម្រេចចិត្តចេញទៅខាងក្រៅបរិវេណសុវត្ថិភាពជាធម្មតារបស់ខ្លួន ឬនិយាយម្យ៉ាងទៀតចេញពីរបៀបគិត ឥរិយាបថ ឬការរស់នៅតាមបែប "ធម្មតា"។ វាតម្រូវឱ្យមានសេចក្តីក្លាហាន ភាពអំណត់ និងការប្តេជ្ញាចិត្ត ដែលអាចមាននៅកម្រិតខុសៗគ្នា ហើយប្រភពដែលល្អបំផុត គឺបានពីជំនឿផ្ទាល់ខ្លួន ការឈ្វេងយល់ស៊ីជម្រៅ ឬអារម្មណ៍សាមញ្ញពីអ្វីដែលចាត់ទុកថាជារឿងត្រឹមត្រូវ។

(កថាខណ្ឌ ៤.២ ក្របខណ្ឌសម្រាប់អនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០)

Parilov/Shutterstock.com

ការផ្ដោតការយកចិត្តទុកដាក់លើការដឹកនាំរបស់រដ្ឋជាសមាជិក

ភាពបន្ទាន់នៃបញ្ហាប្រឈមដែលកំពុងកើតមាននាពេលបច្ចុប្បន្ននេះ ទាមទារឱ្យមានការដឹកនាំច្បាស់លាស់ពីរដ្ឋជាសមាជិក ដើម្បីបញ្ជ្រាប ESD ទៅក្នុងគ្រប់សកម្មភាពទាំងអស់ស្ដីពីការអប់រំ និងការអភិវឌ្ឍដោយចីរភាព នៅកម្រិតប្រទេសដែលជាផ្នែកមួយនៃការអនុវត្តគោលដៅ SDG ទី ៤ និងគោលដៅ SDG ដទៃទៀតនៅក្នុងប្រទេសទាំងនេះ។ ដើម្បីសម្រេចគោលដៅនេះក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ផ្ដោតការយកចិត្តទុកដាក់លើគំនិតផ្ដួចផ្ដើមរបស់រដ្ឋជាសមាជិក ឆ្ពោះទៅសម្រេច SDG ។

តើរដ្ឋជាសមាជិកគួរធ្វើអ្វីខ្លះ ?

- ✓ **ឆ្លើយតបចំពោះផ្នែកសកម្មភាពជាអាទិភាពទាំង ៥៖** រដ្ឋជាសមាជិកត្រូវបានអញ្ជើញឱ្យផ្ដោតការយកចិត្តទុកដាក់លើ ការពង្រឹងគំនិតផ្ដួចផ្ដើមនៅតាមប្រទេសជុំវិញផ្នែកសកម្មភាពជាអាទិភាពទាំង ៥ នៃក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ដូចជាជម្រើសគោលនយោបាយ ធ្វើឱ្យផ្លាស់ប្ដូរបរិយាកាសរៀនសូត្រជាវិជ្ជមាន កសាងសមត្ថភាពអ្នកអប់រំ លើកកម្ពស់ភាពអង់អាច និងកៀរគរយុវជន និងចាត់វិធានការក្នុងសហគមន៍ និងពិនិត្យតាមដានវឌ្ឍនភាពនៃសកម្មភាពទាំងនោះ។
- ✓ **ជំរុញឱ្យមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់៖** ដោយសារតែ ESD មានលក្ខណៈចម្រុះរដ្ឋជាសមាជិកត្រូវបានជំរុញឱ្យកៀរគរជំរុញការចូលរួម និងផ្ដល់ការគាំទ្រដល់តួអង្គពាក់ព័ន្ធចម្រុះ ដោយប្រើប្រាស់យុទ្ធសាស្ត្រដោយមានការសម្របសម្រួលបានល្អសម្រាប់អនុវត្តក្របខ័ណ្ឌជាតិស្ដីពី SDG។ ការចូលរួមរបស់តួអង្គពាក់ព័ន្ធចម្រុះបែបនេះ គឺជាការចូលរួមដែលត្រូវមាននៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល ដើម្បីធានាឱ្យបាននូវភាពជាដៃគូ និងការសហការគ្នាក្នុងចំណោមតួអង្គពាក់ព័ន្ធ។
- ✓ **តស៊ូមតិ និងកៀរគរធនធាន៖** ដើម្បីធានាឱ្យការអនុវត្ត ESD នៅកម្រិតប្រទេសមានប្រសិទ្ធភាព ជាការសំខាន់ណាស់ដែលរដ្ឋជាសមាជិក និងត្រូវផ្សព្វផ្សាយដល់សាធារណៈជនទូទៅតាមរយៈកិច្ចខិតខំប្រឹងប្រែងអប់រំផ្សព្វផ្សាយ និងស្វែងរកការគាំទ្រជុំវិញ ESD ឱ្យបានខ្លាំងក្លា។ ក្នុងពេលជាមួយគ្នា គួរមានកិច្ចខិតខំប្រឹងប្រែងបង្កើនការផ្សព្វផ្សាយ តាមរយៈការបង្កើនការកៀរគរធនធានសម្រាប់អនុវត្ត ESD។

ការរួមចំណែករបស់ ESD ចំពោះអាទិភាពជាសកលរបស់យូណេស្កូ

ការផ្ដល់អាទិភាពលើតំបន់អាហ្វ្រិក និង ESD	ESD គាំទ្រដល់ដំណោះស្រាយនវានុវត្តន៍ សម្រាប់ការអភិវឌ្ឍដោយចីរភាពនៅក្នុង បរិបទនៃតម្រូវការ និងឱកាសនៅតំបន់អាហ្វ្រិក និងជាតំបន់មួយក្នុងចំណោមតំបន់ដែលងាយរងគ្រោះជាងគេ ដោយសារការប្រែប្រួលអាកាសធាតុ។ ជាពិសេស ESD មានភាពពាក់ព័ន្ធជាមួយនឹងក្រីក្រធ្ងន់ធ្ងររបស់ប្រជាពលរដ្ឋ ដែលជារឿយៗក៏ជាជនរងគ្រោះ នៃការអភិវឌ្ឍដោយបង្កមហន្តរាយ និងគ្រោះមហន្តរាយធម្មជាតិផងដែរ។
អាទិភាពលើសមភាពយេនឌ័រ និង ESD[៦]	ESD ប្រើប្រាស់អភិក្រមជាប្រព័ន្ធដែលមានលក្ខណៈចម្រុះជំនាញដោយផ្សារភ្ជាប់សមភាពយេនឌ័រជាមួយនឹងបញ្ហាប្រឈមយេនឌ័រជាក់លាក់ ដែលពាក់ព័ន្ធនឹង SDG នីមួយ។ ឧទាហរណ៍ ភាពងាយរងគ្រោះដោយសារមុខសញ្ញាគ្រោះថ្នាក់ ដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ មានលក្ខណចម្រុះ និងច្រើនយ៉ាង។ ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* លើកកម្ពស់សមភាពយេនឌ័រ និងកសាងលក្ខខណ្ឌ ដើម្បីបង្កភាពអង់អាចដល់ស្ត្រី។ នៅពេលអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* គួរពិចារណាប្រើប្រាស់អភិក្រមដែលគិតគូរពីយេនឌ័រ ក្នុងការអនុវត្តសកម្មភាពអាទិភាពទាំង ៥។

រដ្ឋកំពុងអភិវឌ្ឍន៍ដែលស្ថិតនៅតាមដែនកោះតូចៗ

រដ្ឋកំពុងអភិវឌ្ឍន៍ដែលស្ថិតនៅតាមដែនកោះតូចៗ (SIDS) គឺជារដ្ឋដែលស្ថិតនៅជួរមុខនៃការប្រែប្រួលអាកាសធាតុខណៈពេលដែលរដ្ឋទាំងនេះជួបប្រទះនឹងការកើនឡើងនៅកម្ពស់ទឹកជំនន់ ការបាត់បង់ផ្កាថ្មធម្មជាតិ និងប្រព័ន្ធបរិស្ថានសមុទ្រ ក៏ដូចជាការកើនឡើងនៅគ្រោះមហន្តរាយធម្មជាតិ។ បញ្ហាប្រឈមផ្នែកបរិស្ថានធ្វើឱ្យប៉ះពាល់ដល់ចីរភាពសង្គម និងសេដ្ឋកិច្ច ដោយជារឿយៗ ស្ត្រីគឺជាអ្នកដែលរងផលប៉ះពាល់លើសលប់។ សហគមន៍ទទួលរងការគំរាមកំហែង ដូចជាបាត់បង់ទីលំនៅ និងត្រូវបង្ខំចិត្តធ្វើចំណាកស្រុក ហើយឧស្សាហកម្មដែលពឹងអាស្រ័យលើធនធាននៅក្នុងសមុទ្រក៏ទទួលរងផលប៉ះពាល់ដោយសារតែការទាញយកធនធានពីក្នុងសមុទ្រផងដែរ។

ESD ត្រូវត្រៀមរៀបចំមនុស្សគ្រប់យេនឌ័រទាំងអស់ដោយផ្ដល់ឱ្យពួកគេនូវចំណេះសម្បទា បំណិនសម្បទា និងគុណសម្បទា ដើម្បីឆ្លើយតបចំពោះការផ្លាស់ប្ដូរទាំងនេះ ដោយត្រូវប្រើប្រាស់ចំណេះដឹង និងការអនុវត្តដែលមានស្រាប់នៅក្នុងប្រទេស។ ការរៀនសូត្រពេញមួយជីវិតរួមទាំង ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) អាចនឹងជួយធានាយ៉ាងណាឱ្យអ្នកជំនាញ និងសហគមន៍ត្រៀមខ្លួនបានយ៉ាងល្អ ដើម្បីជំនះការផ្លាស់ប្ដូរទាំងនេះ។

[៦] សូមមើលផែនការសកម្មភាពស្ដីពីសមភាពយេនឌ័រអាទិភាពរបស់យូណេស្កូ (២០១៤-២០២១) https://unesdoc.unesco.org/ark:/48223/pf0000370905.locale=en and https://en.unesco.org/genderequality

Felix Lipov/Shutterstock.com

តាមរយៈការអនុវត្តគោលបំណង និងគោលដៅនៃក្របខ័ណ្ឌ ESD សម្រាប់ឆ្នាំ ២០៣០ នៅក្នុង រយៈពេល ១០ ឆ្នាំទៀត យើងមានគោលបំណងបង្កើតនូវពិភពលោកមួយដែលក្នុងនោះ...

រដ្ឋាភិបាល បញ្ជ្រាប ESD ទៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌអប់រំរបស់ពួកគេ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានក្នុងការអប់រំ

អ្នកសិក្សាមកពីគ្រប់ស្រទាប់វណ្ណៈទូទាំងពិភពលោកមានឱកាសទទួលបានចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទាដែលចាំបាច់ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព និងសម្រេចគោលដៅ SDG ទាំង ១៧ និងអាចអនុវត្តការអភិវឌ្ឍដោយចីរភាពដោយប្រើប្រាស់អភិក្រម ESD នៅទូទាំងស្ថាប័ន



មនុស្សដែលរស់នៅក្នុងទីក្រុង និងសហគមន៍ទូទាំងពិភពលោក ទទួលស្គាល់ថា ESD គឺជាឧបករណ៍ដ៏សំខាន់ និងផ្តល់នូវឱកាសរៀនសូត្រពេញមួយជីវិត ដើម្បីសម្រេចបាននូវចីរភាពនៅកម្រិតមូលដ្ឋាន

អ្នកអប់រំ នៅទូទាំងសកលលោក មានឱកាសអភិវឌ្ឍន៍សមត្ថភាព ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម ដើម្បីអនាគតប្រកបដោយចីរភាព។ គ្រឹះស្ថានបណ្តុះបណ្តាលអ្នកអប់រំ បានបញ្ចូល ESD ក្នុងលក្ខណៈជាប្រព័ន្ធ

យុវជន ត្រូវបានពង្រឹងឱ្យក្លាយជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរ ហើយអង្គការយុវជនផ្តល់ការបណ្តុះបណ្តាលក្នុងលក្ខណៈជាប្រព័ន្ធដល់យុវជន និងអ្នកបណ្តុះបណ្តាលយុវជនស្តីពី ESD

natalia bulatova/Shutterstock.com

៣.

សកម្មភាព

អាទិភាព

រដ្ឋជាសមាជិក ព្រមទាំងអ្នកពាក់ព័ន្ធនៅថ្នាក់តំបន់ និង សកល ត្រូវបានអំពាវនាវឱ្យចូលរួមរៀបចំសកម្មភាព ជុំវិញផ្នែកសកម្មភាពជាអាទិភាពទាំង ៥

សកម្មភាពជាអាទិភាពទី ១

ការជំរុញគោលនយោបាយ

អ្នកធ្វើគោលនយោបាយ មានទំនួលខុសត្រូវពិសេស ដើម្បីនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមាន ក្នុងទ្រង់ទ្រាយធំនៅទូទាំងសកលលោក ដែលចាំបាច់ សម្រាប់ការអភិវឌ្ឍដោយចីរភាពចាប់ពីពេលនេះតទៅ។ អ្នកធ្វើគោលនយោបាយ គឺជាអ្នកដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការកសាងបរិយាកាសអំណោយផល សម្រាប់ពង្រីកការបញ្ចូល ESD ទៅក្នុងគ្រឹះស្ថានអប់រំ សហគមន៍ និងទីកន្លែងរៀនសូត្រដទៃទៀត ឲ្យបានជោគជ័យ។ ការគាំទ្រផ្នែកគោលនយោបាយមានសារៈសំខាន់ ដូចគ្នាសម្រាប់វិស័យអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការ ក៏ដូចជាសម្រាប់ការបង្កើតឱ្យមានផ្គុំកម្លាំងគ្នារវាងវិស័យអប់រំទាំងនេះ។ លើសពីនេះការជំរុញគោលនយោបាយដែលគាំទ្រដល់ ESD មិនត្រឹមតែមានភាពពាក់ព័ន្ធជាមួយនឹងវិស័យអប់រំប៉ុណ្ណោះទេ ថែមទាំងជាមួយនឹងគ្រប់វិស័យទាំងអស់ ដែលមានភាពពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍដោយចីរភាពផងដែរ។

តួអង្គសំខាន់ៗ

- ✓ អ្នកធ្វើគោលនយោបាយអប់រំ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល ជាពិសេសក្រសួងអប់រំ
- ✓ អ្នកធ្វើគោលនយោបាយមកពីវិស័យអភិវឌ្ឍន៍ដោយចីរភាព ជាពិសេសក្រសួងបរិស្ថាន និងក្រសួងស្ថាប័នដទៃទៀត
- ✓ អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវ ដែលរួមចំណែកដល់ការពិភាក្សា អំពីការអភិវឌ្ឍដោយចីរភាព និងការអប់រំ
- ✓ យូណេស្កូ និងដៃគូដទៃទៀត

សកម្មភាពដែលស្នើឡើង

- ✓ ក្រសួងអប់រំគួរ**ពិនិត្យឡើងវិញលើគោលបំណងនៃប្រព័ន្ធអប់រំរបស់ខ្លួន ដើម្បីឲ្យគោលបំណងទាំងនេះស្របតាមមហិច្ឆតានៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព** និងកំណត់វត្ថុបំណងនៃការសិក្សា ឱ្យស្របទាំងស្រុងទៅនឹងគោលដៅទាំងនេះ។ អ្នកធ្វើគោលនយោបាយអប់រំនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលលោក គួរ**បញ្ចូល ESD ទៅក្នុងគោលនយោបាយអប់រំ** រាប់បញ្ចូលទាំងគោលនយោបាយដែលពាក់ព័ន្ធនឹងបរិយាកាសសិក្សា កម្មវិធីសិក្សា ការអប់រំគ្រូ ក៏ដូចជាវង្វាយតម្លៃសិស្ស ហើយជានិច្ចកាលត្រូវចងចាំជានិច្ចពីកត្តាយេនឌ័រ។
- ✓ អ្នកធ្វើគោលនយោបាយអប់រំគួរ **បញ្ចូល ESD ទៅក្នុងលក្ខណៈវិនិច្ឆ័យសម្រាប់ធានាគុណភាពនៃការអប់រំ** ដើម្បីធានាយ៉ាងណាឱ្យមានការពិនិត្យតាមដាន និងវាយតម្លៃគ្រឹះស្ថានអប់រំ ដើម្បីវាស់វែងវឌ្ឍនភាពជុំវិញការអភិវឌ្ឍសមត្ថភាព របស់អ្នកសិក្សា ដើម្បីក្លាយខ្លួនជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្ដូរ។
- ✓ ដោយសហការជាមួយនឹងក្រសួងស្ថាប័នដទៃទៀត អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវអ្នកធ្វើគោលនយោបាយអប់រំគួររៀបចំ**គោលនយោបាយ ដើម្បីពង្រឹងទំនាក់ទំនងបែបផ្គួបកម្លាំងគ្នា** រវាងការអប់រំ និងការរៀនសូត្រក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងក្រៅផ្លូវការ។ ឧទាហរណ៍ អាចមានដូចជាការដាក់ចេញនូវវិធានការគោលនយោបាយ ដើម្បីលើកទឹកចិត្តឱ្យមានការរៀនសូត្របែបគម្រោង ដែលផ្ដោតលើបញ្ហាចីរភាព នៅក្នុងសហគមន៍ជាដើម។
- ✓ អ្នកធ្វើគោលនយោបាយមកពីវិស័យអភិវឌ្ឍន៍ដោយចីរភាព គួរ**បញ្ចូល ESD ទៅក្នុងគ្រប់គោលនយោបាយទាំងអស់ ដែលផ្ដោតការយកចិត្តទុកដាក់លើការសម្រេច SDG** ដោយសហការជាមួយនឹងអ្នកធ្វើគោលនយោបាយអប់រំ អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវ។ ឧទាហរណ៍ ESD គួរត្រូវបានបញ្ចូលឱ្យបានដាក់ច្បាស់ ទៅក្នុងគ្រប់គោលនយោបាយទាំងអស់ដែលឆ្លើយតបចំពោះបញ្ហាប្រែប្រួលអាកាសធាតុ (SDG ១៣)។ កិច្ចខិតខំប្រឹងប្រែងទាំងនេះទាមទារឱ្យមានការសហការយ៉ាងជិតស្និទ រវាងអ្នកធ្វើគោលនយោបាយនានា មកពីវិស័យអភិវឌ្ឍន៍ដោយចីរភាព និងវិស័យអប់រំ ជាពិសេសនៅក្នុងចំណោមក្រសួងស្ថាប័នដែលពាក់ព័ន្ធ ក៏ដូចជាទាមទារឱ្យមានការពង្រឹងអភិបាលកិច្ច ដែលមានការសហការគ្នា រវាងតួអង្គពាក់ព័ន្ធចម្រុះ។

ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ យូណេស្កូ និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាដៃគូ ព្រមទាំងស្ថាប័នដទៃទៀត បានដាក់ឱ្យអនុវត្តនូវកម្មវិធីមួយ ដើម្បី**គាំទ្រដល់គំនិតផ្តួចផ្តើមក្នុងប្រទេស** ដែលផ្ដោតលើ *ESD សម្រាប់ឆ្នាំ ២០៣០* ដើម្បីបញ្ចូល ESD ទៅក្នុងគោលនយោបាយអប់រំ និងអភិវឌ្ឍន៍ដោយចីរភាព **លើកកម្ពស់ភាពជាដៃគូរវាងតួអង្គពាក់ព័ន្ធចម្រុះនៅកម្រិតអន្តរវិស័យ និងអន្តររដ្ឋាភិបាល** តាមរយៈការបង្កើតនូវវេទិកាសកលមួយ សម្រាប់អ្នកធ្វើគោលនយោបាយ និងជំរុញឱ្យមានការផ្ដោតការយកចិត្តទុកដាក់លើ ESD នៅកម្រិតសកល រួមជាមួយនឹងទីភ្នាក់ងារអង្គការសហប្រជាជាតិជាដៃគូ តួអង្គនៅថ្នាក់អន្តរជាតិ និងថ្នាក់ជាតិ រួមទាំងគណៈកម្មាធិការជាតិសម្រាប់យូណេស្កូផងដែរ។

TOOL BOX

on.unesco.org/esdtoolbox

Lightspring/Shutterstock.com

សកម្មភាពជាអាទិភាពទី ២
ការផ្លាស់ប្តូរជាវិជ្ជមាននៃបរិយាកាសរៀនសូត្រ

ដើម្បីលើកទឹកចិត្តឱ្យអ្នកសិក្សាក្លាយជាភ្នាក់ងារ ដែលនាំមកនូវការផ្លាស់ប្តូរ ហើយដែលជាអ្នកមានចំណេះដឹងមធ្យោបាយ ឆន្ទៈ និងសេចក្តីក្លាហានក្នុងការធ្វើសកម្មភាពនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ការអភិវឌ្ឍដោយចីរភាព គ្រឹះស្ថានសិក្សាក៏ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរខ្លួនឯងផងដែរ។ គ្រឹះស្ថានសិក្សាទាំងមូលចាំបាច់ ត្រូវតម្រឹមខ្លួន ឱ្យស្របតាមគោលការណ៍អភិវឌ្ឍន៍ដោយចីរភាព ដើម្បីឱ្យមានការពង្រឹងបន្ថែមលើខ្លឹមសារ ដែលប្រើប្រាស់នៅក្នុងការសិក្សា ក៏ដូចជាវិធីសាស្ត្រគរុកោសល្យ រួមជាមួយនឹងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់គ្រប់គ្រងគ្រឹះស្ថាន និងវិធីសាស្ត្រធ្វើការសម្រេចចិត្តនៅក្នុងគ្រឹះស្ថាន។ ការអនុវត្ត ESD ដោយប្រើប្រាស់អភិក្រមទូទាំងស្ថាប័នបែបនេះ អំពាវនាវឱ្យមានការបង្កើតនូវបរិយាកាសសិក្សាដែលអ្នកសិក្សា អាចរៀនសូត្រពីបទពិសោធន៍ផ្ទាល់ក្នុងជីវិតរបស់ពួកគេ និងយកអ្វីដែលពួកគេរៀនទៅប្រើប្រាស់នៅក្នុងជីវិតរស់នៅរបស់ពួកគេ។

តួអង្គសំខាន់ៗ

- ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា ដូចជានាយកសាលា សាកលវិទ្យាធិការ ប្រធានមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងបុគ្គលិកនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនឯកជន
- អ្នកអប់រំ អ្នកសិក្សា ក៏ដូចជាបុគ្គលិករដ្ឋបាល នៅតាមគ្រឹះស្ថានសិក្សានានា
- អ្នកដឹកនាំសហគមន៍មូលដ្ឋាន គ្រួសារនៅតាមសហគមន៍មូលដ្ឋាន ក៏ដូចជាតួអង្គនៅក្នុងវិស័យក្រៅរដ្ឋាភិបាល និងវិស័យឯកជនដែលធ្វើការងារផ្តោតលើចីរភាព
- អ្នកធ្វើគោលនយោបាយអប់រំ
- យូណេស្កូ និងដៃគូ

សកម្មភាពដែលស្នើឡើង

✓ ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា ដូចជានាយកសាលា សាកលវិទ្យាធិការ ប្រធានមជ្ឈមណ្ឌលអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងបុគ្គលិកនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនឯកជន។ គួរ**រៀបចំផែនការដាក់លាក់ដែលមានពេលវេលាកំណត់ច្បាស់លាស់ ដោយមានការបញ្ជាក់ពីវិធីសាស្ត្រអនុវត្ត ESD ដោយប្រើប្រាស់អភិក្រមទូទាំងស្ថាប័ន** រួមគ្នាជាមួយនឹងសមាជិករបស់ខ្លួន ក៏ដូចជាសហគមន៍មូលដ្ឋាន។

✓ ឧទាហរណ៍ ថ្នាក់ដឹកនាំគ្រឹះស្ថានសិក្សា គួរ**ធានាយ៉ាងណាឱ្យអភិបាលកិច្ច និងវប្បធម៌របស់គ្រឹះស្ថាន ស្របតាមគោលការណ៍អភិវឌ្ឍន៍ដោយចីរភាព។** វិធានការមួយដែលអាចយកមកអនុវត្តបាន គឺត្រូវធានាដំណើរការធ្វើសេចក្តីសម្រេចចិត្តពីក្រោមឡើងលើ ដែលក្នុងនោះសមាជិកទាំងអស់របស់គ្រឹះស្ថានក៏ដូចជាតួអង្គពាក់ព័ន្ធដទៃទៀត អាចបញ្ចេញសម្លេងអំពីបញ្ហាចីរភាពដែលចាំបាច់ត្រូវធ្វើការដោះស្រាយនៅក្នុងគ្រឹះស្ថាន។ គួរមានកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើយ៉ាងណាឱ្យវប្បធម៌នៅក្នុងស្ថាប័ន ផ្តោតការយកចិត្តទុកដាក់លើការសហការ សាមគ្គីភាព និងបរិយាបន្ន ដើម្បីឱ្យមានការចូលរួមអំពីមនុស្សគ្រប់យេនឌ័រ និងសាវតារទាំងអស់។

✓ បុគ្គលិករដ្ឋបាលនៃគ្រឹះស្ថានសិក្សា គួរ**ធានាយ៉ាងណាឱ្យសម្ភារៈរូបវន្ត និងប្រតិបត្តិការណ៍របស់ខ្លួន បានបញ្ចូលគោលការណ៍ចីរភាព។** ឧទាហរណ៍ នេះអាចមានដូចជាអាគារដែលប្រើថាមពលតិច ជម្រើសមធ្យោបាយដឹកជញ្ជូនដែលមានចីរភាព និងសុវត្ថិភាព សម្រាប់បុគ្គលិក និងអ្នកសិក្សា ការធ្វើលទ្ធកម្មផលិតផលដែលមានចីរភាព និងផលិតនៅក្នុងស្រុក និងការធ្វើសវនកម្ម ដែលផ្តោតលើចីរភាព ជាដើម។

✓ អ្នកអប់រំ អ្នកសិក្សា និងបុគ្គលិករដ្ឋបាលគួរសហការជាមួយនឹងអ្នកដឹកនាំនៅតាមសហគមន៍ គ្រួសារ ក៏ដូចជាតួអង្គក្រៅរដ្ឋាភិបាល និងតួអង្គនៅក្នុងវិស័យឯកជន ដែលធ្វើការងារផ្តោតលើចីរភាព ដើម្បី**ជំរុញឱ្យសហគមន៍មូលដ្ឋាន ចូលរួមផ្តល់ជាទីតាំងដ៏មានតម្លៃ សម្រាប់ការសិក្សា និងការធ្វើសកម្មភាពលើកកម្ពស់ចីរភាព ក្នុងទម្រង់ជាការអនុវត្តគម្រោង ដែលតម្រូវឲ្យមានការប្រើប្រាស់ជំនាញចម្រុះ។**

✓ អ្នកធ្វើគោលនយោបាយអប់រំ គួរ**កសាងបរិយាកាសអំណោយផល ដើម្បីឲ្យអ្នកអប់រំអាចធ្វើសមាហរណកម្មអភិក្រមទូទាំងស្ថាប័ន ដែលប្រើប្រាស់ សម្រាប់អនុវត្ត ESD ។** ឧទាហរណ៍អាចមានដូចជាការយកចិត្តទុកដាក់លើESDក្នុងចំណោមអាទិភាពដែលមានលក្ខណៈប្រជែងគ្នា ដែលផ្តល់លទ្ធភាពឱ្យមានភាពបត់បែនបង្កភាពងាយស្រួលដល់ការកសាងភាពជាដៃគូ និងឆ្លុះបញ្ចាំងពីអភិក្រមទូទាំងស្ថាប័នដែលប្រើប្រាស់សម្រាប់អនុវត្ត ESD នៅក្នុងការវាយតម្លៃលើសមិទ្ធកម្មរបស់គ្រឹះស្ថានសិក្សា។

ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ យូណេស្កូ និងទីភ្នាក់ងារអង្គការសហប្រជាជាតិជាដៃគូ ព្រមទាំងស្ថាប័នដទៃទៀតកំពុងខិតខំប្រឹងប្រែងរួមគ្នា ដើម្បី**រៀបចំ និងផ្សព្វផ្សាយឯកសារផ្តល់ការណែនាំជាជំហានៗអំពីរបៀបអនុវត្ត ESD** ដោយប្រើប្រាស់អភិក្រមទូទាំងស្ថាប័ន និងបង្កើតវេទិកាសកលមួយ ដើម្បីឱ្យតួអង្គពាក់ព័ន្ធនានាអាចធ្វើការផ្លាស់ប្តូរព័ត៌មានបទពិសោធន៍ និងកសាងភាពជាដៃគូជាពិសេសតាមរយៈបណ្តាញសកល ដូចជាបណ្តាញសាលាដែលមានទំនាក់ទំនងជាមួយនឹងយូណេស្កូ (ASPnet) មជ្ឈមណ្ឌល UNESCO-UNEVOC និងប្រធានយូណេស្កូ ជាដើម។

TOOL BOX

on.unesco.org/esdtoolbox

Getty/cristianoalessandro

សកម្មភាពអាទិភាពទី ៣
កសាងសមត្ថភាពអ្នកអប់រំ

អ្នកអប់រំនៅតែជាតួអង្គសំខាន់ ដែលជួយសម្រួលអន្តរកាលរបស់អ្នកសិក្សា ឆ្ពោះទៅរកបែបផែននៃជីវិតប្រកបដោយចីរភាព ក្នុងយុគសម័យដែលគេអាចរកបានព័ត៌មាននៅគ្រប់ទិសទី និងខណៈពេលដែលតួនាទីរបស់ពួកគេ កំពុងឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងធំធេង។ អ្នកអប់រំនៅគ្រប់បរិបទអប់រំទាំងអស់ អាចជួយឱ្យអ្នកសិក្សាយល់ពីជម្រើសដ៏សែនស្មុគស្មាញក្នុងការអភិវឌ្ឍដោយចីរភាពនិងលើកទឹកចិត្តឱ្យពួកគេធ្វើការផ្លាស់ប្តូរខ្លួនឯង និងផ្លាស់ប្តូរសង្គម របស់ពួកគេជាវិជ្ជមាន។ ដើម្បីផ្តល់ការតម្រង់ទិស និងលើកកម្ពស់ភាពអង់អាចរបស់អ្នកសិក្សា អ្នកអប់រំខ្លួនឯងក៏ត្រូវទទួលបានភាពអង់អាច និងទទួលការបំពាក់បំប៉ននូវចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទា ដែលចាំបាច់សម្រាប់ការធ្វើអន្តរកាលនេះផងដែរ។ នេះរួមមានការឈ្វេងយល់ពីទិដ្ឋភាពសំខាន់ៗនៃ SDG នីមួយៗក្នុងចំណោម SDG ទាំង ១៧ ព្រមទាំងទំនាក់ទំនងទៅវិញទៅមករវាង SDG ទាំងនេះ ក៏ដូចជាឈ្វេងយល់ថាតើសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន អាចកើតឡើងដោយរបៀបណា និងថាតើវិធីសាស្ត្រគរុកោសល្យ ដែលឆ្លើយតបចំពោះយេនឌ័រប្រភេទណាដែលអាចនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះបានល្អបំផុត។

តួអង្គសំខាន់ៗ

- ថ្នាក់ដឹកនាំ និងបុគ្គលិកនៃគ្រឹះស្ថានអប់រំគ្រូនៅគ្រប់កម្រិត
- ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រឹះស្ថានបណ្តុះបណ្តាលសម្រាប់អ្នកអប់រំក្រៅប្រព័ន្ធ
- ថ្នាក់ដឹកនាំ និងបុគ្គលិកក្រុមហ៊ុនឯកជន
- អ្នកធ្វើគោលនយោបាយ
- អ្នកអប់រំ
- យូណេស្កូ និងដៃគូរបស់ខ្លួន

សកម្មភាពដែលស្នើឡើង

- ✓ ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រឹះស្ថានអប់រំគ្រូគួរ**បញ្ចូលការអភិវឌ្ឍសមត្ថភាពជុំវិញ ESD ដែលមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយទៅក្នុងវគ្គបណ្តុះបណ្តាល និងវិក្រឹតការគ្រូ និងវង្វាយតម្លៃគ្រូ**នៅកម្រិតមតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ព្រមទាំងការអប់រំសម្រាប់មនុស្សពេញវ័យ។នេះរួមមានការបញ្ចូលខ្លឹមសារសិក្សា ពាក់ព័ន្ធនឹង SDG នីមួយៗ ក៏ដូចជាវិធីសាស្ត្រគរុកោសល្យ ដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន សម្រាប់ជួយដល់ការអនុវត្តសកម្មភាពនោះ។
- ✓ ថ្នាក់ដឹកនាំនិងបុគ្គលិកគ្រឹស្ថាន TVET និងគ្រឹះស្ថានបណ្តុះបណ្តាលរបស់ក្រុមហ៊ុនឯកជន គួរធ្វើការរួមគ្នា ដើម្បី**អភិវឌ្ឍសមត្ថភាពអ្នកអប់រំ** នៅក្នុងមជ្ឈមណ្ឌល TVET និងក្រុមហ៊ុនឯកជន ដោយផ្តោតលើចំណេះសម្បទា បំណិនសម្បទា គុណសម្បទា និងចរិយាសម្បទា ដើម្បីសម្រេចការអភិវឌ្ឍដោយចីរភាព ដោយមានការផ្តោតការយកចិត្តលើសេដ្ឋកិច្ចបៃតង ព្រមទាំងផលិតកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព។ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់គ្រឹះស្ថានបណ្តុះបណ្តាល ដែលផ្តោតលើអ្នកអប់រំក្រៅប្រព័ន្ធ ក៏គួរបញ្ចូល ESD ទៅក្នុងគ្រប់សកម្មភាពកសាងសមត្ថភាពទាំងអស់របស់គ្រូផងដែរ។
- ✓ គ្រូឧទ្ទេសគួរ**រៀបចំឱកាសរៀនសូត្រពីគ្នាទៅវិញទៅមក ក្នុងលក្ខណៈជាប្រព័ន្ធ** ដែលក្នុងនោះអ្នកអប់រំឈានមុខអាចចែករំលែកជោគជ័យ និងបញ្ហាប្រឈមរបស់ខ្លួន និងបង្ហាញឱ្យសហការីរបស់ខ្លួនដឹងថា បើទោះជា ESD មានគោលបំណងប្រកបដោយមហិច្ឆតាក៏ដោយ គេនៅតែអាចបញ្ចូលវាជាជំហានៗទៅក្នុងការបង្រៀនប្រចាំថ្ងៃបាន។
- ✓ អ្នកធ្វើគោលនយោបាយគួរ**ផ្តល់លទ្ធភាព លើកទឹកចិត្ត និងសាទរ**អ្នកអប់រំដែលបានបញ្ចូល ESD ទៅក្នុងការបង្រៀន របស់ពួកគេប្រកបដោយជោគជ័យ ដើម្បីឱ្យការអប់រំកាន់តែឆ្លើយតបចំពោះតម្រូវការនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ។ឧទាហរណ៍នេះអាចធ្វើឡើយតាមរយៈការផ្តល់ការលើកទឹកចិត្ត និងទទួលស្គាល់ថា គំនិតផ្តួចផ្តើម ESD ថាជាផ្នែកមួយនៃសកម្មភាព សម្រាប់ពិនិត្យលើគុណភាព នៃការអប់រំនៅតាមគ្រឹះស្ថាននានា។
- ✓ អ្នកអប់រំគួរ**បំពេញតួនាទី ជាអ្នកសម្របសម្រួលដែលជួយផ្តល់ការណែនាំដល់អ្នកសិក្សា**តាមរយៈ ការនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ក៏ដូចជាការកសាងជំនាញឯកទេស និងការផ្សព្វផ្សាយចំណេះដឹងដែលផ្តោតលើការកសាងអនាគតប្រកបដោយចីរភាព។ អ្នកអប់រំអាចប្រើប្រាស់គោលវិធីគរុកោសល្យ ដែលមានលក្ខណៈនវានុវត្តន៍ ដើម្បីផ្តល់ភាពអង់អាចឱ្យអ្នកសិក្សាក្លាយជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរ។

ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ យូណេស្កូ និងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលជាដៃគូរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត បានគាំទ្រដល់ការកសាងសមត្ថភាពរបស់អ្នកអប់រំ ក៏ដូចជាផ្តល់ការណែនាំកម្រិតគោលនយោបាយ និងធនធាននានា ដើម្បីជួយសម្រួលក្នុងការបញ្ចូល ESD ទៅក្នុងកម្មវិធីសិក្សា និងបង្កើតជាវេទិកាសកល ដើម្បីភ្ជាប់ទំនាក់ទំនងរវាងអ្នកអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលនានា ដើម្បីឱ្យពួកគេអាចចែករំលែកការអនុវត្តល្អ និងសហការគ្នានៅកម្រិតសកល។

TOOL BOX
on.unesco.org/esdtoolbox

©UNESCO/Keathunthea

សកម្មភាពជាអាទិភាពទី ៤
ផ្តល់ភាពអង់អាច និងកៀរគរចលនាយុវជន

គឺយុវជនសម័យនេះនិងមនុស្សជំនាន់ក្រោយដែលត្រូវប្រឈមនឹងផលវិបាកដែលកើតឡើងដោយសារការអភិវឌ្ឍ ដែលពុំមានចីរភាព។ អ្នកដែលមានភាពពាក់ព័ន្ធខ្លាំងបំផុត គឺយុវជនទាំងនេះនិងមនុស្សជំនាន់ក្រោយនេះឯង។ដូច្នេះយុវជនត្រូវតែខិតខំបញ្ចេញសម្លេង និងធ្វើសកម្មភាពឱ្យកាន់តែសកម្ម ត្រូវធ្វើការទាមទារឱ្យមានការផ្លាស់ប្តូរបន្ទាន់ និងដាច់ណាត់ និងក៏ដូចជាទាមទារឱ្យមេដឹកនាំពិភពលោកមានគណនេយ្យភាពចំពោះសកម្មភាពរបស់ពួកគេ ជាពិសេសទាមទារឱ្យពួកគេឆ្លើយតបចំពោះវិបត្តិអាកាសធាតុ។ ពួកគេត្រូវតែ និងត្រូវបន្តដាក់ចេញនូវចក្ខុវិស័យ ក៏ដូចជាស្វែងរកនូវដំណោះស្រាយដែលមានលក្ខណៈច្នៃប្រឌិតបំផុត ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព លើសពីនេះ យុវជនក៏ជាក្រុមអ្នកប្រើប្រាស់ដ៏សំខាន់ផងដែរ ហើយការប្រែប្រួលនៃបែបផែននៃការប្រើប្រាស់របស់ពួកគេ និងមានឥទ្ធិពលយ៉ាងធំធេងលើគន្លងនៃការអភិវឌ្ឍដោយចីរភាព នៅក្នុងប្រទេសរបស់ពួកគេ។ ដូច្នេះការបង្កើតភាពអង់អាច និងការកៀរគរចលនាយុវជន គ្រប់យេនឌ័រទាំងអស់ គឺជាផ្នែកមួយដ៏សំខាន់នៃការអនុវត្ត ESD។

តួអង្គពាក់ព័ន្ធសំខាន់ៗ

- យុវជននៅទូទាំងសកលលោក
- ក្រុមអង្គការ និងបណ្តាញដែលដឹកនាំដោយយុវជន និងផ្តោតលើយុវជន
- អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសមាជិកនៃស្ថាប័នសាធារណៈ និងឯកជន
- តួអង្គនៅក្នុងសហគមន៍ មាតាបិតា និងគ្រួសារ
- យូណេស្កូ និងដៃគូរបស់ខ្លួន

សកម្មភាពដែលស្នើឡើង

- ✓ យុវជននៅទូទាំងសកលលោក ដែលជាអ្នកទទួលផលផង និងជាអ្នកជំរុញសកម្មភាពអាទិភាពនេះផង គឺអ្នកដែលមានគំនិតនវានុវត្តន៍ និងសហគ្រិនដ៏សកម្ម និងប្រកបដោយភាពច្នៃប្រឌិតដែលអាចដឹកនាំការផ្លាស់ប្តូរ ដើម្បីអនាគតប្រកបដោយចីរភាព។ យុវជនអាច**ប្រើប្រាស់សហគមន៍អនឡាញ និងច្រកទំនាក់ទំនងដទៃទៀត ដើម្បីចែករំលែកសារអំពីភាពបន្ទាន់ ក្នុងការឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធនឹងចីរភាព ជំរុញឱ្យមានការបញ្ចូល ESD ទៅក្នុងការអប់រំរបស់ពួកគេបង្កើនភាពអង់អាចរបស់ខ្លួន និងចាត់វិធានការ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន**នៅក្នុងសង្គម។
- ✓ ក្រុមអង្គការ និងបណ្តាញដែលដឹកនាំដោយយុវជន និងដែលផ្តោតការយកចិត្តទុកដាក់លើយុវជន គួរ**កសាងឱកាស ដើម្បីឱ្យយុវជនអាចផ្តល់ភាពអង់អាចឱ្យគ្នាទៅវិញទៅមក** តាមរយៈការចែករំលែកចំណេះដឹងជំនាញ គុណតម្លៃ និងឥរិយាបថដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន។ នេះរួមមានជម្រើសតស៊ូមតិ និងនិយាយសាសាធារណៈ ដើម្បីបុព្វហេតុរបស់យុវជន និងការជំរុញឱ្យមានការចូលរួមពីអ្នកធ្វើគោលនយោបាយ និងក្រុមដទៃទៀត ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមបន្ទាន់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។
- ✓ ក្រុមអង្គការ និងបណ្តាញដែលដឹកនាំដោយយុវជន និងដែលផ្តោតការយកចិត្តទុកដាក់លើយុវជនគួរ**ផ្សព្វផ្សាយព័ត៌មានដើម្បីកសាងទំនាក់ទំនង កៀរគរចលនា និងជំរុញឱ្យមានការចូលរួមពីយុវជនសំដៅការបង្កើនការចូលរួមរបស់ពួកគេ នៅក្នុងសកម្មភាពអភិវឌ្ឍន៍ដោយចីរភាព។** នេះរួមមានការបង្កើនការយល់ដឹងអំពី SDG តាមរយៈការតស៊ូមតិ និងការអប់រំផ្សព្វផ្សាយ ដូចជា តាមរយៈយុទ្ធនាការដឹកនាំដោយយុវជន ដើម្បីបង្ហាញពីទំនាក់ទំនង រវាងគោលដៅទាំងនេះជាមួយនឹងអ្វីដែលមានសារៈសំខាន់បំផុតចំពោះយុវជន នៅក្នុងសហគមន៍របស់ពួកគេ។
- ✓ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសមាជិកនៃស្ថាប័នសាធារណៈ និងឯកជនត្រូវទទួលស្គាល់ថា**យុវជនគឺជាអ្នករួមចំណែក និងតួអង្គដ៏សំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។** ជាពិសេសត្រូវមានការបញ្ចូលយុវជនឱ្យបានពេញលេញ ក្នុងការរៀបចំការអនុវត្ត និងការពិនិត្យតាមដានគោលនយោបាយនិងកម្មវិធីអប់រំនិងការអភិវឌ្ឍដោយចីរភាព។ការធានាយ៉ាងណាឱ្យតំណាងយុវជន អាចចូលរួមជាសមាជិកនៅក្នុងគណៈកម្មាធិការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នគ្រប់កម្រិតទាំងអស់ គឺជាវិធីមួយក្នុងចំណោមវិធីនានា ដើម្បីសម្រេចគោលដៅនេះ។

ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ យូណេស្កូ និងទីភ្នាក់ងារសហប្រជាជាតិជាដៃគូ ក៏ដូចជាតួអង្គពាក់ព័ន្ធដទៃទៀតផ្តល់ការគាំទ្រ**ដល់ឱកាសបណ្តុះបណ្តាល និងការរៀបចំឧបករណ៍បណ្តុះបណ្តាលដែលពាក់ព័ន្ធ** ដើម្បីឱ្យយុវជនអាចបង្កើនចំណេះដឹង ពង្រឹងគុណតម្លៃ និងឥរិយាបថរបស់ពួកគេ ដើម្បីធ្វើយ៉ាងណាឱ្យសម្លេងរបស់ពួកគេត្រូវបានស្តាប់ឮ និង**បានបង្កើតនូវវេទិកាកម្រិតសកលមួយ ដើម្បីឱ្យយុវជនអាចជំរុញការសហការជាមួយនឹងតួអង្គពាក់ព័ន្ធនានា ក៏ដូចជាចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់អន្តរជំនាន់ ស្របតាមយុទ្ធសាស្ត្រយុវជន** ដែលកំពុងអនុវត្តនៅក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិទាំងមូល។[៧]

TOOL
BOX
on.unesco.org/esdtoolbox

[៧] តាមរយៈយុទ្ធសាស្ត្រប្រតិបត្តិការស្តីពីយុវជន (២០១៤-២០២១) (https://unesdoc.unesco.org/ark:/48223/pf0000227150.locale=en), យូណេស្កូធ្វើការងារជាមួយនឹងយុវជននិងមានការប្តេជ្ញាចិត្តក្នុងការអមដំណើរពួកគេ ដើម្បីជំរុញនវានុវត្តន៍ និងការផ្លាស់ប្តូរនៅក្នុងសង្គម ចូលរួមឱ្យបានពេញលេញក្នុងការអភិវឌ្ឍសង្គមរបស់ពួកគេ លុបបំបាត់ភាពក្រីក្រ និងវិសាលភាព និងលើកកម្ពស់វប្បធម៌សន្តិភាព។ ESD គឺជាផ្នែកមួយដ៏សំខាន់នៃកញ្ចប់សកម្មភាពរបស់យូណេស្កូនេះ ដែលត្រូវធ្វើឡើយដោយយុវជន ជាមួយយុវជន និងដើម្បីយុវជន (https://en.unesco.org/youth)។

Alexandros Michailidis/Shutterstock.com

សកម្មភាពជាអាទិភាពទី ៥

ពន្លឿនសកម្មភាពនៅមូលដ្ឋាន

ការផ្លាស់ប្តូរជាវិជ្ជមាន និងសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ប្រកបដោយអត្ថន័យ ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍដោយចីរភាព ទំនងជាកើតឡើងនៅក្នុងសហគមន៍។ ពោលគឺ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេនៅក្នុងសហគមន៍នេះឯង ដែលអ្នកសិក្សា និងមនុស្សទូទៅធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងអភិវឌ្ឍន៍ចីរភាព និងអនុវត្តតាមការសម្រេចចិត្តទាំងនោះ។ គឺនៅក្នុងសហគមន៍នេះឯងដែលមនុស្សទូទៅស្វែងរកដៃគូ ដើម្បីរួមគ្នាសម្រេចឱ្យបាននូវការអភិវឌ្ឍដោយចីរភាព។ ហេតុនេះ គួរមានការជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការសកម្ម រវាងគ្រឹះស្ថានសិក្សានានា ដើម្បីធានាយ៉ាងណាឱ្យគេយកចំណេះដឹង និងការអនុវត្តចុងក្រោយគេពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពទៅប្រើប្រាស់ ដើម្បីលើកកម្ពស់របៀបវារៈនៅក្នុងមូលដ្ឋាន។

តួអង្គពាក់ព័ន្ធសំខាន់ៗ

- អាជ្ញាធរសាធារណៈនៅក្នុងមូលដ្ឋានដូចជារដ្ឋបាលក្រុងក្រុមប្រឹក្សាក្រុង និងការិយាល័យអប់រំក៏ដូចជាអ្នកធ្វើគោលនយោបាយ នៅថ្នាក់ជាតិ និងថ្នាក់តំបន់
- អង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសហគមន៍
- តួអង្គពាក់ព័ន្ធនៃការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅក្នុងសហគមន៍ រួមនឹងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងគ្រឹះស្ថានឧត្តមសិក្សា
- ប្រជាពលរដ្ឋទាំងអស់នៅក្នុងសហគមន៍មូលដ្ឋាន
- យុវជន និងដៃគូរបស់ខ្លួន

សកម្មភាពដែលត្រូវបានស្នើឡើង

- អាជ្ញាធរសាធារណៈក្នុងមូលដ្ឋាន ដូចជា រដ្ឋបាលក្រុង ក្រុមប្រឹក្សាក្រុង និងការិយាល័យអប់រំ ដោយសម្របសម្រួលជាមួយនឹងតួអង្គពាក់ព័ន្ធទាំងអស់ នៅក្នុងសហគមន៍គួរ**រៀបចំផែនការសកម្មភាព ដើម្បីឱ្យសហគមន៍ទាំងមូល អាចក្លាយជាកន្លែងដកស្រង់បទពិសោធន៍ សម្រាប់ការសិក្សាជុំវិញការអភិវឌ្ឍដោយចីរភាព និងក្លាយជាសមាសភាគមួយដ៏សំខាន់នៃគំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* ដែលអនុវត្តនៅក្នុងប្រទេស** ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបក្លាយជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរ។
- អាជ្ញាធរសាធារណៈនៅថ្នាក់មូលដ្ឋាន ដោយសហការជាមួយនឹងគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិល ក្រុមហ៊ុនឯកជន និងបណ្តាញផ្សព្វផ្សាយក្នុងមូលដ្ឋានផង គួរ**ផ្តល់ការអភិវឌ្ឍសមត្ថភាពដល់គ្រប់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកដឹកនាំផ្នែកគំនិតទាំងអស់ ក៏ដូចជាដល់សាធារណៈជនទូទៅ** ដើម្បីផ្តល់ការស្រាយបំភ្លឺ អំពីគោលដៅអភិវឌ្ឍន៍ដោយចីរភាព ដើម្បីឱ្យពួកគេយល់ពីភាពពាក់ព័ន្ធនៃគោលដៅទាំងនេះ ក្នុងសហគមន៍របស់ពួកគេ។ នេះរួមមានការរៀនសូត្រក្រៅផ្លូវការ ក្នុងជីវិតប្រចាំថ្ងៃដូចជាការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធានាឱ្យមានការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈប្រកបដោយសុវត្ថិភាព និងការផ្សព្វផ្សាយព័ត៌មានជាប្រចាំអំពីការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈសារព័ត៌មានក្នុងស្រុកជាដើម។ល។
- អ្នកផ្តល់សេវាអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ក្នុងសហគមន៍គួរ**ធ្វើការសម្របសម្រួលកម្មវិធីទាំងនេះ ដើម្បីឱ្យពួកគេអាចរួមគ្នាឆ្លើយតបចំពោះគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់ ក៏ដូចជាចំពោះបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព នៅក្នុងមូលដ្ឋានរបស់ពួកគេ។** មជ្ឈមណ្ឌលសិក្សាសហគមន៍អាចបំពេញតួនាទី ជាមជ្ឈមណ្ឌលសម្រាប់ការសិក្សាពេញមួយជីវិត ផ្តោតលើប្រធានបទ ESD នៅក្នុងសហគមន៍របស់ពួកគេ។
- អ្នកធ្វើគោលនយោបាយនៅថ្នាក់ជាតិគួរ**លើកទឹកចិត្ត និងផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដែលធ្វើឡើយ ដោយសហគមន៍មូលដ្ឋាន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងទាំងនេះ** ជាផ្នែកមួយនៃការអនុវត្តសកម្មភាពនៃក្នុងប្រទេសផ្តោតលើ *ESD សម្រាប់ឆ្នាំ ២០៣០* និងជាផ្នែកមួយនៃការរួមចំណែករបស់ប្រទេសក្នុងការសម្រេច SDG។ នេះរួមមានការផ្តល់ការលើកទឹកចិត្តឱ្យអាជ្ញាធរមូលដ្ឋានបញ្ចូល ESD ទៅក្នុងកម្មវិធីសិក្សា ក៏ដូចជាបញ្ចូល ESD ទៅក្នុងប្រព័ន្ធរៀនសូត្រពេញមួយជីវិតរបស់ពួកគេ។
- ប្រជាពលរដ្ឋគ្រប់រូប នៅក្នុងសហគមន៍មូលដ្ឋានគួរចូលរួមឱ្យបានសកម្ម ក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព អភិវឌ្ឍនជំនាញ ដើម្បីចេះប្រៀបធៀបសេណារីយ៉ូផ្សេងៗនាពេលអនាគត សម្រាប់សហគមន៍របស់ពួកគេ ច្បាមយកគុណតម្លៃ និងឥរិយាបថដែលគាំទ្រដល់ការកសាងអនាគតប្រកបដោយចីរភាព **ចូលរួមនៅក្នុងការនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងចាត់វិធានការក្នុងនាមជាសមាជិកប្រកបដោយការទទួលខុសត្រូវនៅក្នុងសហគមន៍។**

ដើម្បីគាំទ្រដល់សកម្មភាពទាំងនេះ យូណេស្កូ និងទីភ្នាក់ងារសហប្រជាជាតិជាដៃគូ ក៏ដូចជាតួអង្គពាក់ព័ន្ធដទៃទៀត បានសហការជាមួយនឹងបណ្តាញទីក្រុង និងសហគមន៍ដែលមានស្រាប់ ដើម្បីបញ្ចូល ESD ទៅក្នុងការរៀនសូត្រនៅគ្រប់កម្រិតទាំងអស់នៅក្នុងសហគមន៍មូលដ្ឋាន និងតម្រឹមសកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដូចជាផ្តល់ការគាំទ្រដល់ការបង្កើតវេទិកាសកលដើម្បីឱ្យសហគមន៍មូលដ្ឋានអាចលើកកម្ពស់ភាពជាដៃគូ និងការសហការគ្នាបន្ថែមទៀត លើ ESD។

TOOL BOX

on.unesco.org/esdtoolbox

SewCream/Shutterstock.com

© UNESCO/C.ALIX

៤.

ការអនុវត្ត

ការអនុវត្តសកម្មភាពជាអាទិភាពទាំង ៥ នៃ *ESD សម្រាប់ឆ្នាំ ២០៣០* គឺជាសកម្មភាពដែលត្រូវអនុវត្ត ដោយរដ្ឋជាសមាជិក និងតួអង្គពាក់ព័ន្ធនៅថ្នាក់តំបន់ និងថ្នាក់សកល ដោយមានការគាំទ្រ និងជំនួយពី យូណេស្កូ និងដៃគូនានា របស់យូណេស្កូ

៤.១. ការអនុវត្ត *ESD* *របស់ឆ្នាំ ២០៣០* នៅកម្រិតប្រទេស

“ក្នុងការអនុវត្តសកម្មភាពជាអាទិភាព រដ្ឋជាសមាជិក ត្រូវបានអញ្ជើញឲ្យកៀរគរអ្នកពាក់ព័ន្ធដែលធ្វើការងារក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងផ្ដល់ការគាំទ្រដល់ការចងក្រងបណ្ដាញរបស់អ្នកពាក់ព័ន្ធទាំងនេះ ដោយប្រើប្រាស់យុទ្ធសាស្ត្រអនុវត្តក្របខ័ណ្ឌជាតិស្ដី SDG ដោយមានការសម្របសម្រួល។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់បន្ថែមទៀត ដើម្បីរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយ និងតស៊ូមតិ ជំរុញឱ្យមានការឆ្លុះបញ្ចាំង SDG ក្នុងការអនុវត្តសកម្មភាពអប់រំ និងក្នុងក្របខ័ណ្ឌអប់រំ។ គំនិតផ្ដួចផ្ដើម ដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះនៅទូទាំងប្រទេស ក៏អាចត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ការអនុវត្ត ***ESD សម្រាប់ឆ្នាំ ២០៣០*** នៅកម្រិតប្រទេស ផងដែរ។”

(កថាខណ្ឌ ៥.១៩ ក្របខ័ណ្ឌសម្រាប់អភិវឌ្ឍន៍ ESD សម្រាប់ ២០៣០)

វត្ថុបំណង

ដើម្បីកសាងនូវមូលដ្ឋានសម្រាប់អនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០ និងសកម្មភាពជាអាទិភាពទាំង ៥ នៃ ESD រដ្ឋជាសមាជិកត្រូវបានលើកទឹកចិត្តឲ្យចូលរួមអនុវត្តគំនិតផ្តួចផ្តើមតាមប្រទេស ដើម្បីបញ្ជ្រាប ESD ទៅក្នុងការអប់រំ និងការអភិវឌ្ឍប្រកបដោយចីរភាព។

សកម្មភាពដែលលើកស្នើនៅតាមប្រទេស

ដើម្បីអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* នៅក្នុងប្រទេស រដ្ឋជាសមាជិកត្រូវបានអញ្ជើញឲ្យ

- ចូលរួមក្នុងគំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* នៅតាមប្រទេសដែលមាន ឬអាចមានផលជះទូទាំងប្រទេស។ គំនិតផ្តួចផ្តើមទាំងនេះអាចរៀបចំធ្វើឡើង ផ្អែកតាមគំនិតផ្តួចផ្តើមដែលមានស្រាប់ពាក់ព័ន្ធនឹង ESD ឬអាចមានការបង្កើតគំនិតផ្តួចផ្តើមថ្មី ប្រសិនបើចាំបាច់ ក្នុងបរិបទនៃការរួមចំណែករបស់ SDG ទី ៤ និងត្រូវមានការពង្រីកវិសាលភាពនៃគំនិតផ្តួចផ្តើមទាំងនេះ ក្នុងករណីដែលអាចធ្វើទៅបាន។ ជាធម្មតា រដ្ឋាភិបាល ឬតួអង្គក្រៅរដ្ឋាភិបាលណាមួយ ត្រូវផ្តួចផ្តើមបង្កើត និងដឹកនាំគំនិតផ្តួចផ្តើមនៅក្នុងប្រទេស ដោយសហការជាមួយនឹងរដ្ឋាភិបាល។
- បញ្ចូលសកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០* ក្នុងក្របខ័ណ្ឌជាតិស្តីពី SDG ក្របខ័ណ្ឌអប់រំ ឬក្របខ័ណ្ឌពាក់ព័ន្ធដទៃទៀត ដើម្បីធានាឲ្យមានការអនុវត្តសកម្មភាពដែលមានលក្ខណៈប្រទាក់ក្រឡាគ្នានៅថ្នាក់ជាតិ។
- ឆ្លើយតបចំពោះសកម្មភាពមួយឬច្រើននៅក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៥ តាមរយៈការអនុវត្តសកម្មភាពជាច្រើន ដែលអាចបញ្ចូលទៅក្រោមឆ័ត្រនៃគំនិតផ្តួចផ្តើមដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះណាមួយក្នុងប្រទេសនីមួយៗ។
- ជំរុញឲ្យមានការកសាងភាពជាដៃគូ និងការសហការគ្នាអន្តរវិស័យ ជាពិសេសជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗ នៃសកម្មភាពជាអាទិភាពទាំង ៥ ដើម្បីឆ្លើយតបបញ្ហានានាដែលកើតមាននៅក្នុងវិស័យអប់រំ និងវិស័យអភិវឌ្ឍន៍ដោយចីរភាពដែលពាក់ព័ន្ធ។ គួរមានការបង្កើតក្រុមការងារនៅកម្រិតប្រទេស ដើម្បីទទួលខុសត្រូវលើការសម្របសម្រួលការធ្វើផែនការការអនុវត្តការបង្កើតបណ្តាញការពិនិត្យតាមដាន ការរាយការណ៍ និងការទំនាក់ទំនងជាមួយនឹងយុណេស្កូ។ ស្ថាប័នដឹកនាំ SDG នៅថ្នាក់ជាតិ គណៈកម្មការជាតិយុណេស្កូ ឬក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត អាចធ្វើជាប្រធាននៃក្រុមការងារនេះ។
- ពង្រឹងកិច្ចខិតខំប្រឹងប្រែងទំណាក់ទំនង និងតស៊ូមតិជុំវិញ SDG ដើម្បីកៀរគរឱ្យមានការចូលរួមពីក្រុមអ្នកពាក់ព័ន្ធដទៃទៀត ក្រៅតែពីសហគមន៍អភិវឌ្ឍន៍ដោយចីរភាព។
- ពិនិត្យតាមដាន និងរាយការណ៍វឌ្ឍនភាពនៃគំនិតផ្តួចផ្តើមតាមប្រទេស ដោយកំណត់ចំណុចដៅឱ្យបានច្បាស់លាស់ ក្នុងករណីដែលអាចធ្វើទៅបាន។

សកម្មភាពរបស់យុណេស្កូ

- យុណេស្កូគាំទ្រដល់គំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* នៅតាមប្រទេសផ្អែកតាមសំណើ ដែលដាក់ដោយរដ្ឋជាសមាជិក។
- យុណេស្កូគាំទ្រការកសាងភាពជាដៃគូ និងការសហការគ្នារវាងគំនិតផ្តួចផ្តើមនៅតាមប្រទេស។
- យុណេស្កូផ្តល់ការគាំទ្របច្ចេកទេសពិសេសដល់គំនិតផ្តួចផ្តើមនៅតាមប្រទេសដែលត្រូវបានកំណត់ និងរៀបចំកិច្ចប្រជុំចែករំលែកព័ត៌មាននៅថ្នាក់តំបន់ ដើម្បីផ្តល់ការណែនាំបច្ចេកទេសដល់ការបង្កើតគំនិតផ្តួចផ្តើមទាំងនេះ។
- យុណេស្កូពិនិត្យតាមដានវឌ្ឍនភាព នៃការបញ្ចូលគំនិតផ្តួចផ្តើមនៅតាមប្រទេស ទៅក្នុងការរាយការណ៍ជាសកល *ESD សម្រាប់ឆ្នាំ ២០៣០* (សូមមើលទំព័រទី ៤៨ សម្រាប់ព័ត៌មានបន្ថែម)។
- គេរំពឹងថាគំនិតផ្តួចផ្តើមនៅតាមប្រទេសនឹងទទួលបានថវិកាគាំទ្រដោយខ្លួនឯង។ យុណេស្កូអាចផ្តល់ថវិកាចាប់ផ្តើមសកម្មភាពដំបូងដល់គំនិតផ្តួចផ្តើមនៅតាមប្រទេសកំពុងអភិវឌ្ឍ។

TOOL BOX
on.unesco.org/esdtoolbox

៤.២. កសាងភាពជាដៃគូ និងជំរុញការសហការ

"ក្នុងការអនុវត្តសកម្មភាពជាអាទិភាព រដ្ឋជាសមាជិកត្រូវបានអញ្ជើញឲ្យកៀរគរ តួអង្គពាក់ព័ន្ធនានា ដែលកំពុងធ្វើការងារនៅក្នុងផ្នែកសកម្មភាពទាំង ៥ និងគាំទ្រដល់ការចងក្រងបណ្តាញសហការគ្នា ដោយប្រើប្រាស់យុទ្ធសាស្រ្តដែលមានការសម្របសម្រួល ជុំវិញក្របខ័ណ្ឌជាតិស្តីពីគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

យូណេស្កូនឹងបន្តផ្តល់ការគាំទ្រ ដល់ការកសាងបណ្តាញដៃគូសំខាន់ៗដែលត្រូវបានកំណត់នៅថ្នាក់សកល និងដល់ដំណើរការចងក្រងបណ្តាញរបស់ពួកគេ។ កិច្ចការងារនេះនឹងត្រូវធ្វើឡើងតាមរយៈការផ្តល់ឲ្យពួកគេនូវវេទិកាមួយ ដើម្បីជួបគ្នាជាប្រចាំដើម្បីផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍នានានិងរៀបចំផែនការសហការគ្នាក្នុងការអនុវត្តគំនិតផ្តួចផ្តើម។ វេទិកានេះចាំបាច់ត្រូវមានការចូលរួមពីតំណាងនិងដៃគូមកពីវិស័យរដ្ឋាភិបាល និងវិស័យឯកជន ក៏ដូចជាពីអ្នកផ្តល់ជំនួយ សហគមន៍ដៃគូអភិវឌ្ឍន៍ និងសហគមន៍ SDG ព្រមទាំងតួអង្គពាក់ព័ន្ធ ដែលធ្វើការងារនៅក្នុងវិស័យសកម្មភាពជាអាទិភាពទាំង៥ នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល។

(កថាខណ្ឌ ៥.១៩, ៥.២២ ក្របខ័ណ្ឌសម្រាប់ ESD សម្រាប់ឆ្នាំ ២០៣០)

វត្ថុបំណង

ដើម្បីអនុវត្តសកម្មភាពជាអាទិភាពទាំង ៥ នៃ *ESD សម្រាប់ឆ្នាំ ២០៣០* ត្រូវមានការរៀបចំឱកាសកសាងបណ្តាញដល់រដ្ឋជាសមាជិក និងតួអង្គពាក់ព័ន្ធដទៃទៀត ដើម្បីលើកកម្ពស់ការសហការឆ្លងប្រទេស និងឆ្លងវិស័យ ក៏ដូចជាកសាងកម្លាំងផ្គួបរវាងតួអង្គពាក់ព័ន្ធទាំងនេះ។

សកម្មភាពដែលស្នើឡើង នៅកម្រិតប្រទេស

ដើម្បីកសាងភាពជាដៃគូ និងជំរុញការសហការ រដ្ឋជាសមាជិកត្រូវបានអញ្ជើញឱ្យ

- ពង្រឹងភាពជាដៃគូ និងការសហការក្នុងចំណោមវិស័យសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការ រួមនឹងការរៀនសូត្រពេញមួយជីវិតឆ្លងជំនាន់ ដែលកើតមាននៅតាមសហគមន៍។
- កសាង និងផ្តល់ការគាំទ្រដល់ភាពជាដៃគូ និងការសហការក្នុងចំណោមតួអង្គពាក់ព័ន្ធដែលធ្វើការងារខាងការអប់រំ ការអភិវឌ្ឍដោយចីរភាព និងគោលដៅអភិវឌ្ឍន៍ដោយចីរភាព រាប់បញ្ចូលទាំងគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤ ផងដែរ។
- ពង្រឹងភាពជាដៃគូ និងការសហការគ្នារវាងរដ្ឋ និងឯកជន ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរ ដែលជាមូលដ្ឋានគ្រឹះចាំបាច់ ដើម្បីកសាងអនាគតប្រកបដោយចីរភាព និងការកៀរគរធនធាន ដើម្បីគាំទ្រដល់ដំណើរការនេះ។
- អភិវឌ្ឍបណ្តាញនៅទូទាំងប្រទេស សម្រាប់តួអង្គដែលធ្វើការងារពាក់ព័ន្ធនឹង *ESD សម្រាប់ឆ្នាំ ២០៣០* អាចសម្របសម្រួលសកម្មភាពនានានៃគំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* ដែលអនុវត្តនៅក្នុងប្រទេស និងផ្តល់ភាពងាយស្រួល ដើម្បីឱ្យតួអង្គពាក់ព័ន្ធចម្រុះអាចចូលរួមនៅក្នុងភាពជាដៃគូ និងការសហការនេះបាន។
- តម្រឹម និងពង្រឹងការសម្របសម្រួល និងការសហការនៅថ្នាក់សកល ថ្នាក់តំបន់ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានជុំវិញគោលនយោបាយ និងការអនុវត្ត ESD ដើម្បីធានាឲ្យមានការផ្គួបកម្លាំងគ្នា និងការគាំទ្រដល់គ្នាទៅវិញទៅមក ។

សកម្មភាពរបស់យូណេស្កូ

បណ្តាញសកលនៃ ESD សម្រាប់ឆ្នាំ ២០៣០ (ESD-Net)

យូនីស្កូបង្កើតបណ្តាញសកលនៃ *ESD សម្រាប់ឆ្នាំ ២០៣០* (ESD-Net)៖

- ដើម្បីសម្របសម្រួលកិច្ចពិគ្រោះយោបល់ ភាពជាដៃគូ និងការសហការគ្នារវាងតំណាងនៃគំនិតផ្តួចផ្តើមនៅតាមប្រទេស និងអង្គការជាដៃគូដទៃទៀត។
- ចែករំលែកមេរៀនដែលទទួលបាន និងការអនុវត្តល្អពាក់ព័ន្ធនឹង *ESD សម្រាប់ឆ្នាំ ២០៣០* ដើម្បីផ្តល់ឱកាសឲ្យមានការរៀនសូត្រពីគ្នាទៅវិញទៅមក។
- ទាញចំណាប់អារម្មណ៍ ចំពោះការបន្តួរមចំណែករបស់ ESD ដល់ SDG ដែលជាផ្នែកមួយនៃការតស៊ូមតិជាសកល ជុំវិញ ESD។
- រាយការណ៍ និងតាមដានវឌ្ឍនភាពឆ្ពោះទៅអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ។

តើអ្នកណាខ្លះដែលជាសមាជិក?

- តំណាងនៃគំនិតផ្តួចផ្តើមនៅកម្រិតប្រទេស ដូចជា ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ស្ថាប័ននីមួយៗ ទីភ្នាក់ងារសហប្រជាជាតិដែលជាដៃគូ សមាជិកនៃសហគមន៍ដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារផ្តល់ជំនួយ។

តើបណ្តាញនេះដំណើរការយ៉ាងដូចម្តេច?

- យូណេស្កូរៀបចំកិច្ចប្រជុំបណ្តាញ ESD-Net ថ្នាក់សកលរៀងរាល់ ២ ឆ្នាំម្តង ដោយកិច្ចប្រជុំលើកទីមួយគ្រោងនឹងធ្វើឡើងនៅក្នុងឆ្នាំ ២០២៣ ដើម្បីពិភាក្សាពីវឌ្ឍនភាពចុងក្រោយ ដែលសម្រេចបានពីការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ។
- នៅចន្លោះកិច្ចប្រជុំទាំងនេះ នឹងមានការសម្របសម្រួលការរៀនសូត្ររវាងគ្នាទៅវិញទៅមកតាមប្រព័ន្ធអនឡាញ ដើម្បីកសាងការសហការផ្គួបកម្លាំងគ្នាក្នុងចំណោមសមាជិករបស់បណ្តាញ។
- នៅក្នុងបណ្តាញនេះអាចមានការបង្កើតអនុក្រុមការងារថ្នាក់តំបន់ អនុក្រុមបែងចែកតាមប្រធានបទ ឬអនុក្រុមដែលផ្តោតលើបញ្ហាអ្វីមួយនៃបណ្តាញនេះ អាស្រ័យទៅតាមតម្រូវការដែលត្រូវបានកំណត់។ ការងាររបស់អនុក្រុមនៅក្នុងតំបន់ គួរធ្វើឡើងតាមបែបផែនដែលអាចបង្កើនកម្លាំងផ្គួបជាមួយនឹងយន្តការសម្របសម្រួល SDG ថ្នាក់តំបន់ និងដំណើរការអន្តរជាតិដទៃទៀតបានដល់កម្រិតអតិបរមា។

TOOL BOX

on.unesco.org/esdtoolbox

៤.៣. ការអប់រំផ្សព្វផ្សាយ ដើម្បីជំរុញឲ្យមានការធ្វើសកម្មភាព

"នៅក្នុងពេលជាមួយគ្នា ជាមួយនឹងវត្តមាននៃគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) ដែលត្រូវបានប្រកាសផ្សព្វផ្សាយ កន្លងមក ESD ក៏អាចមានតួនាទីបន្ថែមទៀត ដើម្បីជួយសម្រេច SDG តាមរយៈការលើកឡើងឲ្យបានជាក់ច្បាស់ ពីគោលដៅទាំងនេះ។ សកម្មភាពអប់រំផ្សព្វផ្សាយ និងតស៊ូមតិដែលពាក់ព័ន្ធនឹង SDG នៅតាមគ្រឹះស្ថានអប់រំ គឺសុទ្ធតែជាឧទាហរណ៍។ ជាធម្មតាសកម្មភាពទាំងនេះត្រូវផ្សព្វផ្សាយដល់អ្នកសិក្សានៅគ្រប់វ័យអំពី SDG ទាំង ១៧ ព្រមទាំងភាពពាក់ព័ន្ធនៃគោលដៅទាំងនេះ ចំពោះជីវិតរបស់ពួកគេម្នាក់ៗ ក្នុងនាមជាបុគ្គល និងក្នុងនាមជាក្រុមរួមទាំងការទទួលខុសត្រូវដែលបុគ្គល និងស្ថាប័នត្រូវមានដើម្បីជួយសម្រេចគោលដៅទាំងនេះ។ សកម្មភាព ESD ទាំងនេះសុទ្ធតែជាសកម្មភាពដែលមានតម្រូវការខ្ពស់ ព្រោះថាគេចាំបាច់ត្រូវអប់រំផ្សព្វផ្សាយដល់អ្នកសិក្សានៅគ្រប់វ័យ ក៏ដូចជាសាធារណជនទូទៅ ដើម្បីពង្រីកការយល់ដឹងរបស់ពួកគេអំពី SDG និងតួនាទីនៃការអប់រំដើម្បីសម្រេចគោលដៅទាំងនេះ។"

"លើសពីនេះ ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងអប់រំផ្សព្វផ្សាយ និងតស៊ូមតិផ្តោតចំគោលដៅបន្ថែមទៀត ដើម្បីផ្សព្វផ្សាយពីតួនាទីនៃការអប់រំនៅក្នុងការគាំទ្រដល់ការសម្រេច SDG។ នៅថ្នាក់ជាតិ កិច្ចខិតខំប្រឹងប្រែងនេះគឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* ដែលត្រូវអនុវត្តនៅទូទាំងប្រទេស។ នៅកម្រិតសកល យូណេស្កូនឹងរៀបចំកម្មវិធីពិសេសមួយ ដើម្បីជម្រាបជូនសហគមន៍ពាក់ព័ន្ធអំពី SDG និងដល់អ្នកសិក្សា ក៏ដូចជាអ្នកអប់រំអំពីតួនាទីដ៏សំខាន់ដែលការអប់រំអាចបំពេញ ដើម្បីជួយគាំទ្រដល់ការសម្រេច SDG។ កម្មវិធីផ្តល់រង្វាន់ដែលអនុវត្តដោយយូណេស្កូ និងប្រទេសជប៉ុន ប្រសិនបើនៅតែបន្តអនុវត្តនឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្រ្តអប់រំផ្សព្វផ្សាយ និងតស៊ូមតិរបស់យូណេស្កូ។

(កថាខណ្ឌ ៥.៤, ៥.២៤ ក្របខ័ណ្ឌសម្រាប់ ESD សម្រាប់ឆ្នាំ ២០៣០)

វត្ថុបំណង

ដោយបង្ហាញឲ្យឃើញពីភាពបន្ទាន់ក្នុងការអនុវត្តសកម្មភាពជាអាទិភាពទាំង ៥ និងអាចធានាយ៉ាងណាឲ្យ *ESD សម្រាប់ឆ្នាំ ២០៣០* ទទួលបានជោគជ័យ រដ្ឋជាសមាជិកនិងតួអង្គពាក់ព័ន្ធដទៃទៀតត្រូវបានលើកទឹកចិត្តឲ្យធ្វើការអប់រំផ្សព្វផ្សាយ និងតស៊ូមតិ ដោយត្រូវជំរុញឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ និងដៃគូមកពីវិស័យអប់រំ និងវិស័យអភិវឌ្ឍន៍ដោយចីរភាពឱ្យបានទូលំទូលាយ។

សកម្មភាពដែលស្នើឡើង នៅកម្រិតប្រទេស

ពាក់ព័ន្ធនឹងការតស៊ូមតិ រដ្ឋជាសមាជិកត្រូវបានអញ្ជើញឲ្យៈ

- ចុះផ្សព្វផ្សាយពីតួនាទីនៃការអប់រំក្នុងនាមជាកាតាលីករ ដើម្បីបំពេញគោលដៅ SDG ទាំងអស់ តាមរយៈការអប់រំផ្សព្វផ្សាយផ្តោតចំគោលដៅ ដោយត្រូវបញ្ចូលសកម្មភាពនេះទៅក្នុងសកម្មភាព ESD ទាំងអស់របស់ខ្លួន និងត្រូវកៀរគរឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ។
- គួរបញ្ជាក់ពីសារៈសំខាន់នៃការអប់រំនៅក្នុងការងារអប់រំផ្សព្វផ្សាយ និងតស៊ូមតិរបស់ខ្លួនពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព និង SDG រាប់បញ្ចូលទាំងយុទ្ធនាការសាធារណៈផងដែរ។
- ប្រើប្រាស់របៀបអប់រំផ្សព្វផ្សាយដែលមានលក្ខណៈនវានុវត្តន៍អំពីការងារ ESD របស់ខ្លួន ដូចជា ប្រើប្រាស់វេទិកាឌីជីថល និងផ្តល់អាទិភាពដល់ការចូលរួមរបស់យុវជន។

សកម្មភាពរបស់យូណេស្កូ

ផ្តល់ភាពអង់អាចដើម្បីឲ្យតួអង្គពាក់ព័ន្ធសំខាន់ៗចូលរួម នៅក្នុងកិច្ចខិតខំប្រឹងប្រែងអប់រំផ្សព្វផ្សាយរបស់ពួកគេ។

យូណេស្កូធ្វើការងារជាមួយនឹងតួអង្គសំខាន់ៗ ដែលធ្វើការងារពាក់ព័ន្ធសកម្មភាពជាអាទិភាពទាំង ៥ ដូចជា គ្រឹះស្ថានអប់រំ អ្នកអប់រំ និងអ្នកអនុវត្តន៍ការងារ យុវជន និងអ្នកធ្វើគោលនយោបាយ ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេអាចផ្តល់ព័ត៌មានដល់តួអង្គពាក់ព័ន្ធនានា អំពី ESD និងស្វែងរកការគាំទ្រពីតួអង្គពាក់ព័ន្ធទាំងនោះ។ យូណេស្កូ ធ្វើការងារ ដើម្បី

- បង្ហាញពីការអនុវត្តល្អជុំវិញការរួមចំណែករបស់ ESD ដល់ការសម្រេចSDGតាមរយៈផលិតផលនិងច្រកសម្រាប់អប់រំផ្សព្វផ្សាយរបស់ខ្លួន ដូចជា តាមរយៈបណ្តាញសាលារៀនដែលមានទំនាក់ទំនងជាមួយយូណេស្កូជាដើម។
- រំលេចឲ្យឃើញអំពីគំនិតផ្តួចផ្តើម ESD ដែលមានលក្ខណៈលេចធ្លោ ហើយដែលរួមចំណែកដល់ការសម្រេច SDG តាមរយៈកម្មវិធីផ្តល់រង្វាន់ ESD ដែលអនុវត្តដោយយូណេស្កូ និងប្រទេសជប៉ុន។
- ផ្តល់ឯកសារធនធានសិក្សារៀនសូត្រអំពី SDG ដោយបង្ហាញពី SDG ណាមួយ ឬ SDG មួយចំនួន រំលេចឲ្យឃើញពីវត្ថុបំណង និងគោលវិធីដែលប្រើប្រាស់សម្រាប់ការសិក្សា ក៏ដូចជាភាពប្រទាក់ក្រឡាគ្នា និងភាពប្រទាំងប្រទើសគ្នារវាងគោលដៅមួយចំនួន។

ការតស៊ូមតិ នៅកម្រិតសកល

យូណេស្កូក៏ធ្វើការងារដើម្បីបង្ហាញឲ្យឃើញពីតួនាទីរបស់ ESD នៅថ្នាក់សកលផងដែរ ជាពិសេសតួនាទីរបស់យូណេស្កូក្នុងនាមជាស្ថាប័នសំខាន់ដែលជួយដល់ការសម្រេចគោលដៅ SDG ទាំង ១៧។ យូណេស្កូ ធ្វើការដើម្បីៈ

- កោះឲ្យមានកិច្ចប្រជុំជាសកលនៃបណ្តាញ ESD-Net រៀងរាល់ពីរឆ្នាំម្តង ដែលបណ្តាលគឺជាវេទិកាដ៏សំខាន់មួយសម្រាប់ការស្វែងរកការគាំទ្រដល់ ESD នៅកម្រិតសកល ហើយក៏ជាឱកាសដើម្បីឲ្យតួអង្គពាក់ព័ន្ធនានាចងក្រងបណ្តាញជាមួយគ្នាផងដែរ។
- គាំទ្រដល់ច្រកអនឡាញ ដើម្បីភ្ជាប់ទំនាក់ទំនងគំនិតផ្តួចផ្តើមនៅតាមប្រទេសនានា និងដល់តួអង្គពាក់ព័ន្ធ ក៏ដូចជារៀបចំ រួមគ្នានូវទិវាសំខាន់ៗ ដើម្បីកសាងឱកាស និងជំរុញឲ្យមានកាអនុវត្តសកម្មភាព ESD នៅកម្រិតសកល។
- ប្រើប្រាស់លទ្ធផលដែលសម្រេចបានពីយុទ្ធនាការESDឆ្នាំ២០២០ ដែលរៀបចំដោយយូណេស្កូ ដោយជំរុញឲ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធនៅកម្រិតសកលឲ្យបានទូលំទូលាយ ដើម្បីលើកទឹកចិត្តដល់បុគ្គល និងសហគមន៍ទទួលខុសត្រូវ និងធ្វើសកម្មភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព។
- ចូលរួមក្នុងដំណើរការដែលអនុវត្តដោយអង្គការសហប្រជាជាតិ និងដំណើរការអន្តរជាតិដទៃទៀត ដែលផ្តោតពីការអភិវឌ្ឍដោយចីរភាព (ដូចជា សន្និសីទភាគីនៃកិច្ចព្រមព្រៀងប្រែប្រួលអាកាសធាតុ) ដែលនេះគឺជាឱកាសដើម្បីរំលេចឲ្យឃើញពីសារសំខាន់នៃ *ESD សម្រាប់ឆ្នាំ ២០៣០* និងសហការជាមួយនឹងស្ថាប័នអង្គការសហប្រជាជាតិដទៃទៀតដូចជា UN DESA, បណ្តាញ ONE Planet Network របស់ UNEP និងស្ថាប័នដទៃទៀតដែលទទួលខុសត្រូវលើការគ្រប់គ្រង SDG ក៏ដូចជាដៃគូសកលដទៃទៀត ដូចជា មជ្ឈមណ្ឌលជំនាញ ESD ថ្នាក់តំបន់ជាដើម។

TOOL BOX
on.unesco.org/esdtoolbox

៥.៥. ការតាមដានបញ្ហា និងនិន្នាការនានា

“ការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ត្រូវធ្វើឡើងដោយផ្អែកតាមភស្តុតាង។ ចាំបាច់ត្រូវមានការពិនិត្យតាមដានបញ្ហា និងនិន្នាការថ្មីៗឲ្យបានល្អិតល្អន់ និងយកទៅធ្វើការវិភាគ ដើម្បីកំណត់ពីភាពពាក់ព័ន្ធ និងគោលវិធីគរុកោសល្យ។ ដើម្បីសម្រេចគោលដៅនេះ យូណេស្កូត្រូវធ្វើការវិភាគលើបញ្ហាដែលបានកំណត់ ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងដំណើរការដែលនាំមកនូវការផ្លាស់ប្តូររបស់បុគ្គលម្នាក់ៗ បញ្ហាដែលមានសារសំខាន់សម្រាប់ការអភិវឌ្ឍ និងចីរភាព ព្រមទាំងអនាគតនៃ ESD ក្នុងយុគសម័យនៃការជឿនលឿនផ្នែកវិទ្យាសាស្ត្រ ដោយត្រូវមានការផ្សព្វផ្សាយលទ្ធផលដល់តួអង្គពាក់ព័ន្ធនានានៅក្នុងមូលដ្ឋានផ្ទាល់។

(កថាខណ្ឌ ៥.២៣ ក្របខ័ណ្ឌសម្រាប់ ESD សម្រាប់ឆ្នាំ ២០៣០)

វត្ថុបំណង

ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពជាអាទិភាពទាំង ៥ នៃ ESD ឆ្នាំ ២០៣០ ដោយប្រើប្រាស់ភស្តុតាងជាក់លាក់ និងដាក់ចេញនូវចក្ខុវិស័យយុទ្ធសាស្ត្រ ចាំបាច់ត្រូវមានការពិនិត្យឡើងវិញលើស្ថានការណ៍ចុងក្រោយនៅក្នុងវិស័យអប់រំ និងវិស័យអភិវឌ្ឍន៍ដោយចីរភាព។

ស្ថានភាពប្រសើរឡើងនៅថ្នាក់ប្រទេស

ដើម្បីតាមដានបញ្ហា និងនិន្នាការនានា រដ្ឋជាសមាជិកត្រូវបានអញ្ជើញឲ្យ

- ការពិនិត្យឡើងវិញលើគោលដៅ SDG ទាំង ១៧ ក្រោមបរិបទនៅមូលដ្ឋាន បរិបទជាតិ និងបរិបទតំបន់នៅតាមគ្រឹះស្ថានអប់រំនានា ជាផ្នែកមួយនៃការអនុវត្តសកម្មភាព ESD ដើម្បីការកំណត់ពីបញ្ហានិន្នាការ និងសំណួរពាក់ព័ន្ធដែលចាំបាច់ត្រូវពិនិត្យ និងពិភាក្សាបន្ត។
- ធ្វើការស្រាវជ្រាវតាមប្រធានបទពាក់ព័ន្ធអំ ESD និង SDG ផ្អែកតាមបញ្ហានិន្នាការ និងសំណួរសំខាន់ៗដែលត្រូវបានលើកឡើងពាក់ព័ន្ធនឹងសកម្មភាពជាអាទិភាពទាំង ៥។ គ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានស្រាវជ្រាវ គួរបំពេញតួនាទីសំខាន់នៅក្នុងសកម្មភាពស្រាវជ្រាវប្រភេទនេះ ដែលគេអាចបញ្ចូលផងដែរទៅក្នុងគំនិតផ្តួចផ្តើម ESD សម្រាប់ឆ្នាំ ២០៣០ នៅកម្រិតប្រទេស។
- ផ្សព្វផ្សាយ និងពិនិត្យឡើងវិញលើលទ្ធផលនៃការស្រាវជ្រាវ ដើម្បីកសាងឱកាសរៀនសូត្រ ដែលនាំឲ្យមានការលើកឡើងនូវសំណួរសំខាន់ៗ ជាពិសេស សំណួរពាក់ព័ន្ធនឹងភាពប្រទាក់ក្រឡាគ្នា និងភាពប្រទាំងប្រទើសរវាង SDG នានា។
- សហការជាមួយនឹងប្រទេសដទៃទៀត ដើម្បីពិនិត្យឡើងវិញលើបញ្ហា និងនិន្នាការថ្មីៗពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព និង ESD នៅក្នុងបរិបទជាក់លាក់ ដើម្បីស្វែងរកការឆ្លើយតបឲ្យបានសមស្របពីវិស័យអប់រំ។

សកម្មភាពរបស់យូណេស្កូ

យូណេស្កូ ធ្វើការស្រាវជ្រាវផ្តោតលើប្រធានបទមួយចំនួន រៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងអ្នកជំនាញ និងធ្វើការបោះពុម្ពផ្សាយរបាយការណ៍ពាក់ព័ន្ធអំពីបញ្ហា និងនិន្នាការថ្មីៗស្តីពីប្រធានបទសំខាន់ៗ ដែលពាក់ព័ន្ធនឹងការរួមចំណែករបស់ ESD ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ចីរភាព។ រួមគ្នាជាមួយនឹងដៃគូរបស់ខ្លួន យូណេស្កូ៖

- រៀបចំកិច្ចពិគ្រោះយោបល់ជាមួយអ្នកជំនាញ ដើម្បីកំណត់ និងការពិនិត្យឡើងវិញលើបញ្ហា និងនិន្នាការសំខាន់សំខាន់ថ្មីៗ។
- ធ្វើការសិក្សាដើម្បីប្រមូល និងវិភាគភស្តុតាងពាក់ព័ន្ធពីរដ្ឋជាសមាជិក ផលិតនូវរបាយការណ៍ផ្អែកតាមភស្តុតាង ដើម្បីកៀរគរតួអង្គនានាឲ្យចូលរួមនៅក្នុងការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០*។
- ផ្សព្វផ្សាយផលិតផលចំណេះដឹងចុងក្រោយ តាមរយៈប្រកតស្ទីមតិនានា ដូចជា កិច្ចប្រជុំនៅកម្រិតសកល ដែលធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង និងកម្មវិធីបណ្តុះបណ្តាលជាដើម។

TOOL BOX

on.unesco.org/esdtoolbox

ប្រធានបទ ដែលបានទទួលការយកចិត្តទុកដាក់

នឹងមានការយកចិត្តទុកដាក់ជាពិសេសលើប្រធានបទ និងសំណួរពាក់ព័ន្ធនឹងបរិបទសំខាន់ៗ និងការឆ្លុះបញ្ចាំងអំពី ESD សម្រាប់ឆ្នាំ ២០៣០ ជាអាទិ៍

ESD និង SDG

→ តើមានការអនុវត្តគរុកោសល្យអ្វីខ្លះ ដែលទទួលបានជោគជ័យ ក្នុងការសម្រេចគោលដៅ SDG ទាំង ១៧?

→ តើ ESD អាចផ្តោតការយកចិត្តទុកដាក់លើភាពប្រទាក់ក្រឡាគ្នា និងភាពតានតឹងរវាង SDG ផ្សេងៗដោយរបៀបណា?

សកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន និង ESD

→ តើការផ្លាស់ប្តូររបស់បុគ្គលម្នាក់ៗកើតឡើងដោយរបៀបណា និងថាតើការអប់រំអាចជួយសម្របសម្រួលឲ្យអ្នកសិក្សា អាចអនុវត្តសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីសម្រេចការអភិវឌ្ឍដោយចីរភាព តាមរបៀបណា?

→ តើសហគមន៍មានតួនាទីអ្វីខ្លះ ក្នុងការលើកកម្ពស់សកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីកសាងអនាគតប្រកបដោយចីរភាព?

បញ្ហាគន្លឹះនិង ESD

→ តើ ESD អាចគាំទ្រដល់ការរក្សាតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាពដោយរបៀបណា?

→ តើ ESD អាចលើកទឹកចិត្តឲ្យអ្នកសិក្សាឈ្វេងយល់ពីគុណតម្លៃនានាសម្រាប់សង្គមអ្នកប្រើប្រាស់ដោយរបៀបណា?

→ នៅក្នុងបរិបទនៃភាពក្រីក្រធ្ងន់ធ្ងរ តើ ESD ប្រភេទណាដែលអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងអ្នកសិក្សា និងផ្តល់ការគាំទ្រដល់ការដោះស្រាយបញ្ហាប្រឈមប្រចាំថ្ងៃរបស់ពួកគេ?

ការរីកចម្រើនផ្នែកបច្ចេកវិទ្យា និង ESD

→ តើបញ្ញាសិប្បនិម្មិត និងបដិវត្តន៍ឧស្សាហកម្មទី ៤ មានភាពពាក់ព័ន្ធអ្វីខ្លះចំពោះ ESD?

→ តើ ESD ឆ្លើយតបចំពោះហានិភ័យ និងអត្ថប្រយោជន៍នៃបច្ចេកវិទ្យាបៃតងបែបណាខ្លះ?

→ តើគេអាចប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដោយរបៀបណា ដើម្បីផ្តល់ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព?

៤.៥. ការកៀរគរធនធាន

“អ្វីដែលចាំបាច់ផងដែរនោះ គឺភាពជាដៃគូជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗដទៃទៀត ដូចជា ស្ថាប័នហិរញ្ញវត្ថុពហុភាគី ទីភ្នាក់ងារអភិវឌ្ឍន៍ជាតិ វិស័យឯកជន សង្គមស៊ីវិល និងតួអង្គពាក់ព័ន្ធនៅសហគមន៍។ សម្ព័ន្ធភាពជាមួយយន្តការជាតិ ដែលត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព តាមរយៈការអប់រំ ក៏ត្រូវការការយកចិត្តទុកដាក់បន្ថែមផងដែរ។ ក្នុងការកសាងភាពជាដៃគូ ទាមទារឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត ដល់ការប្រើប្រាស់យន្តការផ្តល់ហិរញ្ញប្បទានដែលមានលក្ខណៈនវានុវត្តន៍ និងច្នៃប្រឌិត។”

នៅក្នុងក្របខ័ណ្ឌ យូណេស្កូ វិស័យអប់រំត្រូវបន្តពង្រឹងភាពជាដៃគូអន្តរវិស័យរបស់ខ្លួនជាមួយនឹងវិស័យដទៃទៀត ជាពិសេសវប្បធម៌ និងវិទ្យាសាស្ត្រ ដោយត្រូវបញ្ចូលការ *ESD សម្រាប់ឆ្នាំ ២០៣០* ទៅក្នុងកម្មវិធីដែលពាក់ព័ន្ធក្នុងករណីដែលអាចធ្វើទៅបាន ជាអាទិ៍ កម្មវិធីដែលពាក់ព័ន្ធនឹងតំបន់បេតិកភណ្ឌពិភពលោក បេតិកភណ្ឌវប្បធម៌អរូបី និងបណ្តាញបរមនីយជីវមណ្ឌល តំបន់ឧទ្យានធម្មជាតិ (Geoparks) រដ្ឋកំពុងអភិវឌ្ឍដែលឋិតនៅលើដែនកោះតូចៗព្រមទាំងចំណេះដឹងក្នុងមូលដ្ឋាន និងចំណេះដឹងរបស់សហគមន៍ជនជាតិដើមភាគតិច។ វិស័យអប់រំក៏ត្រូវបន្តលើកកម្ពស់ការសហការក្នុងវិស័យរបស់ខ្លួន ជុំវិញ ESD ផងដែរ និងគួរលើកទឹកចិត្តឲ្យមានការរួមចំណែកពីកម្មវិធី និងបណ្តាញពាក់ព័ន្ធ និង *ESD សម្រាប់ឆ្នាំ ២០៣០* ដូចជា បណ្តាញសាលារៀនដែលមានទំនាក់ទំនងជាមួយយូណេស្កូ (ASPnet), ប្រធានយូណេស្កូ, មជ្ឈមណ្ឌលអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ UNEVOC, បណ្តាញទីក្រុងដែលផ្តល់អាទិភាពដល់ការរៀនសូត្រ ក៏ដូចជា គណៈកម្មាធិការដឹកនាំការអប់រំឆ្នាំ ២០៣០។

(កថាខណ្ឌ ៥.២៥-៥.២៧ នៃក្របខ័ណ្ឌសម្រាប់អនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០)

វត្ថុបំណង

ដើម្បីអនុវត្តសកម្មភាពជាអាទិភាពទាំង ៥ នៃ ESD ឆ្នាំ ២០៣០ ប្រកបដោយប្រសិទ្ធភាព ការកៀរគរធនធានដែលចាំបាច់គឺជារឿងដែលសំខាន់។

សកម្មភាពដែលស្នើឡើងនៅថ្នាក់ប្រទេស

ដើម្បីកៀរគរធនធានសម្រាប់អនុវត្ត ESD ឆ្នាំ ២០៣០ រដ្ឋជាសមាជិកត្រូវបានអញ្ជើញឱ្យ៖

- ពិនិត្យមើលលទ្ធភាពប្រើប្រាស់កម្មវិធី ដែលមានស្រាប់ក្នុងវិស័យអប់រំ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការអនុវត្តសកម្មភាព ESD ឆ្នាំ ២០៣០ ដូចជា ថវិកា និងកម្មវិធីការគាំទ្រដល់សាលារៀន ការបណ្តុះបណ្តាលគ្រូ ការលើកកម្ពស់ភាពអង់អាចរបស់យុវជន ការរៀនសូត្រពេញមួយជីវិតក្នុងទីក្រុងនិងសហគមន៍ ជាមួយនឹងការយល់ថា ESD មិនមែនជាប្រធានបទនោះឡើយ ប៉ុន្តែជាអភិក្រមគ្រប់ជ្រុងជ្រោយ ដើម្បីសម្រួចការអប់រំ សំដៅឆ្លើយតបចំពោះបញ្ហាដែលពាក់ព័ន្ធនឹងចីរភាព។
- ប្រើប្រាស់ធនធានមានស្រាប់ ដែលត្រូវបានវិភាជសម្រាប់ការអភិវឌ្ឍដោយចីរភាព ការអនុវត្ត ESD នៅក្នុងប្រទេស ក៏ដូចជាកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីបង្កើតកម្លាំងផ្ទួបរវាង ESD និងវិស័យដែលពាក់ព័ន្ធ។
- ពិចារណាវិភាជថវិកាថ្មីសម្រាប់ ESD នៅឆ្នាំ ២០៣០ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនៅក្នុងប្រទេស ដើម្បីលើកកម្ពស់ការអប់រំប្រកបដោយគុណភាព និងការរួមចំណែកនៃការអប់រំដល់ការរស់រាន និងការសម្រេចបាននូវវិបុលភាពជាសមូហភាពសម្រាប់មនុស្សជាតិ។
- ប្រើប្រាស់គំនិតផ្តួចផ្តើមពាក់ព័ន្ធនៅថ្នាក់តំបន់ ព្រមទាំងធនធាននៃគំនិតផ្តួចផ្តើមទាំងនេះ ដើម្បី ចូលរួមសហការជាមួយនឹងប្រទេសដទៃទៀត ក្នុងការអនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០។
- កៀរគរធនធានក្នុងវិស័យឯកជនជាពិសេស ដើម្បីប្រែក្លាយជាគ្រឹះស្ថាន TVET និងមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ក្រុមហ៊ុនឯកជនឲ្យក្លាយជាគ្រឹះស្ថាន ដែលផ្តល់ការគាំទ្រដល់ការអភិវឌ្ឍជំនាញក្នុងវិស័យបៃតង និងក្លាយជាគ្រឹះស្ថាននាំមុខ និងសកម្មក្នុងការលើកកម្ពស់ ESD សម្រាប់ឆ្នាំ ២០៣០។
- ស្វែងរកដំណោះស្រាយដែលមានលក្ខណៈច្នៃប្រឌិត ដើម្បីអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ប្រកបដោយប្រសិទ្ធភាព ដោយមិនប្រើប្រាស់ធនធានបន្ថែមច្រើន ដូចជា ការបញ្ចូល ESD ទៅក្នុងលក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃគុណភាពនៃការអប់រំ ដើម្បីវាយតម្លៃលើសមិទ្ធកម្មរបស់គ្រឹះស្ថានអប់រំ។

សកម្មភាពរបស់យូណេស្កូ

- ការកៀរគរធនធានដែលធ្វើឡើងដោយយូណេស្កូ ដើម្បីគាំទ្រដល់រដ្ឋជាសមាជិកក្នុងការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០*។
- នៅថ្នាក់សកលយូណេស្កូនឹងខិតខំប្រឹងប្រែងស្វែងរកថវិកាសម្រាប់ជួយដល់ការងារអប់រំ និងការអភិវឌ្ឍដោយចីរភាព និងជំរុញឲ្យមានការប្រើប្រាស់ថវិកាទាំងនេះ ដើម្បីគាំទ្រដល់សកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០*។
- មានការរំពឹងទុកថា រាល់សកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០* ទាំងអស់ រាប់បញ្ចូលទាំងគំនិតផ្តួចផ្តើមដែលអនុវត្តទៅតាមប្រទេសផង នឹងមានថវិកាគាំទ្រដោយខ្លួនឯង។ យូណេស្កូនឹងផ្តល់ថវិកាសម្រាប់ជួយការចាប់ផ្តើមសកម្មភាពដល់គំនិតផ្តួចផ្តើមមួយចំនួនតូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចតួច។
- ធនធានសម្រាប់សកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០* របស់យូណេស្កូ។
- យូណេស្កូនឹបន្តខិតខំប្រឹងប្រែងកៀរគរការរួមបដិភាគ ដែលស្ម័គ្រចិត្ត។
- យូណេស្កូ នឹងប្រើប្រាស់ការគាំទ្រមិនមែនថវិកាពីបណ្តាញនានារបស់យូណេស្កូ ដើម្បីជួយដល់ការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ជាពិសេស ASPnet ប្រធានយូណេស្កូ មជ្ឈមណ្ឌលនានារបស់យូណេស្កូ ដូចជា មជ្ឈមណ្ឌល TVET របស់ UNEVOC បណ្តាញបឋមនីយជីវមជ្ឈមណ្ឌល និងឧទ្យានធម្មជាតិពិភពលោក តំបន់បេតិកភណ្ឌពិភពលោក និងបេតិកភណ្ឌវប្បធម៌អរូបី ព្រមទាំងតំណាងជាទីក្រុងរបស់យូណេស្កូ (ជាពិសេសបណ្តាញសកលនៃទីក្រុងដែលផ្តោតការយកចិត្តទុកដាក់លើការសិក្សា និងបណ្តាញទីក្រុងប្រកបដោយភាពច្នៃប្រឌិតរបស់យូណេស្កូ)។

TOOL BOX
on.unesco.org/esdtoolbox

៤.៦. ពិនិត្យតាមដានវឌ្ឍនភាព

“ការពិនិត្យតាមដាន និងការវាយតម្លៃជាច្រើនប្រភេទ នៅតែជាកិច្ចការសំខាន់ៗរបស់យូណេស្កូ ដូចរៀបរាប់ខាងក្រោម។ ផ្អែកតាមមេរៀនដែលទទួលបានពីកម្មវិធី GAP ចាំបាច់ត្រូវមានការអនុវត្ត និងកែលម្អវិធានការពិនិត្យតាមដានជាក់លាក់ ក្នុងគោលបំណងសម្រេចចំណុចដៅ ៤.៧ នៃ SDG ឲ្យបានត្រឹមឆ្នាំ ២០៣០។

ដំបូង ការពង្រីកវិសាលភាពសកម្មភាពនានា ដែលជាផ្នែកនៃសកម្មភាពជាអាទិភាពទាំង ៥ ធ្វើឡើងដោយរដ្ឋជាសមាជិក ក៏ដូចជាដៃគូដែលត្រូវបានកំណត់នៅកម្រិតសកល ទាមទារឲ្យមានការពិនិត្យតាមដានឲ្យបានជិតស្និទ្ធ។ [...]

ដើម្បីវាស់វែងការពង្រីកវិសាលភាពសកម្មភាពទាំងនេះនៅក្នុងរដ្ឋជាសមាជិក យូណេស្កូនឹងធ្វើការកែសម្រួលនូវកម្រងសំណួរដែលប្រើប្រាស់ សម្រាប់អង្កេតតាមដានចំណុចដៅ ៤.៧។ មានការលើកស្នើឲ្យមានការបញ្ចូលកិច្ចខិតខំប្រឹងប្រែង ដើម្បីវាស់វែងវឌ្ឍនភាពនៃការពង្រីកសកម្មភាព ក្នុងផ្នែកសកម្មភាពជាអាទិភាពទាំង ៥ នៅតាមប្រទេសនានាទៅក្នុងឧបករណ៍នេះ។ [...]

ការពិនិត្យតាមដានប្រភេទទី ២ នឹងត្រូវធ្វើឡើងក្នុងវិសាលភាពរបស់កម្មវិធី ឬគម្រោងដែលត្រូវបានកំណត់ នឹងមានការយកចិត្តទុកដាក់ ដើម្បីធានាឲ្យមានការសម្រេចលទ្ធផលរំពឹងទុកដូចនៅក្នុងផែនការ និងធ្វើឲ្យផលជះ ដែលបានពីសកម្មភាពទាំងនេះកាន់តែមានវិសាលភាពធំទូលាយ។ [...]

លើសពីនេះក៏នឹងមានកិច្ចខិតខំប្រឹងប្រែងពិនិត្យតាមដានថ្មីមួយដែលធ្វើឡើងដោយយូណេស្កូផងដែរ។ ដើម្បីគាំទ្រដល់គោលការណ៍ប្រើប្រាស់ភស្តុតាងសម្រាប់អនុវត្តសកម្មភាពក្រោយពេលដែលកម្មវិធីGAPបញ្ចប់ យូណេស្កូនឹងធ្វើការអង្កេតជាទៀងទាត់តាមប្រធានបទនីមួយៗ ដើម្បីធ្វើការកំណត់ និងវិភាគបញ្ហា និន្នាការ និងការអភិវឌ្ឍសំខាន់ៗ។ [...]

តាមរយៈការអនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០ ក៏នឹងមានការវាយតម្លៃតាមការកំណត់លើវឌ្ឍនភាពនៃការអនុវត្តក្របខ័ណ្ឌផងដែរ។

(កថាខណ្ឌ ៥.២៨-៥.៣៣ នៃក្របខ័ណ្ឌសម្រាប់អនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០*)

វត្ថុបំណង

ដើម្បីតម្រង់ទិសសកម្មភាពដែលធ្វើឡើងក្នុងផ្នែកសកម្មភាពជាអាទិភាពទាំង ៥ ក្នុងលក្ខណៈជាយុទ្ធសាស្ត្រ និងប្រកបដោយប្រសិទ្ធភាព នឹងមានការវាយតម្លៃជាលក្ខណៈប្រព័ន្ធលើវឌ្ឍនភាពនៃការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០*។

សកម្មភាពដែលលើកស្នើឡើង នៅកម្រិតប្រទេស

ដើម្បីពិនិត្យតាមដានវឌ្ឍនភាព *ESD សម្រាប់ឆ្នាំ ២០៣០* រដ្ឋជាសមាជិកត្រូវបានអញ្ជើញឲ្យ៖

- រៀបចំសូចនាករជាតិ ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃគំនិតផ្តួចផ្តើម *ESD សម្រាប់ឆ្នាំ ២០៣០* ដែលអនុវត្តតាមប្រទេសនីមួយៗ និងត្រូវរួមចំណែកដល់ការរៀបចំកម្មវិធីពិនិត្យតាមដាន និងលទ្ធផលនេះ ESD ប្រកបដោយអត្ថន័យ។
- ពិនិត្យតាមដាន និងវាយតម្លៃជាទៀងទាត់លើវឌ្ឍនភាព ESD នៅកម្រិតប្រទេស ជាពិសេសតាមរយៈការធ្វើការអង្កេត ដើម្បីវាយតម្លៃវឌ្ឍនភាពនៃសកម្មភាពជាអាទិភាពទាំង ៥។
- រាយការណ៍ពីវឌ្ឍនភាពនៃ ESD ជាផ្នែកមួយនៃការពិនិត្យតាមដាន SDG នៅថ្នាក់សកល និងថ្នាក់តំបន់ រួមទាំងការពិនិត្យតាមដានចំណុចដៅ ៤.៧ នៃ SDG ផងដែរ។

សកម្មភាពរបស់យូណេស្កូ

យូណេស្កូ បានធ្វើការវាយតម្លៃតាមការកំណត់លើវឌ្ឍនភាព នៃការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ដោយប្រើប្រាស់ទិន្នន័យ និងព័ត៌មានដែលប្រមូលបាន តាមរយៈសកម្មភាពចំនួន ៤ ដូចខាងក្រោម៖

- ការពិនិត្យតាមដានវឌ្ឍនភាពជារួមនៃ ESD ដែលសម្រេចបានដោយរដ្ឋជាសមាជិក។
- ពិនិត្យតាមដានលើវឌ្ឍនភាពនៃសកម្មភាពជាអាទិភាពទាំង ៥។
- ពិនិត្យតាមដានលើការអនុវត្តសកម្មភាពនៅក្នុងផែនការ តាមរយៈគំនិតផ្តួចផ្តើមផ្តើមនៅតាមប្រទេស ព្រមទាំងគំនិតផ្តួចផ្តើមដទៃទៀត
- ពិនិត្យឡើងវិញលើទិន្នន័យបន្ថែមស្តីពីវឌ្ឍនភាពនៃ ESD។
- យូណេស្កូគ្រោងនឹងធ្វើការវាយតម្លៃចំនួន ២ នៅក្នុងឆ្នាំ ២០២០-២០៣០៖ ការវាយតម្លៃពាក់កណ្តាលអាណត្តិនៅក្នុងឆ្នាំ ២០២៥ និងការវាយតម្លៃចុងក្រោយនៅក្នុងឆ្នាំ ២០៣០។ នៅចន្លោះពេលនេះ និងមានការផ្សព្វផ្សាយរបាយការណ៍ខ្លីៗបន្ថែមទៀត។

TOOL BOX
on.unesco.org/esdtoolbox

សូចនាករគន្លឹះសម្រាប់ពិនិត្យតាមដានវឌ្ឍនភាព ESD សម្រាប់ឆ្នាំ២០៣០

គោលនយោបាយ

កម្រិតនៃការអនុវត្តក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដើម្បីលើកកម្ពស់ ESD។

បរិយាកាសសិក្សា

កម្រិតដែលបរិយាកាសសិក្សាលើកកម្ពស់ ESD និងអភិក្រមទូទាំងស្ថាប័នដែលប្រើប្រាស់ សម្រាប់អនុវត្ត ESD។

ការអប់រំ

កម្រិតនៃការបណ្តុះបណ្តាលដល់អ្នកអប់រំ ដើម្បីអាចបង្រៀនប្រធាន ESD និងប្រើប្រាស់អភិក្រមទូទាំងស្ថាប័នសម្រាប់អនុវត្ត ESD នៅតាមគ្រឹះស្ថានសិក្សា។

យុវជន

កម្រិតនៃការចូលរួមរបស់យុវជននៅក្នុង ESD។

សហគមន៍

កម្រិតនៃការផ្សព្វផ្សាយអំពី ESD នៅតាមសហគមន៍មូលដ្ឋាន។

វឌ្ឍនភាពនៃគំនិតផ្តួចផ្តើមតាមប្រទេស

កម្រិតដែល *ESD សម្រាប់ឆ្នាំ ២០៣០* ត្រូវបានអនុវត្តនៅតាមប្រទេសនានាទូទាំងពិភពលោក។

តារាងទី ១ តាមដាន និងវាយតម្លៃ ESD សម្រាប់ឆ្នាំ ២០៣០

	អ្វី	អ្នកណា
វឌ្ឍនភាពជារួមនៃ ESD	យូណេស្កូក្នុងនាមជាស្ថាប័នទទួលបន្ទុកសូចនាករសកល ៤.៧.១ នៃចំណុចដៅ SDG ៤.៧ នឹងប្រើប្រាស់ទិន្នន័យដែលប្រមូលបាន តាមរយៈដំណើរការរាយការណ៍ពីការអនុវត្តអនុសាសន៍ឆ្នាំ ១៩៧៤ ដើម្បីពិនិត្យតាមដានវឌ្ឍនភាព ESD ដែលសម្រេចបានដោយរដ្ឋជាសមាជិក។	យូណេស្កូ រួមជាមួយនឹងរដ្ឋជាសមាជិក
វឌ្ឍនភាពនៃការអនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០ តាមរយៈ: គំនិតផ្តួចផ្តើមនៅក្នុងប្រទេស	នឹងមានការពិនិត្យតាមដានលើសមិទ្ធផលនៃសកម្មភាពជាអាទិភាពទាំង ៥ ដែលសម្រេចបានដោយគំនិតផ្តួចផ្តើម ESD សម្រាប់ឆ្នាំ ២០៣០។	យូណេស្កូ រួមជាមួយនឹងរដ្ឋជាសមាជិក
វឌ្ឍនភាពនៃការអនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០ តាមរយៈ: សកម្មភាពរបស់ស្ថាប័នជាដៃគូផ្សេងទៀតរបស់ ESD-Net	នឹងមានការពិនិត្យតាមដានសមិទ្ធផលនៃសកម្មភាពជាអាទិភាពទាំង ៥ តាមរយៈការអនុវត្តសកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០* របស់ស្ថាប័នជាដៃគូដទៃទៀតដែលជាសមាជិកនៃបណ្តាញ ESD-Net។	យូណេស្កូ រួមនឹងអង្គការជាដៃគូដទៃទៀតដែលជាសមាជិករបស់ ESD-Net
ព័ត៌មានបរិមាណវិស័យ និងគុណវិស័យបន្ថែមអំពីវឌ្ឍនភាព និងផលជះនៃ ESD	បន្ថែមលើការពិនិត្យតាមដានជាផ្លូវការ យូណេស្កូនឹងអនុវត្តកិច្ចខិតខំប្រឹងប្រែងពិនិត្យតាមដានសំខាន់ៗមួយចំនួន ដើម្បីប្រមូលភស្តុតាង ដោយបង្ហាញពីផលជះនៃ ESD សម្រាប់ឆ្នាំ ២០៣០។	យូណេស្កូ

ដោយរបៀបណា	សូចនាករ
រៀងរាល់ ៤ ឆ្នាំម្តង រដ្ឋជាសមាជិកត្រូវរាយការណ៍ជូនយូណេស្កូអំពីការអនុវត្តអនុសាសន៍ពាក់ព័ន្ធនឹងការអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងកិច្ចសហប្រតិបត្តិការសន្តិភាពជាអន្តរជាតិ និងការអប់រំដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានអនុម័តនៅក្នុងមហាសន្និបាតលើកទី ១៨ របស់យូណេស្កូកាលពីឆ្នាំ ១៩៧៤។ លទ្ធផលរកឃើញដែលបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ឆ្នាំ ១៩៧៤ ផ្តល់នូវព័ត៌មានដ៏សំខាន់ ដែលអាចឲ្យគេដឹងស៊ីជម្រៅអំពីវឌ្ឍនភាពឆ្ពោះទៅសម្រេចចំណុចដៅ ៤.៧ នៃគោលដៅ SDG ទី ៤ ស្តីពីការអប់រំ ដោយមានភាពពាក់ព័ន្ធនឹង ESD ផងដែរ។	សូចនាករសកល ៤.៧.១៖ កម្រិតនៃការបញ្ជ្រាប (i) ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពទៅក្នុងការអប់រំស្តីពីភាពជាប្រជាពលរដ្ឋសកល និង (ii) ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ទៅក្នុង (ក) គោលនយោបាយអប់រំជាតិ (ខ) កម្មវិធីសិក្សា (គ) ការអប់រំគ្រូ និង (ឃ) វង្វាយតម្លៃសិស្ស។
យូណេស្កូនឹងផ្តល់ការគាំទ្រដល់រដ្ឋជាសមាជិកដែលចូលរួមក្នុងការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ដើម្បីកំណត់ចំណុចដៅ និងប្រមូលព័ត៌មាននៅដើមគ្រា ដែលពាក់ព័ន្ធនឹងសកម្មភាពនីមួយៗក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៥ ដែលរដ្ឋជាសមាជិកគ្រោងនឹងចូលរួមចំណែក។ នឹងមានការអញ្ជើញប្រទេសនានាឲ្យចូលរួមក្នុងការអង្កេតដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង ដើម្បីវាស់វែងវឌ្ឍនភាពនៃសកម្មភាពជាអាទិភាពទាំង ៥ ធៀបនឹងទិន្នន័យដើមគ្រាដែលត្រូវបានដាក់ចេញកាលពីដំបូង។ លទ្ធផលនៃការគិតនេះនឹងត្រូវលើកយកមកធ្វើ ការពិភាក្សានៅក្នុងកិច្ចប្រជុំជាមួយដៃគូសកល ដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង។ សម្រាប់ការពិនិត្យឡើងវិញដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង នឹងមានការជួយឲ្យតួអង្គពាក់ព័ន្ធធ្វើការវាយតម្លៃឡើងវិញ និងបង្កើនចំណុចដៅរបស់ខ្លួនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០៣០។	ការអង្កេតដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង នឹងពិនិត្យតាមដានលើវឌ្ឍនភាពនៃសូចនាករមួយក្នុងមួយសកម្មភាពជាអាទិភាព និងនៃសូចនាករមួយដែលវាស់វែងវឌ្ឍនភាពទូទៅនៃការអនុវត្ត ESD សម្រាប់ឆ្នាំ ២០៣០ (សូមមើលបញ្ជីនៅទំព័រទី ៤៩)។
យូណេស្កូនឹងគាំទ្រដល់អង្គការដទៃទៀតដែលជាដៃគូរបស់ ESD-Net ក្នុងការដាក់ចេញចំណុចក្តៅ និងប្រមូលទិន្នន័យដើមគ្រាសម្រាប់សកម្មភាពនីមួយៗក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៥ ដែលពួកគេគ្រោងនឹងរួមចំណែក។ នឹងមានការអញ្ជើញអង្គការជាដៃគូនានាឲ្យចូលរួមក្នុងការអង្កេតដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង ដើម្បីវាស់វែងវឌ្ឍនភាពនៃសកម្មភាពជាអាទិភាពទាំង ៥ ធៀបនឹងទិន្នន័យដើមគ្រា ដែលត្រូវបានដាក់ចេញកាលពីដំបូង។ លទ្ធផលនៃការគិតនេះនឹងត្រូវលើកយកមកធ្វើការពិភាក្សានៅក្នុងកិច្ចប្រជុំជាមួយដៃគូសកល ដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង។ សម្រាប់ការពិនិត្យឡើងវិញដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង នឹងមានការជួយឲ្យតួអង្គពាក់ព័ន្ធធ្វើការវាយតម្លៃឡើងវិញ និងបង្កើនចំណុចដៅរបស់ខ្លួនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០៣០។	ការអង្កេតដែលធ្វើឡើងរៀងរាល់ ២ ឆ្នាំម្តង នឹងពិនិត្យតាមដានលើវឌ្ឍនភាពនៃសូចនាករមួយក្នុងមួយសកម្មភាពជាអាទិភាព និងនៃសូចនាករមួយដែលវាស់វែងវឌ្ឍនភាពទូទៅនៃការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* (សូមមើលបញ្ជីនៅទំព័រទី ៤៩)។
យូណេស្កូ នឹងធ្វើការវិភាគដោយប្រើប្រាស់ភ័ស្តុតាង និងទិន្នន័យដែលមានស្រាប់ ដោយសហការជាមួយនឹងទីភ្នាក់ងារសហប្រជាជាតិ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីប្រមូលព័ត៌មានបន្ថែមដើម្បីយល់ឲ្យបានស៊ីជម្រៅពីវឌ្ឍនភាពនៃ ESD។ ការអង្កេតតាមប្រធានបទនឹងត្រូវធ្វើឡើង ដើម្បីកំណត់ និងវិភាគពីបញ្ហានិន្នាការ និងការអភិវឌ្ឍសំខាន់ៗ ដើម្បីបំពេញបន្ថែមលើការពិនិត្យតាមដានចំណុចដៅ ៤.៧ ដែលត្រូវធ្វើឡើងជាធម្មតា (សូមមើលផ្នែកទី ៤ ស្តីពីការតាមដានបញ្ហា និងនិន្នាការនានា) យូណេស្កូនឹងបន្តពិនិត្យតាមដានផលជះបែបគុណវិស័យនៃ ESD តាមរយៈការប្រមូល និងរំលេចឲ្យឃើញពីសក្ខីកម្ម និងការអនុវត្តល្អៗ	N/A

៤.៧. ការធ្វើផែនការសម្រាប់រយៈពេល ១០ ឆ្នាំទៀត

២០៣០

ការពិនិត្យឡើងវិញចុងក្រោយលើ ESD សម្រាប់ឆ្នាំ ២០៣០

→ ការអង្កេតតាមប្រទេសលើកទី ៥ លើសមិទ្ធផលដែលសម្រេចបានក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងក្នុងគំនិតផ្តួចផ្តើមតាមប្រទេសនានា

២០២៦-២០២៩

ការពង្រឹងការអនុវត្ត

→ ការអង្កេតតាមប្រទេសលើកទី ៣ លើសមិទ្ធផលដែលសម្រេចបានក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងក្នុងគំនិតផ្តួចផ្តើមតាមប្រទេសនានា
→ ការរៀបចំកិច្ចប្រជុំនៃបណ្តាញ ESD-Net ជាសកល
→ កិច្ចពិគ្រោះយោបល់លើកទី ៩ ស្តីពីអនុសាសន៍ឆ្នាំ ១៩៧៤
→ ការអង្កេតតាមប្រទេសលើកទី ៤ លើសមិទ្ធផលដែលសម្រេចបានក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងក្នុងគំនិតផ្តួចផ្តើមតាមប្រទេសនានា
→ ការរៀបចំកិច្ចប្រជុំនៃបណ្តាញ ESD-Net ជាសកល

២០២៥

២០២៥៖ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើ *ESD សម្រាប់ឆ្នាំ ២០៣០*

→ ការរៀបចំកិច្ចប្រជុំនៃបណ្តាញ ESD-Net ជាសកល

២០២២-២០២៤

ការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០*

→ កិច្ចប្រជុំថ្នាក់តំបន់ស្តី ESD សម្រាប់ឆ្នាំ ២០៣០
→ ការអង្កេតតាមប្រទេសលើកទី ១ លើសមិទ្ធផលដែលសម្រេចបានក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងក្នុងគំនិតផ្តួចផ្តើមតាមប្រទេសនានា
→ ការរៀបចំកិច្ចប្រជុំនៃបណ្តាញ ESD-Net ជាសកល
→ កិច្ចពិគ្រោះយោបល់លើកទី ៨ ស្តីពីអនុសាសន៍ឆ្នាំ ១៩៧៤
→ ការអង្កេតតាមប្រទេសលើកទី ២ លើសមិទ្ធផលដែលសម្រេចបានក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងក្នុងគំនិតផ្តួចផ្តើមតាមប្រទេសនានា

២០២០-២០២១

ដំណាក់កាលកសាងមូលដ្ឋាន

→ កិច្ចពិគ្រោះយោបល់លើកទី ៧ ស្តីពីអនុសាសន៍ឆ្នាំ ១៩៧៤
→ កិច្ចប្រជុំអនឡាញថ្នាក់តំបន់ ដើម្បីប្រកាសដាក់ឱ្យអនុវត្តនូវផែនទីបង្ហាញផ្លូវស្តី ESD សម្រាប់ឆ្នាំ ២០៣០ និងការត្រៀមរៀបចំគំនិតផ្តួចផ្តើមនៅតាមប្រទេស
→ ការប្រកាសដាក់ឱ្យអនុវត្តជាកលនូវ ESD សម្រាប់ឆ្នាំ ២០៣០៖ សន្និសីទពិភពលោករបស់យូណេស្កូស្តីពីការអប់រំសម្រាប់អភិវឌ្ឍន៍ដោយចីរភាព (ខែ ឧសភា ឆ្នាំ ២០២១ ទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់)
→ ការកំណត់ពីគំនិតផ្តួចផ្តើម ESD សម្រាប់ឆ្នាំ ២០៣០ នៅតាមប្រទេស
→ ការបង្កើតបណ្តាញសកលនៃ ESD សម្រាប់ឆ្នាំ ២០៣០ (ESD-Net)

ឧបសម្ព័ន្ធ

ក. សង្ខេបមួយទំព័រស្តីពីក្របខ័ណ្ឌការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព សម្រាប់ឆ្នាំ ២០៣០

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព
ឈានទៅសម្រេចគោលដៅ SDG ៖ESD សម្រាប់ឆ្នាំ ២០៣០

កម្មវិធីសកម្មភាពជាសកល (២០១៥-២០១៩) → **ESD សម្រាប់ឆ្នាំ ២០៣០ (២០២០-២០៣០)**

ចក្ខុវិស័យ

ESD សម្រាប់ឆ្នាំ ២០៣០ មានគោលបំណងកសាងពិភពលោកកាន់តែយុត្តិធម៌ និងកាន់តែមានចីរភាពតាមរយៈ ការពង្រឹង ESD និងរួមចំណែកដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំង ១៧

សកម្មភាពជាអាទិភាព

២) ធ្វើឱ្យបរិយាកាសសិក្សាមានការផ្លាស់ប្តូរជាវិជ្ជមាន
៣) កសាងសមត្ថភាពអ្នកអប់រំ
៤) ផ្តល់ភាពអង់អាច និងកៀរគរចលនាយុវជន
៥) ពន្លឿនសកម្មភាពនៅក្នុងមូលដ្ឋាន

គោលដៅជាយុទ្ធសាស្ត្រ

ជំរុញឱ្យ ESD ក្លាយជាធាតុផ្សំដ៏សំខាន់នៃការអប់រំប្រកបដោយគុណភាព និងជាកត្តាគន្លឹះ ដើម្បីជួយដល់គោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំង ១៧ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ ក) ការផ្លាស់ប្តូរនៅកម្រិតបុគ្គលជាវិជ្ជមាន ខ) ការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម និង គ) ការរីកចម្រើនផ្នែកបច្ចេកវិទ្យា

ក្រុមគោលដៅ

អ្នកធ្វើគោលនយោបាយ អ្នកដឹកនាំស្ថាប័ន អ្នកសិក្សា មាតាបិតា អ្នកអប់រំយុវជន និងសហគមន៍

សកម្មភាពដែលអនុវត្តដោយរដ្ឋជាសមាជិក៖ គំនិតផ្តួចផ្តើម ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះនៅកម្រិតប្រទេស

១ ជំរុញគោលនយោបាយ
បញ្ចូល ESD ទៅក្នុងគោលនយោបាយអប់រំ និងការអភិវឌ្ឍដោយចីរភាព នៅកម្រិតសកល តំបន់ និងជាតិ

២ បរិយាកាសសិក្សា
ជំរុញឱ្យមានការប្រើប្រាស់គោលវិធីទូទាំងស្ថាប័ន

៣ អ្នកអប់រំ
ផ្តល់ឱកាសអភិវឌ្ឍន៍សមត្ថភាព

៤ យុវជន
ផ្តល់ឱកាស ដើម្បីឱ្យមានការចូលរួមពីយុវជន

៥ សហគមន៍
លើកកម្ពស់ភាពអង់អាចរបស់សហគមន៍មូលដ្ឋាន ឱ្យក្លាយជាវេទិកា "គន្លឹះ" សម្រាប់អនុវត្តរាល់សកម្មភាពជាអាទិភាពទាំងអស់

គំនិតផ្តួចផ្តើមនៅកម្រិតប្រទេសស្តីពី ESD ដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ	បណ្តាញដែលមានការចូលរួមពីគ្រប់ដៃគូ	ការតាមដាន និងវាយតម្លៃ	ការអប់រំផ្សព្វផ្សាយ ដើម្បីឱ្យមានការអនុវត្តសកម្មភាព	ការអនុវត្ត និងការកៀរគរធនធានផ្អែកតាមភស្តុតាង
គោលការណ៍ណែនាំជាបទដ្ឋាន និងគាំទ្រនៅកម្រិតប្រទេស	បង្កើនជាវេទិកាទៀងទាត់ ដើម្បីជួបប្រជុំ និងផ្លាស់ប្តូរបទពិសោធន៍	តាមដានសមិទ្ធផលនៅក្នុងសកម្មភាពជាអាទិភាពទាំង ៥ និងអនុវត្តកម្មវិធីស្របតាមការពិនិត្យតាមដានចំណុចដៅ ៤.៧ របស់ SDG	រៀបចំកម្មវិធីពិសេស ដើម្បីផ្តល់ព័ត៌មានអំពី SDG និងតួនាទីរបស់ការអប់រំ	ពិនិត្យតាមដានបញ្ហា និងនិន្នាការថ្មីៗ និងកៀរគរធនធាន ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ESD

ការគាំទ្ររបស់យូណេស្កូដល់រដ្ឋជាសមាជិក

ខ. ក្របខ័ណ្ឌសម្រាប់អនុវត្តការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD ក្រោយ ឆ្នាំ ២០១៩៖ ESD សម្រាប់ឆ្នាំ ២០៣០

ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព៖ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព (*ESD សម្រាប់ឆ្នាំ ២០៣០*)

ក្របខ័ណ្ឌសម្រាប់អនុវត្តការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព ក្រោយឆ្នាំ ២០១៩។

១. ហេតុអ្វីដែលត្រូវប្រើប្រាស់ក្របខ័ណ្ឌនេះ?

១.១ កាលពីឆ្នាំ ១៩៩២ សន្និសីទអង្គការសហប្រជាជាតិស្ដីពីបរិស្ថាននិងការអភិវឌ្ឍ ដែលធ្វើឡើងនៅទីក្រុងរីយ៉ូឌឺហ្សានីរ៉ូ ទទួលស្គាល់នៅក្នុងក្របខ័ណ្ឌសកម្មភាពត្រង់របៀបវារៈទី ២១ របស់ខ្លួន ពីតួនាទីដ៏សំខាន់នៃការអប់រំ ក្នុងអន្តរកាលឆ្ពោះទៅសម្រេចការអភិវឌ្ឍដោយចីរភាព។ ក្នុងឆ្នាំ ២០០២ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសរយៈពេល ១០ ឆ្នាំ ចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១៤ ថាជាទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (DESD) ដោយបានអំពាវនាវឱ្យរដ្ឋាភិបាលបញ្ចូលគោលការណ៍ចីរភាពទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំរបស់ខ្លួន។ យូណេស្កូ ដែលត្រូវបានចាត់តាំងឱ្យបំពេញតួនាទីជាអ្នកគ្រប់គ្រងកិច្ចការ ពាក់ព័ន្ធជំពូកទី ៣៦ ស្ដីពីការអប់រំ ត្រង់របៀបវារៈទី ២១ បានក្លាយជាទីភ្នាក់ងារនាំមុខ និងបានទទួលការចាត់តាំងពីអង្គការសហប្រជាជាតិឱ្យទទួលខុសត្រូវលើការងារនេះ។

១.២ ក្នុងឆ្នាំ២០១៤ទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព បានបញ្ចប់ ហើយជាការអនុវត្តបន្ត យូណេស្កូបានប្រកាសអនុវត្ត[៨] កម្មវិធីសកម្មភាពជាសកល (GAP) ស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព សម្រាប់ដំណាក់កាលដំបូងដែលមានរយៈពេល ៥ ឆ្នាំ (២០១៥ - ២០១៩) នៅក្នុងសន្និសីទពិភពលោក ស្ដីពីការអប់រំប្រកបដោយចីរភាពដែលយូណេស្កូរៀបចំធ្វើឡើងនៅទីក្រុងអៃជី-ណាហ្គូយ៉ា ប្រទេសជប៉ុន។ ស្របពេលជាមួយគ្នានេះដែរ សេចក្ដីប្រកាសអៃជី-ណាហ្គូយ៉ា ស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍចីរភាព ត្រូវបានអនុម័តដោយទទួលស្គាល់ពីតួនាទីនៃរបៀបវារៈ ESD ក្នុងការលើកកម្ពស់ភាពក្លាហានរបស់អ្នកសិក្សា និងសង្គមដែលពួកគេរស់នៅ។[៩] ជាការបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងដែលសម្រេចបាននៅក្នុងទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ជុំវិញការស្វែងរកការគាំទ្រ និងការបង្កើនការយល់ដឹងកម្មវិធីសកម្មភាពសកលដែលត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិ[១០] ទទួលស្គាល់ថាជាកម្មវិធីផ្លូវការបន្តពីកម្មវិធីនេះ ESD ផ្ដោតការយកចិត្តទុកដាក់លើការពង្រីកសកម្មភាពដែលអនុវត្តទៅតាមមូលដ្ឋានផ្ទាល់។ ការលើកកម្ពស់គោលនយោបាយ ការនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមាននៃបរិយាកាសរៀនសូត្រ និងបណ្ដុះបណ្ដាល ការកសាងសមត្ថភាពអ្នកអប់រំ និងអ្នកបណ្ដុះបណ្ដាល ការកៀរគរចលនាយុវជន និងការពន្លឿនដំណោះស្រាយប្រកបដោយចីរភាពនៅថ្នាក់មូលដ្ឋានត្រូវបានចាត់ទុកថាជាសកម្មភាពអាទិភាពចំនួន ៥ ដែលត្រូវអនុវត្ត។

១.៣ វដ្ដរយៈពេល ៥ ឆ្នាំនៃកម្មវិធី GAP បានបញ្ចប់នៅក្នុងឆ្នាំ ២០១៩ ហើយដើម្បីត្រៀមសម្រាប់ស្ថានភាពក្រោយកម្មវិធី GAP ដែលរួមចំណែកដល់របៀបវារៈឆ្នាំ ២០៣០ ទើបមានការរៀបចំក្របខ័ណ្ឌនេះឡើង។

២. តើក្របខ័ណ្ឌនេះត្រូវបានរៀបចំដោយរបៀបណា?

២.១ **ការវាយតម្លៃលើកម្មវិធី GAP៖** ការវាយតម្លៃលើការអនុវត្ត GAP ពីឆ្នាំ២០១៥-២០១៨[១១] បានបង្ហាញថាមានការសម្រេចបាននូវវឌ្ឍនភាពល្អៗជាច្រើននៅក្នុងការអនុវត្តគោលដៅ ដែលត្រូវបានដាក់ចេញដោយដៃគូសំខាន់ៗរបស់កម្មវិធី GAP។[១២] ប៉ុន្តែ

[៨] ដូចដែលបានទទួលការគាំទ្រនៅក្នុងសម័យប្រជុំលើកទី ៣៧ នៃសន្និសីទរបស់យូណេស្កូ (៣៧C/សេចក្ដីសម្រេចលេខ ១២)។

[៩] សេចក្ដីប្រកាសអៃជី-ណាហ្គូយ៉ា ស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព លើកឡើងថា ESD អាចជួយឱ្យអ្នកសិក្សានាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមានសម្រាប់ពួកគេផ្ទាល់ និងសង្គមដែលពួកគេរស់នៅ តាមរយៈការអភិវឌ្ឍជំនាញ បំណិន ឥរិយាបថ សមត្ថភាព និងគុណតម្លៃដែលចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពជាពលរដ្ឋសកល និងចំពោះបញ្ហាប្រឈមនៅតាមមូលដ្ឋានរបស់ពួកគេ ទាំងនាពេលបច្ចុប្បន្ន ទាំងនាពេលអនាគត ដូចជា បំណិនត្រិះរិះពិចារណាបែបល្បិតល្អន់ និងបំណិនត្រិះរិះពិចារណា ជាប្រព័ន្ធ ការដោះស្រាយបញ្ហាបែបវិភាគ ភាពច្នៃប្រឌិត ការធ្វើការសហការគ្នា និងការធ្វើការសម្រេចចិត្ត នៅពេលដែលប្រឈមនឹងភាពមិនប្រាកដប្រជា និងការយល់ពីភាពប្រទាក់ក្រឡាគ្នានៃបញ្ហាប្រឈមនៅក្នុងសកលលោក ក៏ដូចជាការទទួលខុសត្រូវដែលកើតចេញពីការយល់ដឹងទាំងនេះ។

[១០] ទៅដប់សេចក្ដីសម្រេចលេខ A/RES/69/211។

[១១] ការវាយតម្លៃចុងក្រោយលើការអនុវត្ត GAP នឹងត្រូវធ្វើឡើងឱ្យបានមុនចុងឆ្នាំ ២០១៩។ ប្រសិនបើលទ្ធផលនៃការវាយតម្លៃចុងក្រោយ ត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងក្របខ័ណ្ឌក្រោយ GAP នោះនឹងមានគម្លាតរយៈពេលប្រហែលជាមួយឆ្នាំ ទម្រាំដល់ពេលដែលក្របខ័ណ្ឌក្រោយ GAP ថ្មីត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដែលនេះទាមទារឱ្យមានដំណើរការស្ថាប័នមួយដែលត្រូវមានការចូលរួមពីយន្តការអភិបាលកិច្ចរបស់យូណេស្កូ និងអង្គការសហប្រជាជាតិ។ ដើម្បីចៀសវាងគម្លាតនៅក្នុងការអនុវត្តបែបនេះនោះ និងដោយសារតែការវាយតម្លៃពាក់កណ្ដាលអាណត្តិបង្ហាញថា វឌ្ឍនភាពដែលសម្រេចបាននឹងមិនដើរថយក្រោយទៅវិញ ទើបដំណើរការរៀបចំក្របខ័ណ្ឌក្រោយ GAP នេះ ត្រូវបានធ្វើឡើង។ ដំណើរការនៅកម្រិតខ្ពស់នេះបានទទួលការគាំទ្រពី 204 EX/សេចក្ដីសម្រេចលេខ ២៨ នៃក្រុមប្រឹក្សាប្រតិបត្តិរបស់យូណេស្កូ ដែលអំពាវនាវ "ឱ្យមានការតាមដានដោយរលូនចំពោះកម្មវិធីសកម្មភាពសកល និងការបន្តតួនាទីរបស់យូណេស្កូក្នុងការដឹកនាំរបៀបវារៈ ESD ច្រើនឆ្នាំ ២០១៩"។

[១២] ការអង្កេតលើកម្មវិធី GAP ២០១៨ https://en.unesco.org/themes/education-sustainable-development។ បើតាមការអង្កេតលើដៃគូសំខាន់ៗរបស់កម្មវិធី GAP (ឆ្នាំ ២០១៥ -២០១៨) មានការប៉ាន់ប្រមាណថាដៃគូរបស់ GAP និងបណ្ដាដៃគូបន្តបន្ទាប់របស់ពួកគេ បានគាំទ្រដល់ការរៀបចំគោលនយោបាយយុទ្ធសាស្ត្រខេត្តជាង ៩០០ ខណៈពេលដែលកម្មវិធីជាង ១.៤០០ ត្រូវបានរៀបចំ និងអនុវត្ត ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយរបស់ប្រទេសជុំវិញរបៀបវារៈESD។មានសាលារៀនប្រមាណ១៥១.០០០កន្លែងនិងសិស្ស២៦លាននាក់ត្រូវបានប៉ាន់ប្រមាណថាបានទទួលការគាំទ្រពីដៃគូនានារួមជាមួយនឹងអ្នកអប់រំចំនួន២លាននាក់ និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូចំនួន ៤៨.៤០០ កន្លែង។ ដៃគូទាំងនេះក៏បានផ្ដល់ការគាំទ្រដល់យុវជនឈានមុខប្រមាណ ៣,៤ លាននាក់ និងបានផ្ដល់ការបណ្ដុះបណ្ដាលដល់យុវជនចំនួន ៧៦២.០០ នាក់ ដើម្បីធ្វើជាគ្រូបង្គោល។ ចុងក្រោយមានការព្យាករថា មានអង្គការសង្គមស៊ីវិលជាង ៥៦០០ អង្គការ បានអនុវត្តសកម្មភាព ESD ហើយមានសកម្មភាព ESD នៅមូលដ្ឋានជាង ២៣០០ ដែលត្រូវបានរៀបចំឡើង។

នៅក្នុងកិច្ចពិគ្រោះយោបល់បន្ថែមដែលធ្វើឡើងជាមួយនឹងដៃគូសំខាន់ៗរបស់កម្មវិធី GAP និងអ្នកពាក់ព័ន្ធដទៃទៀត មានការលើកឡើងពីភាពចាំបាច់ដើម្បីបង្កើនភាពប្រទាក់ក្រឡាគ្នារវាងដៃគូនានា ដែលធ្វើការងារផ្តោតលើសកម្មភាពអាទិភាពផ្សេងៗគ្នា។ ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្តដែលធ្វើឡើងផ្ទៃក្នុង ក៏មានការលើកឡើងផងដែរថា កន្លងមកនៅមិនទាន់មានការផ្សព្វផ្សាយឱ្យបានគ្រប់គ្រាន់ពីការចូលរួមសហការរបស់រដ្ឋាភិបាលនៅឡើយ។

២.២ **សន្និសីទជាសេរី៖** ដើម្បីកំណត់ពីបញ្ហា និងនិន្នាការនានាដែលចាំបាច់ត្រូវធ្វើការពិចារណា និងធ្វើបច្ចុប្បន្នភាពនៅក្នុងក្របខ័ណ្ឌក្រោយកម្មវិធី GAP យូណេស្កូបានគ្រោងនឹងរៀបចំសន្និសីទប្រមូលគំនិតចំនួន ៤ ជាមួយនឹងអ្នកជំនាញ និងអ្នកពាក់ព័ន្ធជាង ២៥០ នាក់។ សន្និសីទទាំងនេះត្រូវបានរៀបចំឡើងនៅក្នុងប្រទេសប្រេស៊ីល អាល្លឺម៉ង់ ជប៉ុន និងអាហ្វ្រិកខាងត្បូង ដែលចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ដែលក្នុងនោះមានការសម្ភាសន៍ និងការជួបជាមួយនឹងតួអង្គពាក់ព័ន្ធនានា និងស្វែងយល់ពីការអនុវត្តរបស់ពួកគេនៅនឹងមូលដ្ឋានផ្ទាល់។ ការពិភាក្សាទាំងនេះការផ្តោតលើអ្វីដែលធ្វើឱ្យមនុស្សដែលរស់នៅក្នុងបរិបទផ្សេងៗគ្នាត្រូវធ្វើសកម្មភាពដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព និងបានផ្តល់នូវការយល់ឃើញស៊ីជម្រៅអំពីការសង្កេតឃើញថានានា ដូចដែលត្រូវបានរៀបរាប់បង្ហាញនៅក្នុងផ្នែកឆ្លុះបញ្ចាំងចាំបាច់នៃក្របខ័ណ្ឌនេះ។

២.៣ **ដាក់ដំណើរការពិគ្រោះយោបល់៖** ផ្អែកតាមការសង្កេតទទួលបានពីដំណើរការខាងលើ និងការវាយតម្លៃផ្ទៃក្នុងជាច្រើនដែលធ្វើឡើងលើសកម្មភាព ESD ដែលយូណេស្កូកំពុងអនុវត្ត យូណេស្កូបានរៀបចំពង្រាងសូន្យនៃក្របខ័ណ្ឌនេះឡើង។ កំណែដំបូងត្រូវបានផ្ញើជូនដៃគូសំខាន់ៗនៃកម្មវិធី GAP ដើម្បីពិនិត្យក្នុងកិច្ចប្រជុំមួយ ដែលរៀបចំឡើងដោយយូណេស្កូ ក្នុងខែ មេសា ឆ្នាំ ២០១៨ នៅទីក្រុងសាន់ជូសេ ប្រទេសកូស្តារីកា។ កំណែទី ២ ត្រូវបានដាក់ជូនកិច្ចប្រជុំពិគ្រោះយោបល់បច្ចេកទេសជាមួយនឹងតំណាងរដ្ឋាភិបាល និងអ្នកជំនាញមកពីរដ្ឋជាសមាជិក ចំនួន ១១៦ ដែលធ្វើឡើងនៅក្នុងខែ កក្កដា ឆ្នាំ ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ។ ការពិគ្រោះយោបល់តាមប្រព័ន្ធអនឡាញជាមួយនឹងទីភ្នាក់ងារសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត ក៏ដូចជាការពិគ្រោះយោបល់តាមអនឡាញជាមួយសាធារណជនទូទៅ រួមទាំងតួអង្គពាក់ព័ន្ធជាច្រើនត្រូវបានធ្វើឡើងរហូតដល់ចុងឆ្នាំ ២០១៨។

៣. បរិបទសំខាន់ៗ

៣.១ **ទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (DESD) និងកម្មវិធីសកម្មភាពសកល (GAP)៖** DESD មានគោលបំណងបញ្ចូលគោលការណ៍ និងការអនុវត្តជុំវិញការអភិវឌ្ឍដោយចីរភាព ទៅក្នុងគ្រប់ទដ្ឋិភាពទាំងអស់នៃការអប់រំ និងការរៀនសូត្រ។ ការរួមចំណែកចម្បងជាងគេនៃកម្មវិធីនេះ គឺការបង្កើនការយល់ដឹង ដែលជួយនាំឱ្យមានការអនុវត្តសកម្មភាព និងគម្រោងដែលគួរឱ្យចាប់អារម្មណ៍។ ការវាយតម្លៃលើ ESD ផ្តល់ជាអនុសាសន៍ថា ចាំបាច់ត្រូវមានការគាំទ្រផ្នែកស្ថាប័ន ដើម្បីពង្រីកវិសាលភាព និងបន្តការអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗទាំងនេះ។

៣.២ កម្មវិធី GAP (២០១៥-២០១៩) បានជួយបំពេញចំណុចខ្វះខាតទាំងនេះ។មានការកំណត់តួអង្គដែលធ្វើការងារពាក់ព័ន្ធនឹងគោលនយោបាយ គ្រឹះស្ថានអប់រំបណ្តុះបណ្តាល អ្នកអប់រំ យុវជន អាជ្ញាធរមូលដ្ឋាន ថាជាដៃគូសំខាន់ៗដែលត្រូវចូលរួមអនុវត្តសកម្មភាពជាអាទិភាពមួយក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ៥៖ ជំរុញការលើកកម្ពស់គោលនយោបាយ, នាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងបរិយាកាសរៀនសូត្រ និងបណ្តុះបណ្តាល, កសាងសមត្ថភាពអ្នកអប់រំ និងវគ្គបណ្តុះបណ្តាល,លើកកម្ពស់សមត្ថភាពក្លាហាន និងការកៀរគរចលនាយុវជន, ព្រមទាំងពន្លឿនដំណោះស្រាយប្រកបដោយចីរភាពនៅនឹងមូលដ្ឋាន។ ការចងក្រងបណ្តាញការងារតាមវិស័យសម្រាប់តួអង្គពាក់ព័ន្ធទាំងនេះបានទទួលការគាំទ្រពីដៃគូចំនួន ៥ ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្នែកសកម្មភាពទាំង ៥ នេះ។

៣.៣ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិលើការអនុវត្ត GAP កាលពីឆ្នាំ ២០១៧ បានរាយការណ៍ពីការអនុវត្តល្អដែលដៃគូសំខាន់ៗសម្រេចបាន ដើម្បីពង្រីកវិសាលភាពចំណុចដៅរបស់ពួកគេ។ យន្តការចងក្រងបណ្តាញក៏ត្រូវបានរកឃើញថាមានប្រយោជន៍សម្រាប់ការរៀនសូត្រពីគ្នាទៅវិញទៅមកផងដែរ ប៉ុន្តែមិនសូវជាមានប្រយោជន៍សម្រាប់ការរៀបចំផែនការរួមគ្នាអភិវឌ្ឍសម្រាប់ និងរៀបចំគម្រោងរួមគ្នានោះឡើង។ មេរៀនដែលទទួលបានផ្សេងទៀត រួមមានកិច្ចខិតខំប្រឹងប្រែងចងក្រងបណ្តាញ ត្រូវធ្វើឡើងជាមួយនឹងសកម្មភាពកម្មវិធីជាក់លាក់ ដែលប្រមូលផ្តុំដៃគូឱ្យមកជុំគ្នា ហើយដៃគូមកពីតាមវិស័យនានា គួរសហការគ្នាកាន់តែស្អិតរមួតបន្ថែមទៀត ក្នុងការអនុវត្តសកម្មភាពជាអាទិភាពទាំងនេះ។

៣.៤ លើសពីនេះ បើទោះជាការតាក់តែងគោលនយោបាយ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាអាទិភាព ហើយអ្នកធ្វើគោលនយោបាយបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត GAP តាមរយៈការចូលរួមនៅក្នុងបណ្តាញដៃគូផ្នែកធ្វើគោលនយោបាយក៏ដោយ ការនាំរបស់រដ្ឋាភិបាលពុំត្រូវបានស្តែងចេញឱ្យឃើញច្បាស់នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃការអនុវត្ត GAP នោះឡើយ។មូលហេតុមួយគឺដោយសារតែការពិនិត្យតាមដានជាសកលផ្តោតសំខាន់តែលើសកម្មភាពដែលត្រូវបានអនុវត្តនៅមូលដ្ឋានផ្ទាល់ ដែលពុំបានបែងចែកទៅតាមប្រភេទតួអង្គពាក់ព័ន្ធនោះឡើយ។

៣.៥ គួរឱ្យសោកស្តាយដែលទិន្នន័យជាក់ស្តែងបង្ហាញថា រដ្ឋាភិបាលពិតជាកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លុះបញ្ចាំងគោលការណ៍ចីរភាពនៅក្នុងគោលនយោបាយ។ ឧទាហរណ៍ បើតាមការអង្កេតដែលយូណេស្កូធ្វើឡើងកាលពីឆ្នាំ ២០១៦[១៣] រដ្ឋជាសមាជិកដែលឆ្លើយតបចំពោះការអង្កេតនេះ ៩១% បានលើកឡើងថា បានបង្កើនការយកចិត្តទុកដាក់លើការបញ្ចូល ESD ទៅក្នុងគោលនយោបាយ។ ដូច្នេះនៅក្នុងក្របខ័ណ្ឌក្រោម GAP ចាំបាច់ដែលត្រូវមានការពិនិត្យតាមដាន និងរៀបចំរបាយការណ៍អំពីការដឹកនាំដែលធ្វើឡើងដោយតួអង្គរដ្ឋាភិបាល។

៣.៦ **SDG៖** កាលពីឆ្នាំ ២០១៥ សហគមន៍សកលបានប្រកាសដាក់ឱ្យអនុវត្តនូវគោលដៅអភិវឌ្ឍន៍ចីរភាព (SDG) ចំនួន ១៧ ដើម្បីឆ្លើយតបចំពោះបញ្ហាដែលពាក់ព័ន្ធនឹងភាពក្រីក្រ គ្រោះអត់ឃ្លាន សុខភាព ការអប់រំ ថាមពល ការងារ ឧស្សាហកម្ម វិសមភាព ទីក្រុង ការប្រើប្រាស់ អាកាសធាតុ ជីវិតក្នុងសមុទ្រ ប្រព័ន្ធអេកូឡូស៊ី សន្តិភាព និងភាពជាដៃគូ។ ការសម្រេចគោលដៅនេះទាមទារឱ្យមានការផ្លាស់ប្តូររបៀបដែលយើងរស់នៅ របៀបដែលយើងគិត និងរបៀបដែលយើងធ្វើសកម្មភាព។ លើសពីនេះ ក៏ត្រូវបង្កើនការយកចិត្តទុកដាក់ដល់តួនាទីរបស់ការអប់រំក្នុងការសម្រេចគោលដៅ SDG ទាំង ១៧ នេះផងដែរ។

៣.៧ ESD បានជំរុញឱ្យមានការឆ្លុះបញ្ចាំងពីគោលការណ៍ចីរភាពក្នុងគោលនយោបាយអប់រំ កម្មវិធីសិក្សា ការបណ្តុះបណ្តាល និងការអនុវត្ត ដែលជាមធ្យោបាយមួយសម្រាប់លើកកម្ពស់ភាពអង់អាច ក្លាហានឱ្យបុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងសំខាន់ៗមួយចំនួន ព្រោះថាបើទោះជាមានការតស៊ូមតិ ដើម្បីជំរុញឱ្យមានការប្រើប្រាស់អភិក្រមគ្រប់ជ្រុងជ្រោយទូទាំងប្រព័ន្ធក៏ដោយ ប៉ុន្តែនៅពេលដែលនិយាយពីការអនុវត្តវិញ គេច្រើនតែចាត់ទុកថាESDថាជាប្រធានបទមួយទៅវិញ។ ការអនុវត្តបែបនេះចាំបាច់ត្រូវតែផ្លាស់ប្តូរ ហើយគេគួរចាត់ទុក ESD មិនត្រឹមតែជាប្រធានបទប៉ុណ្ណោះទេ ប៉ុន្តែតែជាអ្វីដែលត្រូវផ្តួចផ្តើមអនុវត្តនៅកម្រិតប្រព័ន្ធ ជាផ្នែកមួយនៃ SDG ទី ៤ ផ្តោតលើការអប់រំនិយាយជាទូទៅ និងនិយាយដោយឡែកចំណុចដៅ ៤.៧។

៣.៨ ESD និងការអប់រំភាពជាប្រជាពលរដ្ឋសកល (GCED) គឺជាស្នូលនៃចំណុចដៅ ៤.៧ នៃ SDG ទី ៤ ដែលមានគោលបំណងធ្វើយ៉ាងណាឱ្យអ្នកសិក្សាគ្រប់រូបទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព ជាអាទិ៍តាមរយៈការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព ព្រមទាំងរបៀបផែននៃការរស់នៅប្រកបដោយចីរភាព សិទ្ធិមនុស្ស សមត្ថភាព សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌ សន្តិភាព និងអហិង្សា ភាពជាប្រជាពលរដ្ឋសកល និងការយល់ពីភាពចម្រុះនៃវប្បធម៌ និងការរួមចំណែករបស់វប្បធម៌ដល់ការអភិវឌ្ឍដោយចីរភាព។

៣.៩ SDG គឺជាឱកាសដ៏វិសេសវិសាល សម្រាប់ការពង្រឹងការយល់ដឹងរបស់យើងអំពី ESD។ សេចក្តីសម្រេចលេខ ៧២/២២២[១៤] នៃមហាសន្និបាតអង្គការសហប្រជាជាតិ ចាត់ទុក ESD ថាជាធាតុផ្សំមួយដ៏សំខាន់នៃគោលដៅ SDG ពីការអប់រំ និងជា "សមាសធាតុដ៏សំខាន់ ដើម្បីជួយឱ្យមានការសម្រេច SDG ទាំងអស់ផ្សេងទៀត"។ SDG ទាំង ១៧ គ្របដណ្តប់លើបញ្ហាប្រឈមសំខាន់ៗពាក់ព័ន្ធបរិស្ថាន (ឧទាហរណ៍ ការប្រែប្រួលអាកាសធាតុ ទឹក សមុទ្រ និងដីជាដើម) ក៏ដូចជាបញ្ហាគន្លឹះមួយចំនួន ដែលចាំបាច់ត្រូវយកទៅធ្វើការពិចារណានៅក្នុងការជជែកពិភាក្សាអំពីការអភិវឌ្ឍ ដូចជា ភាពក្រីក្រ សមភាពយេនឌ័រ[១៥] និងសមធម៌[១៦] ជាដើម។

៣.១០ ការរិះគន់ដែលលើកឡើងថា ESD "ពុំមានភាពច្បាស់លាស់" ដែលមួយផ្នែកដែលកើតឡើងដោយសារតែការយល់ឃើញទូលំទូលាយ បែបបរិយាប័ន្ន និងការប្រែប្រួលមិនចេះចប់នៃបញ្ហាចីរភាព គឺជាអ្វីដែលគេអាចឆ្លើយតបកាន់តែជាក់លាក់នៅពេលដែលវិស័យនោះត្រូវបានផ្សារភ្ជាប់ជាមួយនឹង SDG។ ក្នុងចំណោម SDG ទាំង ១៧ គេអាចពិចារណាចាត់អាទិភាពទៅតាមតម្រូវការនៅក្នុងប្រទេសនិងនៅមូលដ្ឋាន។ឧទាហរណ៍ ការប្រែប្រួលអាកាសធាតុនៅតែជាផ្នែកមួយ ក្នុងចំណោមផ្នែកដែលត្រូវផ្តោតការយកចិត្តទុកដាក់សំខាន់ៗ។ESDក៏ឆ្លើយតបចំពោះភាពប្រទាក់ក្រឡាគ្នានៃ SDG ដែលកន្លងមកត្រូវបានគេចាត់ទុកថាជាផ្នែកដ៏សំខាន់ ដើម្បីសម្រេចបាននូវវឌ្ឍនភាពពិតប្រាកដឆ្ពោះទៅសម្រេចការអភិវឌ្ឍដោយចីរភាព។ ការផ្គូបកម្លាំងគ្នារវាង ESD និង SDG មិនត្រឹមតែជារឿងដ៏ចាំបាច់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាដំណោះស្រាយឈ្នះ-ឈ្នះសម្រាប់វិស័យការងារទាំងពីរផងដែរ។

---

[១៣] ជាផ្នែកមួយនៃកិច្ចពិគ្រោះយោបល់លើកទី ៦ លើអនុសាសន៍របស់យូណេស្កូ ឆ្នាំ ១៩៧៤ ពាក់ព័ន្ធនឹងការអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងជាអន្តរជាតិ កិច្ចសហប្រតិបត្តិការ សន្តិភាព និងការអប់រំពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសិទ្ធិជាមូលដ្ឋានដែលបញ្ចូលសំណួរអំពី ESD។ ឧបករណ៍អង្កេតដែលត្រូវបានប្រើប្រាស់សម្រាប់ពិនិត្យតាមដានអនុសាសន៍ឆ្នាំ ១៩៧៤ ក៏ជាឧបករណ៍អង្កេតដែលត្រូវបានធ្វើឡើងសម្រាប់ពិនិត្យតាមដានចំណុចដៅ ៤.៧ នៃ SDG ទី ៤ ដែលក្នុងនោះ ESD ក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ។

[១៤] ESD ក៏ជាផ្នែកមួយនៃកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពផងដែរ ដូចជា អនុសញ្ញា Rio ទាំង ៣ (ស្តីពីការប្រែប្រួលអាកាសធាតុ ជីវចម្រុះ និងទីវាលហោឋាន) កិច្ចព្រមព្រៀងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ក្របខ័ណ្ឌសិនដៃសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងក្របខ័ណ្ឌកម្មវិធីស្តីពីការប្រើប្រាស់និងផលិតកម្មប្រកបដោយចីរភាពរយៈពេល ១០ ឆ្នាំ ២០១២ - ២០២១។ល។

[១៥] ឧទាហរណ៍ ESD គឺជាឧបករណ៍ ដើម្បីសម្រេចគោលដៅ SDG ទាំងអស់ ហើយ SDG នីមួយៗសុទ្ធតែមានបញ្ហាប្រឈមរៀងៗខ្លួន។ ESD ប្រើប្រាស់អភិក្រមបែបប្រព័ន្ធ និងប្រើប្រាស់ជំនាញចម្រុះ ដើម្បីឱ្យគេអាចផ្សារភ្ជាប់ទំនាក់ទំនងរវាងសំណួរស្តីពីសមភាពយេនឌ័រចិជាមួយនឹងបញ្ហានានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។ ឧទាហរណ៍ អ្នកដែលមានយេនឌ័រផ្សេងគ្នា ងាយទទួលរងគ្រោះថ្នាក់ដោយសារការប្រែប្រួលអាកាសធាតុខុសៗគ្នា។ នៅពេលដែលគ្រោះមហន្តរាយកើតមានឡើង ស្ត្រីដែលបាត់បង់ជីវិតមានចំនួនច្រើនជាងបុរស ដោយសារតែវិធានក្នុងសង្គម ឧទាហរណ៍ពេលដែលមានគ្រោះទឹកជំនន់កើតមានឡើង ជារឿយៗស្ត្រីមិនចេះហែលទឹកឡើយ និងមានកត្តាមួយចំនួនដែលរឹតត្បិតធ្វើឱ្យពួកគេពុំអាចផ្លាស់ទីបាន ពេលកំពុងជួបនឹងហានិភ័យ។ ដូច្នេះ ការផ្តល់អាទិភាពឱ្យស្ត្រីទទួលបាន ESD គួរចាត់ទុកថាជាអាទិភាព។ ក្នុងន័យនេះ ESD ជំរុញសមភាពយេនឌ័រ និងកសាងឱកាស ក៏ដូចជាផ្តល់នូវលក្ខខណ្ឌ និងយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ភាពក្លាហានរបស់ស្ត្រី។

[១៦] សូមកត់សម្គាល់ ទស្សនទានអភិវឌ្ឍន៍ដោយចីរភាព និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព រួមមានបញ្ហាស្មុគស្មាញ និងការយល់ឃើញខុសៗគ្នាជាច្រើន ដែលអាចពុំត្រូវបានឆ្លុះបញ្ចាំងពេញលេញនៅក្នុង SDG។

៤. ការឆ្លុះបញ្ចាំងដែលចាំបាច់

៤.១ **សកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន៖** របៀបលើកទឹកចិត្តឱ្យអ្នកសិក្សាធ្វើសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានដើម្បីចីរភាព បានក្លាយជាការងារចាំបាច់ដ៏ធំមួយសម្រាប់ ESD។ សិក្ខាសាលាដែលធ្វើឡើងជាស៊េរី ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ នៅជុំវិញពិភពលោកសម្រាប់រៀបចំឯកសារនេះ បានផ្តល់នូវព័ត៌មានស៊ីជម្រៅសំខាន់ៗមួយចំនួនអំពីរបៀបដែលសកម្មភាពនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននេះត្រូវបានធ្វើឡើង។

៤.២ ទី ១ ការផ្លាស់ប្តូរជាវិជ្ជមានការទាមទារឱ្យមានការរំខានក្នុងកម្រិតមួយចំនួន ដែលក្នុងនោះមនុស្សត្រូវត្រៀមខ្លួនឈានជើងចេញទៅខាងក្រៅស្ថានភាពបច្ចុប្បន្នរបស់ពួកគេឬនិយាយម្យ៉ាងទៀតជារបៀបគិត របៀបធ្វើឥរិយាបថ ឬរបៀបរស់នៅតាមបែបធម្មតា។វាទាមទារឱ្យមានសេចក្តីក្លាហានភាពអំណត់ និងការប្តេជ្ញាចិត្តដែលអាចកើតមានក្នុងកម្រិតខុសៗគ្នា និងដែលអាចកើតចេញពីការមានជំនឿផ្ទាល់ខ្លួន ការយល់ដឹងស៊ីជម្រៅ ឬគ្រាន់តែជាការទទួលអារម្មណ៍ដឹងពីអ្វីដែលត្រឹមត្រូវ។

៤.៣ ទី ២ ការផ្លាស់ប្តូរជាវិជ្ជមានកើតមាននៅដំណាក់កាលផ្សេងៗគ្នា។ តាមរយៈការទទួលបានចំណេះដឹង និងព័ត៌មាន អ្នកសិក្សាដឹងពីតថភាពមួយចំនួន។ តាមរយៈការវិភាគបែបល្អិតល្អន់ ពួកគេចាប់ផ្តើមយល់ពីភាពស្មុគស្មាញនៃតថភាពទាំងនេះ។ ការមានពិសោធន៍ផ្ទាល់ជាមួយតថភាព ធ្វើឱ្យពួកគេកាន់តែអាចភ្ជាប់ទំនាក់ទំនងស៊ីជម្រៅជាមួយនឹងបញ្ហាទាំងនេះ ដែលអាចនាំឱ្យពួកគេយល់ពីស្ថានភាពរបស់អ្នកដែលរងផលប៉ះពាល់ដោយសារតថភាពនេះ។ ការយល់ពីស្ថានភាពរបស់អ្នកដទៃ អាចប្រែក្លាយជាសន្តានចិត្ត ប្រសិនបើតថភាពដែលពួកគេបានឃើញនេះ មានភាពពាក់ព័ន្ធជាមួយនឹងជីវិតផ្ទាល់ខ្លួន និងអត្តសញ្ញាណរបស់អ្នកសិក្សា។ ការផ្លាស់ប្តូរជាវិជ្ជមានកើតមានឡើង នៅពេលដែលចាប់ផ្តើមមានសមានចិត្តនៅលើគន្លងដែលលើកកម្ពស់នូវភាពក្លាហាន។[១៧]

៤.៤ ការយល់ដឹងបែបនេះមានភាពពាក់ព័ន្ធច្រើនជាមួយនឹងជាមួយនឹងគោលវិធីគរុកោសល្យ។ ឱកាសសម្រាប់ចាប់ផ្តើមការស្រាវជ្រាវបែបល្អិតល្អន់ ស្វែងយល់ពីតថភាព ភាពពាក់ព័ន្ធនឹងជីវិតផ្ទាល់ខ្លួន និងវត្តមានរបស់មិត្តភក្តិ អ្នកផ្តល់ការណែនាំ ឬអ្នកដែលជាជនគំរូប្រកបដោយឥទ្ធិពល ក៏ដូចជាចំណុចចាប់ផ្តើមធ្វើការផ្លាស់ប្តូរ បំពេញតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ភាពក្លាហាន ដល់បុគ្គលម្នាក់ៗចាប់ផ្តើមធ្វើសកម្មភាពជាចំណាត់។ អ្វីដែលសំខាន់ផងដែរនោះគឺ អ្នកសិក្សាត្រូវមានទីកន្លែងសម្រាប់ពិសោធន៍ផ្ទាល់ជាមួយនឹងគំនិតថ្មីៗ "ដែលនាំមកនូវការរំខាន" ទាំងនេះដែលអាចជួយឱ្យពួកគេធ្វើការត្រិះរិះពិចារណាយ៉ាងល្អិតល្អន់ និងធ្វើឱ្យពួកគេអាចមើលឃើញពីចំណុចសម្រាប់ចាប់ផ្តើមធ្វើការផ្លាស់ប្តូរ។ ការអប់រំក្នុងប្រព័ន្ធតែឯង គឺមិនគ្រប់គ្រាន់នោះឡើយ។ ការអប់រំក្រៅប្រព័ន្ធ និងការរៀនសូត្រក្រៅផ្លូវការ រួមនឹងការរៀនសូត្រពេញមួយជីវិតឆ្លងជំនាន់ ដែលកើតមាននៅតាមសហគមន៍ ផ្តល់ឱ្យអ្នកសិក្សានូវឱកាសសំខាន់ៗ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងពួកគេជាមួយនឹងតថភាពដែលពាក់ព័ន្ធនឹងពួកគេ និងដែលអាចមានឥទ្ធិពលដើម្បីឱ្យពួកគេអាចចាប់ផ្តើមអនុវត្តសកម្មភាពដែលចាំបាច់។

៤.៥ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតដល់បុគ្គលម្នាក់ៗ និងរបៀបដែលពួកគេធ្វើការផ្លាស់ប្តូរ។ ការផ្លាស់ប្តូរជាមូលដ្ឋានដែលចាំបាច់ ដើម្បីកសាងអនាគតប្រកបដោយចីរភាព ចាប់ផ្តើមចេញពីបុគ្គលម្នាក់ៗ និងពីការផ្លាស់ប្តូរឥរិយាបថ អាកប្បកិរិយា និងបែបផែននៃការរស់នៅរបស់ពួកគេ ខណៈពេលដែលកត្តាបរិបទ និងការគាំទ្រស្ថាប័ន បង្កើតនូវបរិយាកាសអំណោយផល និងអាចជួយឱ្យបុគ្គលម្នាក់ៗអាចចូលរួមចំណែកកាន់តែសកម្ម។ នេះគឺជាអ្វីដែលកើតមាន ជាពិសេសក្នុងចំណោមមនុស្សវ័យក្មេង ដែលជារឿយៗសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានរបស់ពួកគេ កើតមាន នៅពេលដែលពួកគេផ្តល់សារៈសំខាន់ដល់គុណតម្លៃអ្វីមួយ និងនៅពេលដែលបែបផែននៃការរស់នៅរបស់ពួកគេឆ្លើយតបចំពោះអត្តសញ្ញាណរបស់ពួកគេ។ ESD គឺជាកម្មវិធីដែលចាំបាច់ ដើម្បីផ្តល់ឱ្យពួកគេនូវបំណិនត្រិះរិះពិចារណាបែបល្អិតល្អន់ ដើម្បីឆ្លុះបញ្ចាំងពីគុណតម្លៃ ឥរិយាបថ និងអាកប្បកិរិយារបស់បុគ្គលម្នាក់ៗ ក៏ដូចជាជម្រើសក្នុងការរស់នៅរបស់ពួកគេ។

៤.៦ ចុងក្រោយ ការឆ្លុះបញ្ចាំងលើសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរបង្ហាញឱ្យឃើញពីសារៈសំខាន់របស់សហគមន៍។នៅក្នុងសហគមន៍មួយដែលគេអាចឱ្យនិយមន័យមិនត្រឹមតែជាសហគមន៍រូបវន្តប៉ុណ្ណោះទេ ថែមទាំងជាសហគមន៍តាមប្រព័ន្ធអនឡាញ សង្គម នយោបាយ ឬវប្បធម៌ផងដែរនោះ អ្នកសិក្សាអាចរកឃើញគុណតម្លៃ និងបុព្វហេតុនានា ដែលពាក់ព័ន្ធជាមួយនឹងពួកគេជាលក្ខណៈបុគ្គលផង និងជាសមូហភាពផង។ ពួកគេក៏អាចរកឃើញសមាជិកការផ្សេងទៀត និងបង្កើតទំនាក់ទំនងជាមួយនឹងអ្នកទាំងនោះ ដែលនាំមកនូវសាមគ្គីភាព និងជួយសម្រួលឱ្យមានការធ្វើសកម្មភាពជាសមូហភាព ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន និងវប្បធម៌ចីរភាព។

៤.៧ ការអនុវត្ត ESD ប្រៀបបីដូចជាការអនុវត្តភាពជាប្រជាពលរដ្ឋដូច្នោះដែរ។វាជំរុញឱ្យមានការគិតតែពីការរៀនសូត្រពេញមួយ

[១៧] មនុស្សម្នាក់មិនចាំបាច់ឆ្លងកាត់គ្រប់ដំណាក់កាលទាំងអស់នៃការផ្លាស់ប្តូរជាវិជ្ជមាននោះឡើយ (ការយល់ដឹង ការដឹងពីភាពស្មុគស្មាញ ការយល់ពីស្ថានភាពអ្នកដទៃ សន្តានចិត្ត ភាពក្លាហាន)។ គេអាចរំលងដំណាក់កាលមួយចំនួន ដោយបុគ្គលខ្លះអាចផ្លាស់ពីដំណាក់កាលទីមួយ ទៅដំណាក់កាលចុងក្រោយនៃការបង្កើនភាពក្លាហានតែម្តង។ លើសពីនេះក៏អាចមានករណីដែលបុគ្គលមួយចំនួន ចាប់ផ្តើមជាមួយនឹងការយល់ពីស្ថានភាពអ្នក និងការមានសន្តានចិត្ត ហើយក្រោយមកធ្វើការដោះស្រាយបញ្ហានេះតាមរយៈការយល់ដឹងរបស់ពួកគេ ពោលគឺពួកគេពុំបានចាប់ផ្តើមពីដំណើរការយល់ដឹងទៅនោះឡើយ។ បុគ្គលម្នាក់ក៏ឆ្លងកាត់ដំណាក់កាលទាំងនេះដោយប្រើប្រាស់ដំណើរការ និងក្នុងល្បឿនខុសៗគ្នាផងដែរ។

ជីវិត ដែលធ្វើឡើងមិនត្រឹមតែនៅតាមសាលារៀនប៉ុណ្ណោះទេ ថែមទាំងនៅខាងក្រោមវិជ្ជាដ្ឋានសាលារៀនផងដែរ ពោលគឺនៅក្នុងជីវិតរបស់បុគ្គលម្នាក់ៗ។ ដោយឈរលើគោលការណ៍សិទ្ធិមនុស្ស និងគោលការណ៍ដទៃទៀត ដូចជា ការចូលរួម ការមិនរើសអើង និងគណនេយ្យភាពជាដើម ESD មានទំនាក់ទំនងជាមួយនឹងកត្តាសង្គម និងវប្បធម៌របស់សហគមន៍ និងជំរុញឱ្យមានការសិក្សាស្វែងយល់ពីសង្គមនៅក្នុងសហគមន៍ទាំងនោះ។ អត្តសញ្ញាណវប្បធម៌បំពេញតួនាទីយ៉ាងសំខាន់។ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងសហគមន៍កាន់តែជិតស្និទ្ធ គួរមានការផ្ដល់ស្វ័យភាពបន្ថែមទៀតដល់សាលារៀន ក្នុងការអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សា និងគ្រប់គ្រងរាល់សកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។ ដូច្នេះ ការអនុវត្ត ESD ទាមទារឱ្យមានការគិតបែបថ្មីអំពីតួនាទី និងមុខងាររបស់សាលារៀន។

៤.៨ **ការផ្លាស់ប្ដូររចនាសម្ព័ន្ធ៖** ដោយសារតែចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមលើអ្វីដែលកំពុងកើតមាននៅកម្រិតបុគ្គលម្នាក់ៗជុំវិញការសម្រេចចិត្ត និងបទពិសោធន៍ដែលនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមាន ESD ក៏ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់បន្ថែមទៀតលើបុព្វហេតុដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងរចនាសម្ព័ន្ធទៅហើយ។

៤.៩ ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព គឺជាបញ្ហាមួយ ក្នុងចំណោមបញ្ហាពាក់ព័ន្ធនានា។ មានការយល់ស្របជាទូទៅថា គេពិបាកនឹងរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាពណាស់ ដរាបណានិន្នាការនៅក្នុងឧស្សាហកម្ម និងផលិតកម្មបច្ចុប្បន្ន នៅតែបន្តមានបែបនេះទៀត។ ផលិតកម្ម និងការប្រើប្រាស់ដែលមានសន្ទុះកើនឡើងយ៉ាងលឿនមិនធ្លាប់មាន នាំឱ្យរេចរឹលដល់ធនធានធម្មជាតិ នាំឱ្យមានបរិមាណសំណល់ក្នុងកម្រិតដែលមិនអាចគ្រប់គ្រងបាន និងនាំឱ្យមានការកើនឡើងនូវសីតុណ្ហភាពនៅក្នុងសកលលោកទាំងមូល។ មានគំនិតផ្ដួចផ្ដើមដែលគួរឱ្យជឿទុកចិត្ត និងសមទទួលបានការកោតសរសើរជាច្រើនសម្រាប់លើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់ប្រកបដោយចីរភាព ប៉ុន្តែផលជះនៃគំនិតផ្ដួចផ្ដើមទាំងនេះនៅមានកម្រិតនៅឡើយ។

៤.១០ នាពេលអនាគត ESD ត្រូវលើកទឹកចិត្តឱ្យអ្នកសិក្សាឈ្វេងយល់ពីគុណតម្លៃដែលអាចផ្ដល់នូវជម្រើសផ្សេងដល់សង្គម ដែលឱ្យតម្លៃដល់ការប្រើប្រាស់ ដូចជា ភាពគ្រប់គ្រាន់ ភាពយុត្តិធម៌ និងសាមគ្គីភាពជាដើម។ ផលប្រយោជន៍ថ្មីៗដែលទទួលបានពីសេដ្ឋកិច្ចវិលជុំ និងសេដ្ឋកិច្ចបែបចែករំលែក គឺជាគុណតម្លៃមួយក្នុងចំណោមគុណតម្លៃជាជម្រើសទាំងនេះ។[១៨] ESD អាចផ្ដល់ការបណ្ដុះបណ្ដាលដល់តួអង្គពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យឯកជន និងអាចបង្កើនចំណេះដឹងហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការធ្វើសកម្មភាពសេដ្ឋកិច្ចដែលមានចីរភាព។ ESD ក៏ត្រូវមានឥទ្ធិពលលើនិន្នាការផលិតកម្មដែលពុំមានចីរភាពទៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្នដោយផ្ទាល់ផងដែរ។ នេះមានន័យថាចាំបាច់ត្រូវបង្កើនភាពក្លាហានដល់មនុស្ស ដើម្បីឱ្យពួកគេអាចចូលរួមផ្ទាល់ក្នុងដំណើរការនយោបាយ និងការជំរុញឱ្យមានការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកបរិស្ថានឱ្យបានសមស្របសម្រាប់សហគ្រាសនានា។

៤.១១ ចាំបាច់ត្រូវមានការយល់ឃើញដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ដើម្បីឆ្លើយតបចំពោះ ESD នៅក្នុងបរិបទនៃភាពក្រីក្រធ្ងន់ធ្ងរផងដែរ។ មនុស្សមួយចំនួនគិតថា ESD នេះគឺជា "រឿងប្រណិត" នៅក្នុងបរិបទនៃភាពក្រីក្រធ្ងន់ធ្ងរ ឬស្ថានភាពផ្សេងទៀត ដែលបង្កការលំបាកដល់ការរស់រាន (ឧទាហរណ៍ ស្ថានភាពជម្លោះ ឬស្ថានភាពជនភៀសខ្លួនជាដើម)។ ការលើកឡើងបែបនេះ ក៏បង្កនូវភាពពិតមួយចំនួនផងដែរ ព្រោះថាភាពស្មុគស្មាញ ក៏ដូចជាភាពពាក់ព័ន្ធនៃទស្សនទានអភិវឌ្ឍន៍ដោយចីរភាព ជាអ្វីដែលមិនឆ្លើយតបទៅនឹងស្ថានភាពរបស់មនុស្សដែលកំពុងជួបការលំបាកលំបិនក្នុងការរស់នៅប្រចាំថ្ងៃ ប៉ុន្តែការលើកឡើងបែបនេះក៏មិនមែនជំទាស់ទៅនឹងសារៈសំខាន់នៃ ESD ចំពោះក្រុមមនុស្សដែលកំពុងជួបការខ្វះខាតនោះដែរ។

៤.១២ ប្រជាពលរដ្ឋដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ជារឿយៗ គឺជាជនរងគ្រោះដោយសារការអភិវឌ្ឍដែលបង្កឱ្យមានគ្រោះមហន្តរាយ ឬគ្រោះមហន្តរាយធម្មជាតិ។ ពួកគេរងផលប៉ះពាល់ផ្ទាល់ដោយសារការរេចរឹលបរិស្ថាន និងការខ្វះជាចីរភាពសេដ្ឋកិច្ច និងសង្គម។ អភិក្រម ESD ដែលមានប្រសិទ្ធភាពសម្រាប់ក្រុមមនុស្សដែលនៅក្នុងស្ថានភាពល្អប្រសើរ ប្រហែលជាមិនមានប្រសិទ្ធភាពសម្រាប់ក្រុមមនុស្សដែលកំពុងជួបការខ្វះខាតនៅឡើយ ដូច្នេះគេចាំបាច់ត្រូវកែសម្រួលអភិក្រម ESD ឱ្យស្របតាមបរិបទ និងតថភាពរបស់ក្រុមគោលដៅ។

៤.១៣ ឧទាហរណ៍ ការប្រើប្រាស់សហគមន៍ជាវេទិកាសកម្មភាពដូចការលើកឡើងពីខាងដើមអាចអនុវត្តតាមបែបផ្សេងក្នុងបរិបទនៃភាពក្រីក្រធ្ងន់ធ្ងរ។ ជារឿយៗ ភាពក្រីក្រធ្ងន់ធ្ងរកើតមានជាទូទៅក្នុងចំណោមក្រុមចំណាកស្រុក។ គេអាចប្រមូលផ្ដុំសមាជិករបស់ក្រុមទាំងនេះមកជួបជុំគ្នាបែបនិម្មិតដោយពុំមានការផ្សារភ្ជាប់ទំនាក់ទំនង ឬការផ្ដល់អត្តសញ្ញាណរួមនោះឡើយ។ ជនភៀសខ្លួន ឬអ្នកដែលស្ថិតនៅក្នុងស្ថានភាពជម្លោះដទៃទៀត ក៏ប្រឈមនឹងព្រេងវាសនាដូចគ្នានេះដែរ។ សម្រាប់ក្រុមទាំងនេះ

[១៨] សេដ្ឋកិច្ចវិលជុំ ជំរុញឲ្យមានការងាកចេញពីគំរូយក ផលិត និងចោល ទៅជាការប្រើប្រាស់អភិក្រមពី "វត្ថុធាតុដើមដំបូងទៅវត្ថុធាតុដើមដំបូង (cradle to cradle)" ដោយប្រើប្រាស់របៀបរចនាផលិតផលដែលប្រើប្រាស់បានយូរ ការជួសជុល ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ។ មានការលើកឡើងថា នៅក្នុងពិភពលោកប្រកបដោយចីរភាព អ្នកប្រើប្រាស់អាចបន្តការប្រើប្រាស់ផលិតផល និងសេវាស្រដៀងគ្នាដែរ។ ឧទាហរណ៍ គេអាចរចនាទូរស័ព្ទដៃតាមរបៀបដែលអាចឱ្យគេយកបំណែកដែលមានតម្លៃយកទៅប្រើប្រាស់ឡើងវិញកាន់តែងាយស្រួល។ ខណៈពេលដែលមានការចោលសម្លៀកបំពាក់ក្នុងបរិមាណដ៏ច្រើនលើសលុប ដោយសារតែនិន្នាការម៉ូដពេញនិយមមានសន្ទុះយ៉ាងឆាប់រហ័ស ក្រុមហ៊ុនវាយនភណ្ឌមួយចំនួន កំពុងធ្វើការកែសម្រួលរចនាសម្ព័ន្ធនៃប្រព័ន្ធប្រតិបត្តិការរបស់ខ្លួន ដើម្បីផ្ដល់លទ្ធភាពឲ្យគេអាចយកក្រណាត់កែច្នៃ មកប្រើប្រាស់ជំនួសឲ្យវត្ថុធាតុដើមវិញ។

សហគមន៍ដែលអាចផ្តល់នូវវេទិកាសកម្មភាពដ៏មានប្រយោជន៍ គួរធ្វើការពិចារណាពីបញ្ហាពិសេសដែលពាក់ព័ន្ធនឹង អត្តសញ្ញាណក្រុម។

៤.១៤ លើសពីនេះអភិក្រមសម្រាប់ក្រុមមនុស្សដែលរស់នៅក្នុងភាពក្រីក្រធ្ងន់ធ្ងរ ប្រហែលជាទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដល់ចំណុចដែលជាមូលដ្ឋានគ្រឹះ។ ដំបូងឡើយ ចំណុចចាប់ផ្តើមគឺត្រូវធានា និងស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរបស់មនុស្សនិងសិទ្ធិរស់នៅប្រកបដោយភាពថ្លៃថ្នូរ។ ការផ្តល់ឱ្យមនុស្សនូវបំណិនជីវិតជាមូលដ្ឋាន និងបំណិនជីវិតដែលពាក់ព័ន្ធដទៃទៀត ឬជំនាញ ដែលអាចឱ្យពួកគេអាចប្រកបមុខរបរចិញ្ចឹមជីវិត ដើម្បីអាចតតាំង និងយកឈ្នះភាពក្រីក្រធ្ងន់ធ្ងរត្រូវបានចាត់ទុកជាអាទិភាព។ ចំណុចទាំងនេះមិនអាចអនុវត្តទៅបានឡើយ ប្រសិនបើពុំមានការឆ្លើយតបចំពោះបរិបទនយោបាយ ប្រវត្តិសាស្ត្រ សង្គមសេដ្ឋកិច្ច ដែលជាដើមចមនាំឱ្យពួកគេទទួលរងការឈឺចាប់ និងបន្តទទួលរងការឈឺចាប់ទៀត។

៤.១៥ **បច្ចេកវិទ្យានាពេលអនាគត៖** បើតាមរបាយការណ៍មួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០១៥ ដោយវេទិកាសេដ្ឋកិច្ចសកលលោក នៅត្រឹមឆ្នាំ ២០២៥ ឬមិនដល់ ១០ ឆ្នាំទៀតផង ពិភពលោកនឹងមើលឃើញពីបម្រែបម្រួលបច្ចេកវិទ្យាធំៗដែលនាំឱ្យមានការផ្លាស់ប្តូរគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងសង្គមរបស់យើង។ចុងក្រោយការផ្លាស់ប្តូរមិនត្រឹមតែកើតមានចំពោះជីវិត និងបរិស្ថានរបស់យើងប៉ុណ្ណោះទេ ថែមទាំងចំពោះការជជែកវែកញែករបស់យើងអំពីបញ្ហាចីរភាពផងដែរ។ នឹងមានការដោះស្រាយបញ្ហា "ចាស់ៗ" មួយចំនួន ប៉ុន្តែបញ្ហាប្រឈម និងហានិភ័យថ្មីៗនឹងកើតមានឡើង។ ESD ដើម្បីឆ្លើយតបចំពោះស្ថានភាពនាពេលអនាគត មិនអាចមិនអើពើចំពោះភាពពាក់ព័ន្ធនៃយុគសម័យបច្ចេកវិទ្យានោះឡើយ។

៤.១៦ ទំនាក់ទំនងជាទូទៅរវាងអ៊ីនធឺណិតជាមួយនឹងបរិស្ថានរបស់យើង នឹងជួយឱ្យយើងពិនិត្យតាមដាន និងគ្រប់គ្រងការប្រើប្រាស់ថាមពលបានកាន់តែប្រសើរ។ ឧទាហរណ៍ បច្ចេកវិទ្យាទីក្រុងវៃឆ្លាតនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងថាមពល ចរាចរណ៍ និងភ័ស្តុភារ។ នវានុវត្តន៍មួយចំនួន ដូចជា ការបោះពុម្ព 3D អាចកាត់បន្ថយការដឹកជញ្ជូនវត្ថុធាតុដើមដែលចាំបាច់ត្រូវតែធ្វើកន្លងមក។ កិច្ចខិតខំប្រឹងប្រែង ESD មួយចំនួនដែលអនុវត្តកន្លងមក ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថរបស់មនុស្សពាក់ព័ន្ធនឹងការសន្សំសំចៃថាមពល ការគ្រប់គ្រងធនធាន និងបរិស្ថានបៃតងលែងមានភាពពាក់ព័ន្ធទៀត។ក្នុងពេលជាមួយគ្នានេះក៏នឹងមានឱកាសថ្មីៗសម្រាប់ESDផងដែរ។ឧទាហរណ៍ ESD អាចពន្លឿនអន្តរកាលទៅកាន់បច្ចេកវិទ្យាបៃតង តាមរយៈការផ្តល់ការបំពាក់បំប៉នដល់មនុស្សនូវជំនាញបៃតងដែលចាំបាច់ជាដើម។

៤.១៧ ម្យ៉ាងវិញទៀត ក៏មានការកើនឡើងនូវបញ្ហាប្រឈមថ្មីៗផងដែរ ឧទាហរណ៍ការបោះពុម្ព 3D អាចនាំឱ្យមានការកើនឡើងនៅសំណល់ និងនាំឱ្យមានការកើនឡើងនូវការប្រើប្រាស់។ ពិភពលោកដែលមានការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម និងទំនាក់ទំនងតាមប្រព័ន្ធឌីជីថល ជួយនាំមកនូវភាពសុខស្រួល និងគុណភាពនៃជីវិតប៉ុន្តែវាក៏នាំមកនូវហានិភ័យផ្នែកសន្តិសុខ និងសុវត្ថិភាព និងនាំឱ្យមានគ្រោះហានិភ័យប្រភេទថ្មីៗ ដែលផលប៉ះពាល់ដល់ការសាយភាយខ្លាំងជាងពិភពលោកដែលមិនសូវភ្ជាប់ទំនាក់ទំនងជាមួយគ្នា។ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតកំពុងមានឥទ្ធិពលយ៉ាងធំធេងលើឥរិយាបថរបស់មនុស្សក្នុងផ្នែកប្រើប្រាស់ផង និងទំនាក់ទំនងក្នុងសង្គមផង[១៩]។ ការចែករំលែកអត្ថប្រយោជន៍ដែលបានពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាមិនស្មើភាពគ្នាអាចពង្រីកគម្លាតរវាងអ្នកដែលមានបច្ចេកវិទ្យាប្រើប្រាស់ និងអ្នកជំនាញបច្ចេកវិទ្យាប្រើប្រាស់។ ESD សម្រាប់អនាគតគួរត្រៀមមនុស្សជំនាន់ក្រោយឱ្យចេះទប់ទល់នឹងបញ្ហាថ្មីៗ។

៤.១៨ អ្វីដែលសំខាន់ ចាំបាច់ត្រូវមានការត្រិះរិះពិចារណាឱ្យបានល្អិតល្អន់លើការបន្តភាពពាក់ព័ន្ធនៃគុណតម្លៃចីរភាព "បែបប្រពៃណី"។ ជាមួយនឹងអគារដែលបំពាក់ដោយឧបករណ៍សិនស័រ ឥរិយាបថមួយចំនួន ដូចជា ការបិទភ្លើងជាដើម អាចលែងមានភាពចាំបាច់ណាទៅទៀត ប៉ុន្តែគុណតម្លៃដែលពាក់ព័ន្ធនឹងការសន្សំសំចៃថាមពល និងបន្តមានភាពពាក់ព័ន្ធ ហើយក៏គួរបន្តមានភាពពាក់ព័ន្ធផងដែរ។ ការបង្រៀនគោលការណ៍ចីរភាព អាចកាន់តែលំបាកជាងមុន ព្រោះថាបច្ចេកវិទ្យាការនាំមិនមានការយល់ខុសថា គេអាចដោះស្រាយបញ្ហាចីរភាពទាំងអស់ ឬអត់ដោះស្រាយបញ្ហាទាំងនេះភាគច្រើនដោយប្រើប្រាស់បច្ចេកវិទ្យា។

៤.១៩ ដោយសារតែវិស័យធុរកិច្ច កម្មន្តសាល និងសហគ្រាស ក៏ដូចជាសហគមន៍វិទ្យាសាស្ត្រ គឺជាតួអង្គ និងអ្នកទទួលផលសំខាន់ជាងគេនៃនវានុវត្តន៍បច្ចេកវិទ្យា ជាការសំខាន់ណាស់ដែល ESD ត្រូវមានទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយនឹងតួអង្គពាក់ព័ន្ធនៅក្នុងសហគមន៍ទាំងនេះ។ ការតម្រង់ទិស ESD ដើម្បីគាំទ្រដល់ការសម្រេច SDG នឹងផ្តល់ឱកាសឱ្យសហគមន៍ ESD ធ្វើការកាន់តែជិតស្និទ្ធជាមួយនឹងតួអង្គពាក់ព័ន្ធនៅក្នុងសហគមន៍ខាងលើ ដែលពួកគេធ្វើជាតួអង្គពាក់ព័ន្ធសំខាន់ៗនៃគោលដៅទាំងនេះផងដែរ។

[១៩] គួរមានការឈ្វេងយល់អំពីទំនាក់ទំនងរវាងបច្ចេកវិទ្យានាំមុខ ដូចជា ឌីជីថលូបនីយកម្ម និងបញ្ញាសិប្បនិម្មិត និង ESD។

៥. ក្របខ័ណ្ឌអនុវត្ត

៥.១ **ចំណងជើង៖** ឈ្មោះដែលស្នើឡើងសម្រាប់ក្របខ័ណ្ឌ ដើម្បីគាំទ្រដល់យុគសម័យក្រោយ GAP គឺការអប់រំសម្រាប់ការអភិវឌ្ឍចីរភាព៖ ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ចីរភាព (ហៅកាត់ថា ESD សម្រាប់ឆ្នាំ ២០៣០)។ ក្របខ័ណ្ឌនេះមានគោលបំណងបញ្ជាក់ច្បាស់ពីការបន្តពីដំណាក់កាល GAP បច្ចុប្បន្ន ទៅរកដំណាក់កាលក្រោយ GAP ហើយក្នុងពេលជាមួយគ្នាក៏បង្ហាញឱ្យឃើញពីការតម្រឹមឱ្យស្របទៅនឹងរបៀបវារៈអភិវឌ្ឍន៍ចីរភាពឆ្នាំ ២០៣០ ផងដែរ។

៥.២ **គោលដៅ៖** ESD សម្រាប់ឆ្នាំ ២០៣០ មានគោលដៅកសាងនូវពិភពលោកដែលកាន់តែយុត្តិធម៌ និងកាន់តែមានចីរភាពតាមរយៈការពង្រឹង ESD និងការរួមចំណែកដល់ការសម្រេចគោលដៅ SDG ទាំង ១៧។ ESD សម្រាប់ឆ្នាំ ២០៣០ នឹងសម្រេចគោលដៅបនេះ តាមរយៈអភិក្រមចំនួន ៣។

៥.៣ រាល់សកម្មភាព ESD ទាំងអស់ រួមចំណែកដល់ការសម្រេច SDG។ សកម្មភាព ESD ដែលធ្វើឡើងដោយរដ្ឋជាសមាជិក និងយូណេស្កូ បើទោះជាមានការលើកឡើងយ៉ាងជាក់ច្បាស់ពីSDGក៏ដោយកន្លងមកបានឆ្លើយតបនឹងបញ្ហាជាច្រើនដែលបច្ចុប្បន្ននេះត្រូវបានផ្សារភ្ជាប់ជាមួយនឹង SDG មួយចំនួន។ បញ្ហាទាំងនេះ មានដូចជា ការប្រែប្រួលអាកាសធាតុ ដែលត្រូវបានបញ្ចូលទៅក្នុង SDG ទី ១៣ ស្តីពីសកម្មភាពអាកាសធាតុ ជីវិតក្នុងសមុទ្រនៅក្នុង SDG ទី ១៤, ជីវៈចម្រុះក្នុង SDG ទី ១៥, ព្រមទាំងថាមពលស្អាតក្នុង SDG ទី ១៧, ក្រុងនិងសហគមន៍ប្រកបដោយចីរភាពក្នុងSDGទី ១១, ការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវក្នុង SDG ទី ១២ និងការអប់រំក្នុង SDG ទី ១៤។ ការរួមចំណែកនៃសកម្មភាព ESD ដែលអនុវត្តជាយូរមកហើយទាំងនេះដល់ការសម្រេច SDG កន្លងមក បានស្តែងចេញឱ្យឃើញយ៉ាងច្បាស់ ហើយសកម្មភាពទាំងនេះសមនឹងទទួលបានការគាំទ្របន្តទៀត។

៥.៤ ក្នុងពេលជាមួយគ្នាESDក៏អាចមានតួនាទីបែបសកម្មជាងមុនដើម្បីចូលរួមក្នុងការសម្រេចចិត្ត SDG ជាពិសេស SDG ទាំងឡាយណាដែលបានលើកឡើងជាក់លាក់ពី ESD។ សកម្មភាពអប់រំផ្សព្វផ្សាយ និងការតស៊ូមតិពាក់ព័ន្ធនឹង SDG នៅតាមបរិបទនៃការអប់រំផ្សេងៗគ្នា គឺជាឧទាហរណ៍ល្អៗ។ សកម្មភាពទាំងនេះ នឹងផ្តល់នូវព័ត៌មានដល់អ្នកសិក្សាគ្រប់វ័យទាំងអស់អំពី SDG ទាំង ១៧ ព្រមទាំងភាពពាក់ព័ន្ធនៃគោលដៅទាំងនេះ ចំពោះជីវិតរបស់បុគ្គលម្នាក់ៗ និងរបស់ក្រុម ដូចជាការទទួលខុសត្រូវដែលបុគ្គល និងស្ថាប័នមាន ដើម្បីជួយសម្រេចគោលដៅទាំងនេះជាដើម។ សកម្មភាព ESD ទាំងនេះគឺជាសកម្មភាពដែលកំពុងមានតម្រូវការខ្ពស់ ព្រោះថាគេចាំបាច់ត្រូវធ្វើការអប់រំផ្សព្វផ្សាយដល់អ្នកសិក្សានៅគ្រប់វ័យទាំងអស់ ក៏ដូចជាដល់សាធារណជនទូទៅ ដើម្បីពង្រីកការយល់ដឹងរបស់ពួកគេអំពី ESD និងតួនាទីនៃការអប់រំ ក្នុងការសម្រេចគោលដៅទាំងនេះ។

៥.៥ ទំនាក់ទំនងរវាង ESD ជាមួយនឹង SDG ក៏អាចកាន់តែស៊ីជម្រៅជាងនេះទៅទៀត និងមានលើសត្រឹមតែពីការអប់រំ ការផ្សព្វផ្សាយ និងការតស៊ូមតិ។ សកម្មភាព ESD អាចនាំឱ្យមានការលើកឡើងនូវសំណួរសំខាន់ៗមួយចំនួនអំពីភាពប្រទាក់ក្រឡាគ្នារវាងគោលដៅ SDG ផ្សេងៗដែលអាចនាំឱ្យមានភាពប្រទាំងប្រទើស និងបញ្ហាមិនច្បាស់លាស់មួយចំនួន។សកម្មភាព ESD ប្រភេទទាំងនេះ នៅតែបន្តនឹងផ្តោតការយកចិត្តទុកដាក់លើប្រធានបទពាក់ព័ន្ធនិង SDG ឬអាចប្រើប្រាស់ជាឧបករណ៍សម្រាប់អប់រំផ្សព្វផ្សាយអំពី SDG។ សកម្មភាពទាំងនេះនឹងនាំឱ្យមានសំណួរសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការអភិវឌ្ឍ ឬការអភិវឌ្ឍដោយចីរភាព ក៏ដូចជាភាពប្រទាក់ក្រឡាគ្នារវាង SDG ផ្សេងៗ។

៥.៦ ឧទាហរណ៍ SDG ទី ១២ ស្តីពីការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវចាំបាច់ត្រូវផ្សារភ្ជាប់ទំនាក់ទំនងជាមួយ SDG ទី ៨ ស្តីពីការងារសមរម្យ និងកំណើនសេដ្ឋកិច្ច និងត្រូវមានការប្តេជ្ញាចិត្តនៅកម្រិតស្ថាប័ន ទើបអាចដោះស្រាយបញ្ហារវាង SDG ពីរនេះ។ SDG ទី ៩ ស្តីពីឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ត្រូវធ្វើការពិចារណាពីបញ្ហានានាដែលពាក់ព័ន្ធជាមួយ SDG ទី ១១ ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយចីរភាព ហើយគោលដៅទាំងពីរនេះចាំបាច់ត្រូវតែមានតុល្យភាពជាមួយគ្នា។ ESD នៅក្នុងក្របខ័ណ្ឌ ESD សម្រាប់ឆ្នាំ ២០៣០ គួរផ្តល់នូវការយល់ឃើញដែលមានតុល្យភាពជុំវិញការអភិវឌ្ឍ។

៥.៧ ការខិតខំលើកជាសំណួរល្អៗ និងចាត់ទុកការអភិវឌ្ឍថាជា អ្វីដែលត្រូវមានតុល្យភាព មិនមែនជារឿងថ្មីសម្រាប់សហគមន៍ ESD នោះឡើយ។ តាំងពីទសវត្សរ៍ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពមក និងតាមរយៈការអនុវត្ត GAP នៅដំណាក់កាលបច្ចុប្បន្ន ការតម្រង់ទិសសង្គមឱ្យងាកទៅរកការអភិវឌ្ឍដោយចីរភាព នៅតែជាគោលបំណងដ៏សំខាន់បំផុតនៃ ESD។ SDG ទាំង ១៧ ដែលផ្តោតលើបញ្ហាជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍនិងចីរភាពដាក់ទៅក្នុងខណ្ឌតែមួយផ្តល់ឱ្យសហគមន៍សកលនូវឱកាសថ្មីមួយទៀត ដើម្បីពង្រឹងបន្ថែមលើមុខងារជាមូលដ្ឋាននៃ ESD នេះ។

៥.៨ ខណៈពេលដែល ESD រួមចំណែកដល់ SDG ទាំង ១៧ ESD បន្តមានភាពពាក់ព័ន្ធជាពិសេសជាមួយនឹងរបៀបវារៈអប់រំជាសកល ដែលត្រូវបានដាក់ចេញនៅក្នុងគោលដៅ SDG ទី ៤ ជាកន្លែងពិសេសរបស់ ESD។ ESD ក៏ជាសមាសភាគមួយដ៏សំខាន់នៃការអប់រំប្រកបដោយគុណភាពផងដែរ។សមត្ថភាព

នានា ដូចជា សមត្ថភាពស្រូបយកចំណេះដឹង ចិត្តសង្គម និងឥរិយាបថដែលសុទ្ធតែជាសមាសភាគសំខាន់ៗនៃការរៀនសូត្រ មានភាពពាក់ព័ន្ធជាមួយនឹងគ្រប់ផ្នែកទាំងអស់នៃការអប់រំ។ ការផ្តោតការយកចិត្តទុកដាក់នៃក្របខ័ណ្ឌ ESD លើសមត្ថភាពពាក់ព័ន្ធនឹងការយល់ពីស្ថានភាពអ្នកដទៃ សាមគ្គីភាព និងការធ្វើសកម្មភាព ជួយជំរុញ SDG ទី ៤ ទៅរកស្ថានភាពនាពេលអនាគតដែលការអប់រំរួមចំណែកមិនត្រឹមតែដល់ជោគជ័យរបស់បុគ្គលម្នាក់ៗឡើយ ថែមទាំងដល់ការរស់រាន និងការសម្រេចបាននូវវិបុលភាពជារួមរបស់សហគមន៍សកលទៀតផង។ វាក៏អាចជួយដល់របៀបវារៈអប់រំសកល ឱ្យងាកចេញពីការផ្តោតតែលើការចូលរៀន និងគុណភាព ដែលត្រូវបានវាស់វែងជាលទ្ធផលនៃការសិក្សាផងដែរ ដើម្បីងាកទៅបង្កើនការផ្តោតការយកចិត្តទុកដាក់លើខ្លឹមសារនៃការការសិក្សា និងការរួមចំណែកនៃការសិក្សាចំពោះមនុស្សជាតិ។

៥.៩ រចនាសម្ព័ន្ធ៖ គោលបំណងចម្បងនៃដំណាក់កាលបច្ចុប្បន្ននៃកម្មវិធី GAP គឺដើម្បីសម្រួលដល់ការពង្រីកវិសាលភាពសកម្មភាពដែលកំពុងអនុវត្តនៅនឹងមូលដ្ឋាន។ បើតាមការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ គោលដៅនេះកំពុងសម្រេចបានយ៉ាងជោគជ័យដោយដៃគូសំខាន់ៗរបស់កម្មវិធីGAPដោយកន្លងមកមានការរៀបចំសកម្មភាពជាច្រើននៅក្នុងមូលដ្ឋានផ្ទាល់។ ដោយប្រើប្រាស់គោលវិធីវិធីបច្ចុប្បន្នដែលកំពុងប្រើប្រាស់នៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកម្មវិធី GSP គឺជាគោលវិធីដែលមានប្រសិទ្ធភាព ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ផ្តល់អនុសាសន៍ឱ្យមានការបន្តរក្សាសមាសភាគសំខាន់ៗនៃកម្មវិធីនេះ និងមានការលើកស្នើឱ្យធ្វើការកែសម្រួល និងធ្វើបច្ចុប្បន្នភាពមួយចំនួនផ្អែកតាមមេរៀនដែលទទួលបានពីការអនុវត្ត។

៥.១០ ទី ១ សកម្មភាពជាអាទិភាពទាំង ៥ ដូចជា ជំរុញគោលនយោបាយ, ធ្វើការផ្លាស់ប្តូរបរិយាកាសរៀនសូត្រ និងបណ្តុះបណ្តាលជាវិជ្ជាមាន, កសាងសមត្ថភាពអ្នកអប់រំ និងអ្នកបណ្តុះបណ្តាល, បង្កើតភាពក្លាហាន និងកៀរគរយុវជន, និងពន្លឿនដំណោះស្រាយប្រកបដោយចីរភាពនៅនឹងមូលដ្ឋាន នៅតែជាសកម្មភាពដែលមានសុពលភាព។ សកម្មភាពទាំងនេះគឺជាច្រកចូលដ៏មានប្រយោជន៍សម្រាប់រៀបចំសកម្មភាព *ESD សម្រាប់ឆ្នាំ ២០៣០*។

៥.១១ ទី ២ បណ្តាញដៃគូទាំង ៥ មានតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានដល់តួអង្គនៅកម្រិតមូលដ្ឋាន។ ទស្សនទាននេះសមនឹងបន្តទទួលបានការគាំទ្រ[២០] ប៉ុន្តែគួរមានការពង្រឹងការសហការក្នុងចំណោមដៃគូនានាបន្ថែមទៀត។ ដើម្បីសម្រេចគោលដៅនេះ គួររៀបចំឱ្យមានការផ្តល់ការគាំទ្រដល់បណ្តាញនីមួយៗសម្រាប់សកម្មភាពដែលមានការចូលរួមពីដៃគូមកពីក្រុមផ្សេងៗនៅក្នុងបណ្តាញ។[២១] លើសពីនេះ គួរមានការបញ្ចូលបណ្តាញដៃគូទាំង ៥ ទៅក្នុងបណ្តាញដៃគូរួមតែមួយដោយដៃគូចំនួន ៥ ក្រុម ដែលមានឯកទេសលើសកម្មភាពជាអាទិភាព ៥ត្រូវប្រាប់បញ្ចូលគ្នា បន្ថែសហការជាមួយក្រុមដៃគូដទៃទៀត។ នឹងមានការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីជំរុញឱ្យមានការចូលរួមពីតំណាងរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន អង្គការសង្គមស៊ីវិល អ្នកផ្តល់ជំនួយ សហគមន៍អភិវឌ្ឍន៍ព្រមទាំងសហគមន៍SDGនៅក្នុងបណ្តាញដៃគូនេះ។

៥.១២ ចុងក្រោយ កម្មវិធីផ្តល់រង្វាន់ESDដែលអនុវត្តដោយយូណេស្កូ និងប្រទេសជប៉ុន ដែលជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រ GAP ហើយដែលបានក្លាយជាកម្មវិធីផ្តល់រង្វាន់ដែលទទួលបានជោគជ័យជាងគេមួយ សមនឹងទទួលបានការគាំទ្របន្ថែមទៀត ដើម្បីប្រើប្រាស់ជាឧបករណ៍ស្វែងរកការគាំទ្រសម្រាប់ ESD និងជាពិសេសសម្រាប់ស្ថានភាពក្រោយ GAP។

៥.១៣ សកម្មភាពដែលអនុវត្តដោយរដ្ឋជាសមាជិក៖ ESD គឺជាធាតុផ្សំមួយដ៏សំខាន់នៃចំណុចដៅ ៤.៧ នៃគោលដៅ SDG ទី ៤ ស្តីពីការអប់រំ។ ESD ត្រូវបានបញ្ចូលជាចំណុចដៅអប់រំសកលមួយដែលនឹងមានការពិនិត្យតាមដានជាប្រចាំលើវឌ្ឍនភាពដែលសម្រេចបាន។ ។ បច្ចុប្បន្ននេះ មានការយល់ច្បាស់យ៉ាងច្បាស់ថា ESD ថាជាលក្ខខណ្ឌដ៏សំខាន់មួយសម្រាប់ការអប់រំប្រកបដោយគុណភាព បើគិតពីភាពបន្ទាន់នៃការកសាងពិភពលោកមួយប្រកបដោយសន្តិភាព និងចីរភាព ដើម្បីភាពរស់រាន និងវិបុលភាពរបស់មនុស្សជំនាន់នេះ និងមនុស្សជំនាន់ក្រោយ។ ដើម្បីគាំទ្រឱ្យ ESD ក្លាយជាកម្លាំងចលករដ៏សំខាន់សម្រាប់ជួយដល់ការសម្រេចគោលដៅ SDG ដទៃទៀត និងជាពិសេស SDG ទី ៤ ស្តីពីការអប់រំ រដ្ឋជាសមាជិកគួរអនុវត្តកិច្ចខិតខំប្រឹងប្រែង ដូចខាងក្រោម។

៥.១៤ សម្រាប់សកម្មភាពជាអាទិភាពទី ១ ស្តីពីពីគោលនយោបាយ ចាំបាច់ត្រូវមានការបញ្ចូល ESD ទៅក្នុងគោលនយោបាយនៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ ពាក់ព័ន្ធនឹងការអប់រំ និងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីឱ្យគោលនយោបាយទាំងនេះអាចកសាងបរិយាកាសអំណោយផលសម្រាប់ការអនុវត្តគោលវិធីគរុកោសល្យ ដែលគាំទ្រដល់ការបង្កើនភាពក្លាហានរបស់បុគ្គលម្នាក់ៗ និងផ្តល់នូវជំនាញសម្រាប់ចូលរួមក្នុងសកម្មភាពសង្គមនិងនយោបាយ។ គួរមានកិច្ចខិតខំប្រឹងប្រែងដោយមានការសម្របសម្រួលបានល្អសម្រាប់ ដើម្បីឱ្យ ESD អាចផ្គួបកម្លាំងគ្នាជាមួយនឹងរបៀបវារៈ និងគោលនយោបាយជាតិ និងអន្តរជាតិស្តីពីការអប់រំ និងការអភិវឌ្ឍដោយចីរភាពដែលពាក់ព័ន្ធដទៃទៀត។

[២០] ប៉ុន្តែចាំបាច់ត្រូវបន្តសមាជិកភាពនៃបណ្តាដៃគូសំខាន់ៗនាពេលបច្ចុប្បន្នព្រោះថាលក្ខខណ្ឌប្រតិបត្តិរបស់ពួកគេបានបញ្ចប់កាលពីចុងឆ្នាំ២០១៦។ដំណើរការថ្មីដើម្បីរកដៃគូនិងការរៀបចំលក្ខខណ្ឌប្រតិបត្តិសម្រាប់បណ្តាញនេះ នឹងត្រូវកែសម្រួលឡើងវិញស្របតាមកម្មវិធី ESD សម្រាប់ឆ្នាំ ២០៣០។

[២១] ជាមួយដៃគូដែលត្រូវបានលើកឡើងនៅក្នុងឯកសារនេះ គឺជាដៃគូចំនួន ៩៥ ដែលត្រូវបានកំណត់នៅកម្រិតសកល ក្នុងដំណាក់កាលបច្ចុប្បន្ននៃ GAP ហើយដែលសកម្មភាពចងក្រងបណ្តាញបានទទួលការគាំទ្រពីយូណេស្កូ។

៥.១៥ សម្រាប់សកម្មភាពជាអាទិភាពទី ២ ស្តីពីបរិបទនៃការអប់រំ និងការបណ្តុះបណ្តាល ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើការជំរុញឱ្យមានការអនុវត្តអភិក្រមទូទាំងស្ថាប័ន ដែលត្រូវមានការគូសបញ្ជាក់អំពីសារៈសំខាន់នៃភាពចាំបាច់សម្រាប់សាលារៀនឬគ្រឹះស្ថានអប់រំដទៃទៀតនៅគ្រប់កម្រិតទាំងអស់ ចាប់ពីការអប់រំកុមារតូចរហូតដល់ឧត្តមសិក្សា និងរៀនសូត្រពេញមួយជីវិតក្នុងសហគមន៍ ធ្វើការងាររួមគ្នា។ ចាំបាច់ត្រូវមានការដាក់ចេញនូវគោលនយោបាយ និងវិធានការជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងអន្តរកម្ម ក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការ។

៥.១៦ សម្រាប់សកម្មភាពជាអាទិភាពទី ៣ ស្តីពីការអប់រំ ចាំបាច់ត្រូវមានការផ្តល់ឱកាសបន្ថែមឱ្យពួកគេបង្កើនសមត្ថភាព លើកកម្ពស់ភាពក្លាហានដល់អ្នកសិក្សា។ការយល់ដឹងពីរបៀបអនុវត្តសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ត្រូវតែឆ្លុះបញ្ចាំងក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់អ្នកអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដើម្បីឱ្យពួកគេដឹងច្បាស់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃគោលវិធីគរុកោសល្យផ្សេងៗដែលពួកគេប្រើប្រាស់។ អ្នកអប់រំត្រូវតែជាអ្នកសម្របសម្រួលការសិក្សា ដែលផ្តល់ការតម្រង់ទិសដល់អ្នកសិក្សាតាមរយៈការផ្លាស់ប្តូរជាវិជ្ជមានក៏ដូចជាត្រូវបំពេញតួនាទីជាអ្នកជំនាញខាងផ្សព្វផ្សាយចំណេះដឹងផងដែរ។

៥.១៧ សម្រាប់សកម្មភាពជាអាទិភាពផ្តោតលើយុវជន នឹងមានការផ្តោតការយកចិត្តទុកដាក់លើការផ្តល់ឱកាសឱ្យមានការចូលរួមពីយុវជន។ ត្រូវមានការទទួលស្គាល់ថាយុវជនគឺជាតួអង្គមួយក្នុងចំណោមតួអង្គសំខាន់ៗដែលត្រូវឆ្លើយតបចំពោះបញ្ហាប្រឈមដែលពាក់ព័ន្ធចីរភាព និងត្រូវមានការបង្កលក្ខណៈឱ្យពួកគេបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។ យុវជនគឺជាក្រុមដែលមានខួរក្បាលប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ ហើយយុវជនក៏ជាអ្នកធ្វើសកម្មភាពផ្តោតលើភាពច្នៃប្រឌិតនិងនវានុវត្តន៍នេះផងដែរ។ ចាំបាច់ត្រូវមានការពិនិត្យតាមដានឱ្យបានល្អិតល្អន់លើនិន្នាការក្នុងចំណោមយុវជនពាក់ព័ន្ធឥរិយាបថ ក៏ដូចជាគុណតម្លៃរបស់ពួកគេ ដើម្បីកំណត់ពីវិធីសាស្ត្រដែលល្អបំផុតសម្រាប់ទាញប្រយោជន៍ពីចំណុចខ្លាំងរបស់ពួកគេ។

៥.១៨ ចុងក្រោយ សម្រាប់សកម្មភាពជាអាទិភាពទី ៥ ដែលផ្តោតលើយុវជន អ្វីដែលសំខាន់មុនគេ គឺត្រូវយល់ឱ្យច្បាស់ថាការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយអត្ថន័យ និងសកម្មភាពដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ទំនងជាកើតឡើងបំផុតនៅតាមសហគមន៍។ដោយហេតុតែចំនួនប្រជាជននៅក្នុងពិភពលោកប្រមូលផ្តុំនៅក្នុងតំបន់ប្រជុំជន ការលើកកម្ពស់ភាពក្លាហានរបស់អាជ្ញាធរមូលដ្ឋាននៅតំបន់ប្រជុំជន គឺជាយុទ្ធសាស្ត្រមួយដ៏ល្អ ហើយក្នុងពេលជាមួយគ្នាមិនត្រូវមើលរំលងតម្រូវការរបស់សហគមន៍ជនបទនោះឡើយ។ ក្នុងន័យនេះ ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* លើកជាអនុសាសន៍ឱ្យមានការអនុវត្តសកម្មភាពជាអាទិភាពទី ៥ មិនត្រឹមតែក្នុងនាមជាសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំង ៥ ប៉ុណ្ណោះទេ តែរឹតសំខាន់ទៅទៀតនោះ គឺជាសកម្មភាពអាទិភាពស្នូលដែលត្រូវផ្សារភ្ជាប់ទំនាក់ទំនងឱ្យបានជិតស្និទ្ធជាមួយនឹងការអនុវត្តសកម្មភាពដទៃទៀត ជាពិសេសសកម្មភាពដែលផ្តោតលើយុវជន។

៥.១៩ ក្នុងការអនុវត្តសកម្មភាពសម្រាប់ផ្នែកសកម្មភាពជាអាទិភាពទាំងនេះ រដ្ឋជាសមាជិកត្រូវបានអញ្ជើញឱ្យកៀរគរតួអង្គពាក់ព័ន្ធដែលធ្វើការងារនៅក្នុងផ្នែកទាំងនេះនិងផ្តល់ការគាំទ្រដល់ការចងក្រងបណ្តាញសហការគ្នារបស់ពួកគេ ដោយប្រើប្រាស់យុទ្ធសាស្ត្រដោយមានការសម្របសម្រួល ហើយដែលមានទំនាក់ទំនងជាមួយនឹងក្របខ័ណ្ឌ SDG របស់ជាតិ។ គួរមានការខិតខំប្រឹងប្រែងដាក់លាក់បន្ថែមទៀត ដើម្បីអនុវត្តសកម្មភាពអប់រំផ្សព្វផ្សាយ និងស្វែងរកការគាំទ្រ ដើម្បីឆ្លុះបញ្ចាំងពី SDG នៅក្នុងការអនុវត្ត ក៏ដូចជាក្របខ័ណ្ឌអប់រំ ហើយក្នុងពេលជាមួយគ្នា គេអាចបង្កើតជាគំនិតផ្តួចផ្តើមទូទាំងប្រទេសដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ ដើម្បីផ្តល់ការគាំទ្រដល់ក្របខ័ណ្ឌ ESD សម្រាប់ឆ្នាំ ២០៣០ នៅកម្រិតប្រទេស។

៥.២០ សកម្មភាពដែលអនុវត្តដោយយូណេស្កូ ដូចស្តែងចេញក្នុងដំណាក់កាលបច្ចុប្បន្ននៃសកម្មភាព GAP មានសកម្មភាពមួយចំនួនដែលរដ្ឋជាសកមាជិកត្រូវអនុវត្ត តាមរយៈតួអង្គពាក់ព័ន្ធនិងរួមគ្នាជាមួយនឹងតួអង្គពាក់ព័ន្ធទាំងនោះ។ មុខងាររបស់យូណេស្កូគឺត្រូវផ្តល់ការគាំទ្រនិងជួយដល់រដ្ឋជាសមាជិកផ្តល់ជាការណែនាំបច្ចេកទេស បង្កើតជាវេទិកាសម្រាប់ផ្លាស់ប្តូរព័ត៌មាន និងចងក្រងបណ្តាញ និងផ្តល់ការគាំទ្រផ្នែកកម្មវិធីដើម្បីលើកទឹកចិត្តឱ្យមានការពង្រីកវិសាលភាពសកម្មភាពបន្ថែមទៀត។ ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* នៅតែបន្តរក្សាជំហរដដែល ដោយក្នុងនោះយូណេស្កូត្រូវផ្តល់ការគាំទ្រដល់ការងារដូចខាងក្រោម។[២២]

៥.២១ ទី ១ យូណេស្កូនឹងបន្តពង្រឹងសមត្ថភាពជំរុញគោលនយោបាយនៅថ្នាក់ជាតិ។ យូណេស្កូក៏នឹងបង្កើតសមាសភាគកម្មវិធីមួយដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមមួយចំនួនដែលអនុវត្តនៅទូទាំងប្រទេសជុំវិញ *ESD សម្រាប់ឆ្នាំ ២០៣០* ដែលអាចបញ្ចូលផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត និងចែករំលែកបទពិសោធន៍និងលទ្ធផលជាមួយនឹងប្រទេសដទៃទៀតផងដែរ។

[២២] ការអនុវត្តក្របខ័ណ្ឌក្រោយ GAP ពេញលេញ តម្រូវឱ្យមានការរៃអង្គាសប្រើប្រាស់ធនធានក្រៅពីថវិកាក្នុងចំនួនដ៏ច្រើន។

៥.២២ ទី ២ យូណេស្កូនឹងបន្តគាំទ្រដល់ការចងក្រងបណ្តាញដៃគូសំខាន់ៗដែលត្រូវបានកំណត់នៅកម្រិតសកល ព្រមទាំងដំណើរការចងក្រងបណ្តាញរបស់ដៃគូទាំងនោះ។ នេះនឹងធ្វើឡើងតាមរយៈការផ្តល់ឱ្យពួកគេនូវវេទិកាមួយ ដើម្បីជួប និងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ជាប្រចាំ ក៏ដូចជាសហការរៀបចំផែនការគំនិតផ្តួចផ្តើមនានា។ វេទិកានេះនឹងមានការចូលរួមពីតំណាង និងតួអង្គមកពីវិស័យរដ្ឋាភិបាល និងឯកជន និងពីអ្នកផ្តល់ជំនួយ សហគមន៍អភិវឌ្ឍន៍ និងសហគមន៍ SDG ក៏ដូចជា តួអង្គពាក់ព័ន្ធនានាដែលធ្វើការងារនៅក្នុងផ្នែកសកម្មភាពទាំង ៥ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ និងថ្នាក់សកល។

៥.២៣ ទី ៣ ការអនុវត្តកម្មវិធី *ESD សម្រាប់ឆ្នាំ ២០៣០* គួរធ្វើឡើងឈរលើភស្តុតាង។ ចាំបាច់ត្រូវមានការពិនិត្យតាមដាន និងវិភាគបញ្ហា និងនិន្នាការថ្មីៗឱ្យបានជិតស្និទ្ធ ដើម្បីកំណត់រកភាពពាក់ព័ន្ធផ្នែកគុរកោសល្យ។ ដើម្បីសម្រេចគោលដៅនេះ មានការលើកស្នើឱ្យយូណេស្កូធ្វើការវិភាគលើបញ្ហានានា ដែលត្រូវបានកំណត់ជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងដំណើរការផ្លាស់ប្តូរជាវិជ្ជមានរបស់បុគ្គលម្នាក់ៗ បញ្ហាជាប្រព័ន្ធដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍ និងចីរភាព ក៏ដូចជាអនាគតរបស់ ESD នៅក្នុងយុគសម័យនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យា ដូច្នេះត្រូវធ្វើការផ្សព្វផ្សាយលទ្ធផលដល់តួអង្គពាក់ព័ន្ធនៅក្នុងប្រទេស។

៥.២៤ ទី ៤ ចាំបាច់ត្រូវមានការអប់រំផ្សព្វផ្សាយ និងការតស៊ូមតិផ្តោតចំគោលដៅបន្ថែមទៀតស្តីពីតួនាទីរបស់ការអប់រំ ក្នុងការគាំទ្រសម្រេចគោលដៅ SDG។ នៅថ្នាក់ជាតិ កិច្ចខិតខំប្រឹងប្រែងនេះគឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមផ្តោតលើ *ESDសម្រាប់ឆ្នាំ២០៣០* ដែលអនុវត្តនៅទូទាំងប្រទេស។ នៅកម្រិតសកល យូណេស្កូនឹងរៀបចំឱ្យមានជាកម្មវិធីពិសេសមួយ ដើម្បីផ្សព្វផ្សាយដល់សហគមន៍ពាក់ព័ន្ធអំពី SDG ក៏ដូចជាដល់អ្នកសិក្សា និងអ្នកអប់រំអំពីតួនាទីដ៏សំខាន់របស់ការអប់រំក្នុងការគាំទ្រដល់ការសម្រេចគោលដៅ SDG។ កម្មវិធីផ្តល់រង្វាន់ដែលអនុវត្តដោយយូណេស្កូ និងប្រទេសជប៉ុន ប្រសិនបើនៅតែបន្តអនុវត្ត នឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃយុទ្ធនាការអប់រំផ្សព្វផ្សាយ និងតស៊ូមតិរបស់យូណេស្កូ។

៥.២៥ ទី ៥ ដើម្បីអនុវត្តកិច្ចការនេះ យូណេស្កូចាំបាច់ត្រូវបន្តអភិវឌ្ឍភាពជាដៃគូរបស់ខ្លួន មិនត្រឹមតែជាមួយនឹងសហគមន៍ ESD ប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាមួយនឹងសហគមន៍អភិវឌ្ឍន៍ដោយចីរភាព និងសហគមន៍ SDG ទៀតផង។ កិច្ចសហប្រតិបត្តិការ និងការសម្រុះសម្រួលជាមួយ UNDESA ក៏ដូចជាស្ថាប័នរបស់អង្គការសហប្រជាជាតិដទៃទៀតដែលទទួលខុសត្រូវលើការគ្រប់គ្រង SDG[២៣] នៅថ្នាក់សកល និងនៅក្នុងតំបន់ ក៏ចាំបាច់ត្រូវពង្រឹងបន្ថែមផង។

៥.២៦ ភាពជាដៃគូជាមួយនឹងតួអង្គពាក់ព័ន្ធសំខាន់ៗដទៃទៀត ក៏ចាំបាច់ត្រូវរៀបចំឱ្យមានផងដែរ ក៏ដូចជាភាពជាដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុពហុភាគី ទីភ្នាក់ងារអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិលពួក និងតួអង្គនៅតាមសហគមន៍។ សម្ព័ន្ធភាពជាមួយយន្តការនៅថ្នាក់ជាតិដែលត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ការសម្រេច SDG តាមរយៈការអប់រំក៏ត្រូវការការយកចិត្តទុកដាក់បន្ថែមទៀតផងដែរ។ នៅក្នុងការកសាងភាពជាដៃគូ ក៏ចាំបាច់ត្រូវមានការពិនិត្យលើការប្រើប្រាស់យន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនវានុវត្តន៍ និងភាពច្នៃប្រឌិតផងដែរ។[២៤]

៥.២៧ នៅក្នុងក្របខ័ណ្ឌយូណេស្កូ វិស័យអប់រំក៏ត្រូវពង្រឹងភាពជាដៃគូអន្តរវិស័យរបស់ខ្លួនជាមួយនឹងវិស័យដទៃទៀត ជាពិសេសវប្បធម៌ និងវិទ្យាសាស្ត្រ ដោយត្រូវបញ្ជូនការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ទៅក្នុងកម្មវិធីដែលពាក់ព័ន្ធ ក្នុងករណីដែលអាចធ្វើទៅបាន។ កម្មវិធីទាំងនេះមានជាអាទិ៍ កម្មវិធីតំបន់បេតិកភណ្ឌពិភពលោក បេតិកភណ្ឌវប្បធម៌អរូបី បណ្តាញឋបនីយជីវមណ្ឌល ឧទ្យានធម្មជាតិរដ្ឋកំពុងអភិវឌ្ឍដែលជាដែនកោះតូចៗ និងកម្មវិធីដែលផ្តោតលើចំណេះដឹងក្នុងស្រុកនិងចំណេះដឹងរបស់ជនជាតិដើមភាគតិច។ វិស័យអប់រំក៏ត្រូវបង្កើនការសហការក្នុងវិស័យរបស់ខ្លួនផ្តោតលើ ESD និងត្រូវលើកទឹកចិត្តឱ្យកម្មវិធី និងបណ្តាញពាក់ព័ន្ធរបស់ខ្លួន រួមចំណែកដល់កម្មវិធី *ESD សម្រាប់ឆ្នាំ ២០៣០* ដូចជា បណ្តាសាលារៀនដែលមានទំនាក់ទំនងជាមួយយូណេស្កូ (ASPnet), ប្រធានយូណេស្កូ, មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ UNEVOC, បណ្តាញទីក្រុងដែលផ្តល់អាទិភាពដល់ការសិក្សា ក៏ដូចជា គណៈកម្មាធិការដឹកនាំ SDG-ការអប់រំឆ្នាំ ២០៣០។

៥.២៨ ចុងក្រោយ ការពិនិត្យតាមដាន និងវាយតម្លៃប្រភេទផ្សេងៗ នៅតែជាកិច្ចការដ៏សំខាន់សម្រាប់យូណេស្កូ ដូចរៀបរាប់ខាងក្រោម។ ដោយសារមេរៀនដែលទទួលបានពីកម្មវិធី GAP ត្រូវមានការបន្តអនុវត្ត និងកែលម្អវិធានការពិនិត្យតាមដានជាក់លាក់ ដើម្បីឈានទៅសម្រេចចំណុចដៅ ៤.៧ ត្រឹមឆ្នាំ ២០៣០។

៥.២៩ ទី ១ ការពង្រីកវិសាលភាពសកម្មភាពនៅក្នុងផ្នែកជាអាទិភាពទាំង ៥ ដោយរដ្ឋជាសមាជិក ក៏ដូចជាដោយដៃគូដែលត្រូវបានកំណត់នៅថ្នាក់សកល ទាមទារឱ្យមានការពិនិត្យតាមដានឱ្យបានជិតស្និទ្ធ។ ការវាស់វែងវឌ្ឍនភាព ត្រូវធ្វើធៀបនឹងទិន្នន័យដើមគ្រា ដែលប្រមូលពីដើមដំបូង។ សម្រាប់ការពង្រីកវិសាលភាពអនុវត្តដោយដៃគូ យូណេស្កូ ត្រូវធ្វើការអង្កេត ដែលប្រើប្រាស់នៅក្នុងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ហើយក៏នឹងត្រូវប្រើប្រាស់នៅក្នុងការពិនិត្យចុងក្រោយលើការអនុវត្ត GAP ផងដែរ។

---

[២៣] ព្រមទាំងក្របខ័ណ្ឌដែលពាក់ព័ន្ធនានា ដូចជា កិច្ចព្រមព្រៀងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុជាដើម។

[២៤] យន្តការទាំងនេះអាចលើកមកក៏ពន្យល់បកស្រាយនៅតាមវេទិកានានា ដូចជា កិច្ចពិគ្រោះយោបល់ស្តីពីការផ្តល់ហិរញ្ញប្បទានដែលមានរចនាសម្ព័ន្ធត្រឹមត្រូវរបស់យូណេស្កូជាដើម។

៥.៣០ ដើម្បីវាស់វែងការពង្រីកវិសាលភាព និងការអនុវត្តនៅតាមរដ្ឋជាសមាជិក យូណេស្កូនឹងធ្វើការកែសម្រួលកម្រងសំណួរដែលកំពុងប្រើប្រាស់សម្រាប់ពិនិត្យតាមដានលើចំណុចដៅ ៤.៧។[២៥] មានការលើកស្នើឱ្យបញ្ចូលកិច្ចខិតខំប្រឹងប្រែងវាស់វែងវឌ្ឍនភាពនៃការពង្រីកវិសាលភាពសកម្មភាពនៅតាមប្រទេសជុំវិញផ្នែកសកម្មភាពជាអាទិភាពទាំង ៥ ទៅក្នុងឧបករណ៍នេះ។ នេះគឺជាអ្វីដែលអាចធ្វើទៅបាន ហើយក៏ជួយបញ្ចៀសមិនឱ្យមានការប្រើប្រាស់កម្រងសំណួរច្រើន ដើម្បីសម្រេចគោលបំណងពិនិត្យតាមដានផ្សេងៗគ្នានៅតាមរដ្ឋជាសមាជិកផងដែរ។

៥.៣១ ការពិនិត្យតាមដានប្រភេទទី ២ នឹងត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌដោយត្រូវបានកំណត់របស់កម្មវិធី ឬក៏គម្រោងអ្វីមួយ ដែលក្នុងនោះនឹងមានការផ្ដោតការយកចិត្តទុកដាក់លើការសម្រេចលទ្ធផលរំពឹងទុក និងផលជះ។ នឹងមានការពិនិត្យតាមដានលើការអនុវត្តសកម្មភាពផ្ដល់ការគាំទ្រផ្នែកកម្មវិធីដល់រដ្ឋាភិបាល និងដៃគូនៅកម្រិតសកល ការបង្កើតវេទិកា និងការបង្កើតបណ្ដាញរួមតែមួយសម្រាប់តួអង្គផ្សេងៗការអនុវត្តសកម្មភាពអប់រំផ្សព្វផ្សាយ និងគំនិតផ្ដួចផ្ដើម រួមទាំងការគ្រប់គ្រងកម្មវិធីផ្ដល់រង្វាន់ ESD របស់យូណេស្កូ-ជប៉ុន ដើម្បីវាស់វែងលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយដោយត្រូវមានការកំណត់សូចនាករដែលចាំបាច់ពីដើមដំបូងទៅ។

៥.៣២ លើសពីនេះ នឹងមានការពិនិត្យតាមដានថ្មីមួយទៀតដែលនឹងធ្វើឡើងដោយយូណេស្កូ។ ដើម្បីគាំទ្រដល់គោលការណ៍ឈរលើភស្តុតាងសម្រាប់ការអនុវត្តកម្មវិធីក្រោយ GAP យូណេស្កូនឹងធ្វើការអង្កេតជាប្រចាំតាមប្រធានបទ ដើម្បីធ្វើការកំណត់ និងវិភាគលើបញ្ហាទិន្នការ និងការវិវឌ្ឍសំខាន់ៗ។ ការធ្វើបែបនេះ គឺដើម្បីប្រមូលការយល់ឃើញសំខាន់ៗ រួមនឹងភស្តុតាងក៏ដូចជាទិន្នន័យ ដើម្បីបញ្ចូលទៅក្នុងគោលវិធីគរុកោសល្យដែលមានលក្ខណៈយុទ្ធសាស្ត្រនិងដែលមានប្រសិទ្ធភាពបំផុតសម្រាប់អនុវត្តកម្មវិធី *ESD សម្រាប់ឆ្នាំ ២០៣០*។ ការពិនិត្យតាមដានតាមប្រធានបទទាំងនេះ នឹងបំពេញបន្ថែមលើការពិនិត្យតាមដានវឌ្ឍនភាព ដែលកំពុងអនុវត្តដោយរដ្ឋជាសមាជិក តាមរយៈការប្រើប្រាស់ឧបករណ៍អង្កេតសម្រាប់ចំណុចដៅ ៤.៧។

៥.៣៣ នៅក្នុងរយៈពេលនៃការអនុវត្ត *ESD សម្រាប់ឆ្នាំ ២០៣០* ក៏នឹងមានការវាយតម្លៃតាមការកំណត់លើវឌ្ឍនភាពនៃការអនុវត្តក្របខ័ណ្ឌនេះផងដែរ។

សេចក្ដីសម្រេចនៃសន្និសីទរបស់យូណេស្កូ លេខ ៤០C/ សេចក្ដីសម្រេច ១៤

ក្របខ័ណ្ឌសម្រាប់អនុវត្តការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) ក្រោយឆ្នាំ ២០១៩

សន្និសីទ

រំលឹកឡើងវិញនូវ ២០៤X/សេចក្ដីសម្រេចលេខ ២៨ និង ២០៦Ex/សេចក្ដីសម្រេច ៦.II

និងរំលឹកឡើងវិញពីសេចក្ដីសម្រេចនៃមហាសន្និបាតសហប្រជាជាតិលេខ ៧៧/២២២ ដែលគូសបញ្ជាក់ជាថ្មីពីតួនាទីរបស់យូណេស្កូក្នុងនាមជាទីភ្នាក់ងារដឹកនាំការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព និងទទួលស្គាល់ថា "ESD គឺជាសមាសភាពមួយដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍ចីរភាព ដែលផ្ដោតលើការអប់រំប្រកបដោយគុណភាព និងជាកាតាលីករដ៏សំខាន់សម្រាប់ជួយដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដទៃទៀត"

បានពិនិត្យលើឯកសារ ៤០C/២៣

១. កត់សម្គាល់ពីការគាំទ្រទូលំទូលាយរបស់រដ្ឋជាសមាជិកដល់ផ្ដល់ដល់សេចក្ដីព្រាងក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០*។

២. ផ្ដល់ការគាំទ្រដល់ក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* និងអញ្ជើញរដ្ឋជាសមាជិកឱ្យអនុវត្តក្របខ័ណ្ឌនេះឱ្យបានសកម្ម និងប្រមូលកៀរគរធនធានសម្រាប់អនុវត្តសកម្មភាព និងកម្មវិធីអប់រំសម្រាប់ការអភិវឌ្ឍចីរភាព (ESD) នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល ទៅតាមការសមស្រប។

៣. ស្នើសុំឱ្យអគ្គនាយក យកក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិក្នុងសម័យប្រជុំលើកទី ៧៤ ដើម្បីពិចារណា និងចាត់វិធានការតាមការគួរ។

៤. លើកទឹកចិត្តឱ្យអគ្គនាយកកៀរគរវិស័យកម្មវិធី និងបណ្ដាញទាំងអស់របស់យូណេស្កូ ដើម្បីបង្កើនការរួមចំណែកនៃវិស័យ និងបណ្ដាញទាំងនេះដល់ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព និង ESD និងចូលរួមឱ្យបានសកម្មនៅក្នុងការអនុវត្តក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០*។

៥. សូមថ្លែងអំណរគុណដល់រដ្ឋាភិបាលអាល្លឺម៉ង់ដែលបានផ្ដល់ការគាំទ្រ និងរួមចំណែកប្រកបដោយសប្បុរសធម៌ដល់ការរៀបចំព្រឹត្តិការណ៍អន្តរជាតិសម្រាប់ប្រកាសផ្សព្វផ្សាយពីក្របខ័ណ្ឌ *ESD សម្រាប់ឆ្នាំ ២០៣០* កាលពីខែ មិថុនា ឆ្នាំ ២០២០ នៅក្នុងទីក្រុង ប៊ែកឡាំង។

[២៥] កម្រងសំណួរនេះមានដែនកំណត់មួយចំនួន នៅពេលប្រើប្រាស់សម្រាប់ការវាស់វែងវឌ្ឍនភាពនៃ ESD។ ប្រធានបទ ESD ដែលបញ្ចូលក្នុងកម្រងសំណួរនេះ អាចមិនពាក់ព័ន្ធជាមួយគ្នាសោះ ពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយអាចមិនផ្ដោតការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅផ្លូវការ។ ដើម្បីកែតម្រូវបានកំណត់ទាំងនេះ យូណេស្កូគ្រោងនឹងធ្វើការកែសម្រួលកម្រងសំណួរនេះ ដើម្បីឆ្លុះបញ្ចាំងកាន់តែគ្រប់ជ្រុងជ្រោយលើ ESD។

សេចក្ដីសម្រេចដែលត្រូវបានអនុម័ត ផ្ដោតលើរបាយការណ៍នៃគណៈកម្មាធិការ ED ក្នុងសម័យប្រជុំពេញអង្គលើកទី ១៦ កាលពីថ្ងៃ ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៩។

គ. កថាខណ្ឌមួយចំនួនដែលត្រូវបានដកស្រង់ចេញពីសេចក្ដីសម្រេចលេខ ៧២/២២២ (២០១៧) របស់មហាសន្និបាតអង្គការសហប្រជាជាតិស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព នៅក្នុងក្របខ័ណ្ឌនៃរបៀបវារៈអភិវឌ្ឍន៍ចីរភាពឆ្នាំ ២០៣០

មហាសន្និបាត (...)

២ គូសបញ្ជាក់ជាថ្មីថាការអប់រំសម្រាប់អភិវឌ្ឍន៍ដោយចីរភាព គឺជាមធ្យោបាយដ៏សំខាន់សម្រាប់អនុវត្តការអភិវឌ្ឍដោយចីរភាពដូចដែលលើកឡើងនៅក្នុងសេចក្ដីប្រកាស Aichi - ណាហ្គូយ៉ា ស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយជីវភាព និងជាសមាសភាពមួយដ៏សំខាន់នៃគោលដៅអភិវឌ្ឍន៍ចីរភាព ផ្ដោតលើការអប់រំប្រកបដោយគុណភាពនិងជាកាតាលីករដ៏សំខាន់មួយសម្រាប់គោលដៅអភិវឌ្ឍន៍ចីរភាពដទៃទៀតនិងស្វាគមន៍ការបង្កើនការទទួលស្គាល់របស់អន្តរជាតិលើការអប់រំសម្រាប់អភិវឌ្ឍដោយចីរភាពផ្ដោតលើការអប់រំប្រកបដោយគុណភាព និងការរៀនសូត្រពេញមួយជីវិត (...)

https://undocs.org/en/A/RES/72/222

ឃ. កថាខណ្ឌមួយចំនួនដែលត្រូវបានដកស្រង់ចេញពីសេចក្ដីសម្រេចលេខ ៧៤/២២៣ (២០១៩) របស់មហាសន្និបាតអង្គការសហប្រជាជាតិស្ដីពីការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព នៅក្នុងក្របខ័ណ្ឌនៃរបៀបវារៈអភិវឌ្ឍន៍ចីរភាពឆ្នាំ ២០៣០

មហាសន្និបាត (...)

៧. លើកទឹកចិត្តឱ្យរដ្ឋាភិបាលបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចូល និងធ្វើស្ថាប័ននីយតកម្មការអប់រំសម្រាប់ការអភិវឌ្ឍចីរភាពក្នុងលក្ខណៈជាប្រព័ន្ធទៅក្នុងវិស័យអប់រំ និងវិស័យពាក់ព័ន្ធដទៃទៀតទៅតាមការសមស្រប ជាអាទិ៍ផ្ដល់នូវធនធានហិរញ្ញវត្ថុ ការបញ្ចូលការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព ទៅក្នុងគោលនយោបាយដែលពាក់ព័ន្ធ និងការអភិវឌ្ឍសមត្ថភាពអ្នកធ្វើគោលនយោបាយ អ្នកដឹកនាំស្ថាប័ន និងអ្នកអប់រំ ក៏ដូចជាតាមរយៈការពង្រឹងការស្រាវជ្រាវ និងនវានុវត្តន៍ និងការតាមដាន និងការវាយតម្លៃ និងការអនុវត្តក្របខ័ណ្ឌអប់រំសម្រាប់អភិវឌ្ឍន៍ដោយចីរភាព ដើម្បីគាំទ្រដល់ការពង្រីកវិសាលភាពការអនុវត្តល្អ (...)

https://undocs.org/en/A/RES/74/223

ខ. ប្រវត្តិ ESD ដោយសង្ខេប

១៩៧២ សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថានរបស់មនុស្ស ទីក្រុង Stockholm

- សេចក្តីប្រកាសនៃសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថានមនុស្ស បានប្រកាស *"ការពារ និងលើកកម្ពស់បរិស្ថានសម្រាប់មនុស្សជំនាន់នេះ និងជំនាន់បច្ចុប្បន្ន គឺជាគោលដៅចាំបាច់សម្រាប់មនុស្សជាតិ"។*
- **អនុសាសន៍លេខ ៩៦ នៃ សន្និសីទទីក្រុង Stockholm ឆ្នាំ ១៩៧២** ចាត់ទុកការអប់រំពីបរិស្ថានថាជាមធ្យោបាយដ៏សំខាន់សម្រាប់ឆ្លើយតបចំពោះវិបត្តិបរិស្ថាននៅក្នុងពិភពលោក។ **គោលការណ៍ទី ១៩ នៃសេចក្តីប្រកាសទីក្រុង** Stockholm ចែងជាអាទិ៍ថា *"ការអប់រំអំពីបញ្ហាបរិស្ថានសម្រាប់យុវជន និងមនុស្សពេញវ័យ ឱ្យមានការយកចិត្តទុកដាក់ជាពិសេសចំពោះអ្នកដែលមិនសូវមានឱកាស គឺជាអ្វីដែលសំខាន់ និងចាំបាច់ ដើម្បីពង្រីកមូលដ្ឋានសម្រាប់ឱ្យបុគ្គល សហគ្រាស និងសហគមន៍ផ្តល់ជាយោបល់ និងទទួលខុសត្រូវលើការការពារ និងការកែលម្អបរិស្ថានក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់មនុស្ស"។*

១៩៧៧ សន្និសីទអន្តររដ្ឋាភិបាលលើកទី ១ ស្តីពីការអប់រំបរិស្ថាន នៅទីក្រុងប៊ីលីស៊ី ប្រទេសហ្សកហ្ស៊ី

- សន្និសីទនេះបានដាក់ចេញនូវតួនាទី វត្ថុបំណង និងលក្ខខណ្ឌនៃការអប់រំបរិស្ថាន និងបានកំណត់នូវគោលដៅ និងគោលការណ៍ជាច្រើនសម្រាប់កាសរអប់រំបរិស្ថាន។
- សេចក្តីប្រកាសប៊ីលីស៊ី បានកត់សម្គាល់ពី *"តួនាទីដ៏សំខាន់នៃការអប់រំបរិស្ថាននៅក្នុងការការពារ និងការកែលម្អបរិស្ថាននៅក្នុងពិភពលោកក៏ដូចជាក្នុងការធានានូវការអភិវឌ្ឍឱ្យបានល្អប្រសើរប្រកបដោយតុល្យភាពនៅក្នុងសហគមន៍ពិភពលោក។"*

១៩៨៧ "អនាគតរួមរបស់យើង" (របាយការណ៍របស់គណៈកម្មការពិភពលោកទទួលបន្ទុកបរិស្ថាន និងការអភិវឌ្ឍ ដែលហៅថារបាយការណ៍ Brundtland)

- ការអភិវឌ្ឍដោយចីរភាព ត្រូវបានឱ្យនិយមន័យថាជា *"ការអភិវឌ្ឍដែលឆ្លើយតបចំពោះតម្រូវការរបស់មនុស្សបច្ចុប្បន្ន ដោយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់មនុស្សជំនាន់ក្រោយ ក្នុងការបំពេញតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ"។*

១៩៩២ សន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍ (កិច្ចប្រជុំកំពូលទីក្រុង រីយ៉ូ កិច្ចប្រជុំកំពូលផែនដី)

- ជំពូក ៣៦ នៃរបៀបវារៈ ២១ សង្ខេបការពិភាក្សាអន្តរជាតិស្តីពីតួនាទីដ៏សំខាន់នៃការអប់រំ ការបណ្តុះបណ្តាល និងការបង្កើនការយល់ដឹងជាសាធារណៈ ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- "ការអប់រំមានសារៈសំខាន់សម្រាប់លើកកម្ពស់ការអភិវឌ្ឍដោយចីរភាព និងបង្កើនសមត្ថភាពមនុស្សក្នុងការឆ្លើយតបចំពោះបញ្ហាបរិស្ថាន និងបញ្ហាដែលពាក់ព័ន្ធការអភិវឌ្ឍ"។
- **ការប្រែប្រួលអាកាសធាតុ** ៖ មាត្រា ៦ នៃ**អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ** ផ្តោតលើការអប់រំ ការបណ្តុះបណ្តាល ការបង្កើនការយល់ដឹងជាសាធារណៈ ព្រមទាំងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។
- **ជីវចម្រុះ** ៖ មាត្រា ១៣ នៃ**អនុសញ្ញាស្តីពីជីវចម្រុះ** អំពាវនាវឱ្យមាន *"ការរៀបចំកម្មវិធីអប់រំ និងបង្កើនការយល់ដឹងជាសាធារណៈអំពីការអភិវឌ្ឍ និងការប្រើប្រាស់ជីវចម្រុះប្រកបដោយចីរភាព"* និងកម្មវិធីការងារដែលផ្តោតលើការផ្សព្វផ្សាយ ការអប់រំ និងការបង្កើនការយល់ដឹងជាសាធារណៈ ជាពិសេសសកម្មភាពជាអាទិភាពទី ១០៖ ពង្រឹងការអប់រំក្នុងប្រព័ន្ធ និងការអប់រំក្រៅផ្លូវការ ស្តីពីជីវចម្រុះ។

២០០២

កិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍដោយចីរភាព (កិច្ចប្រជុំកំពូល Johannesburg)

- សំណើរៀបចំទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព ត្រូវបានបញ្ចូលទៅក្នុងផែនការអនុវត្ត Johannesburg។
- សេចក្តីសម្រេចលេខ ៥៧/២៥៤ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ចាត់ទុកឆ្នាំ ២០០៥-២០១៤ ថាជាទសវត្សរ៍សហប្រជាជាតិនៃការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព (DESD) ដោយយូណេស្កូត្រូវបានជ្រើសរើសជាស្ថាប័នដឹកនាំការអនុវត្តនេះ។

២០០៥

ទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់សហប្រជាជាតិ (២០០៥-២០១៤ DESD) ទសវត្សរ៍សហប្រជាជាតិស្តីពីការអប់រំសម្រាប់អភិវឌ្ឍន៍ដោយចីរភាព បាន *"ជួយឱ្យមនុស្សរាប់សែននាក់ធ្វើការតម្រង់ទិសការអប់រំឡើងវិញនៅក្នុងសកលលោកទាំងមូល ដើម្បីឈានទៅសម្រេចគោលដៅរួម នោះគឺរៀនរស់ និងរៀនធ្វើការប្រកបដោយចីរភាព"។*

- **ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ៖** ក្របខ័ណ្ឌសកម្មភាព Hyogo ២០០៥-២០១៥៖ កសាងភាពធន់នៃប្រជាជាតិនិងសហគមន៍ចំពោះគ្រោះមហន្តរាយ និងក្របខ័ណ្ឌសិនដៃ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥-២០៣០។

២០០៩

សន្និសីទពិភពលោករបស់យូណេស្កូស្តីពីការអប់រំសម្រាប់ចីរភាពនៅក្នុងទីក្រុង Bonn ប្រទេសអាល្លឺម៉ង់

- សេចក្តីប្រកាសទីក្រុង Bonn ចាត់ទុក ESD ថាជា *"វិធានការសង្គ្រោះជីវិតសម្រាប់អនាគតដែលផ្តល់ភាពក្លាហានឱ្យមនុស្សធ្វើការផ្លាស់ប្តូរ និងបានផ្តល់ជាអនុសាសន៍ឱ្យចាត់ទុក ESD ថាជាការវិនិយោគដើម្បីអនាគត"។*

២០១២

សន្និសីទសហប្រជាជាតិស្តីពីការអភិវឌ្ឍដោយចីរភាព (Rio + ២០)

- *"លើកកម្ពស់ការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពនិងបញ្ចូលការអភិវឌ្ឍដោយចីរភាពឱ្យបានកាន់តែសកម្មទៅក្នុងការអប់រំក្រោយទសវត្សរ៍អប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពរបស់អង្គការសហប្រជាជាតិ"។*
- **ការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព៖** បែបផែននៃការរស់នៅប្រកបដោយចីរភាព និងកម្មវិធីអប់រំសម្រាប់ក្របខ័ណ្ឌកម្មវិធីដែលផ្តោតលើការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព ដែលមានរយៈពេល ១០ ពីឆ្នាំ ២០១២-២០២១។

២០១៤

សន្និសីទពិភពលោករបស់យូណេស្កូស្តីពីការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពនៅទីក្រុងអៃជី-ណាហ្គូយ៉ា (ប្រទេសជប៉ុន)

- ការដាក់ឱ្យអនុវត្តនូវកម្មវិធីសកម្មភាពជាសកលស្តីពីការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព (២០១៥-២០១៩)។ កម្មវិធីសកម្មភាពជាសកលមានគោលបំណង *"កសាង និងពង្រីកសកម្មភាពនៅគ្រប់កម្រិត និងគ្រប់ផ្នែកទាំងអស់នៃការអប់រំ និងការសិក្សា ដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចការអភិវឌ្ឍដោយចីរភាព"*។ កម្មវិធីនេះផ្តោតលើអាទិភាពចំនួន ៥ ដែលត្រូវបានចាត់ទុកថាជាគន្លឹះសម្រាប់លើកកម្ពស់របៀបវារៈ ESD។
- **សេចក្តីប្រកាសអៃជី-ណាហ្គូយ៉ា ស្តីពី ESD** ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកស្តីពី ESD ដែលរៀបចំដោយយូណេស្កូនៅក្នុងឆ្នាំ ២០១៤ គូសបញ្ជាក់ជាថ្មីថា ESD គឺជាមធ្យោបាយដ៏សំខាន់សម្រាប់អនុវត្តការអភិវឌ្ឍដោយចីរភាព។

២០១៥

គោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) និងរបៀបវារៈឆ្នាំ ២០៣០ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសកលលោក

- **ចំណុចដៅ ៤.៧** ជំរុញដូចតទៅ *"ត្រឹមឆ្នាំ ២០៣០ អ្នកសិក្សាគ្រប់រូបទទួលបានចំណេះសម្បទា និងបំណិនសម្បទាដែលចាំបាច់ សម្រាប់លើកកម្ពស់ការអភិវឌ្ឍដោយចីរភាព"*

- **ចំណុចដៅ ១២.៨** អំពាវនាវឱ្យមាន *"ធានាថាមនុស្សនៅគ្រប់ទិសទីទទួលបានព័ត៌មាន និងការយល់ដឹងដែលពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍដោយចីរភាព និងសម្រាប់បែបផែននៃការរស់នៅដែលមានភាពសុខដុមរមនាជាមួយនឹងធម្មជាតិ"*
- **ចំណុចដៅ ១៣.៣** អំពាវនាវឱ្យមានការ *"លើកកម្ពស់ការអប់រំ ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពមនុស្ស និងសមត្ថភាពស្ថាប័នជុំវិញការប្រែប្រួលអាកាសធាតុ..."*

សេចក្តីប្រកាសអ៊ីនឆន់ ស្តីពីការអប់រំឆ្នាំ ២០៣០៖ *"ចក្ខុវិស័យរបស់យើង គឺនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងជីវិត តាមរយៈការអប់រំ ដោយទទួលស្គាល់ថាការអប់រំមានតួនាទីសំខាន់ក្នុងនាមជាកម្លាំងចលករ សម្រាប់ការអភិវឌ្ឍ និងការសម្រេចគោលដៅ SDG ដែលត្រូវបានលើកស្នើដទៃទៀត"*

សកម្មភាពជាសកលស្តីពី ESD (២០១៥-២០១៩)៖ *"ផ្អែកលើសមិទ្ធផលដែលសម្រេចបាននៅក្នុងទសវត្សរ៍កន្លងមក កម្មវិធី GAP មានគោលបំណងកសាង និងពង្រីកវិសាលភាពសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធនឹង ESD"*

សន្និសីទភាគីនៃកិច្ចព្រមព្រៀងអាកាសធាតុប៉ារីស (COP 21)៖ មាត្រា ១១ និង ១២ នៃកិច្ចព្រមព្រៀងប៉ារីស ឯកសារលទ្ធផលនៃ COP 21។ មាត្រា ២១៖ *"ភាគីត្រូវសហការគ្នាចាត់វិធានការ ដើម្បីបង្កើនការអប់រំ ការបណ្តុះបណ្តាល ការយល់ដឹងជាសាធារណៈ ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុ..."*

២០១៦

ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព៖ របៀបវារៈទីក្រុងថ្មី ត្រូវបានអនុម័តនៅក្នុងសន្និសីទសហប្រជាជាតិស្តីពីលំនៅឋាន និងការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព (Habitat III)

២០១៧

សេចក្តីសម្រេចលេខ ៧២/២២២ នៃមហាសន្និបាតអង្គការសហប្រជាជាតិ -- តួនាទីរបស់ ESD ក្នុងនាមជា "សមាសភាគដ៏សំខាន់នៃ SDG ដែលផ្តោតលើការអប់រំប្រកបដោយគុណភាព និងជាកត្តាដ៏សំខាន់ ដើម្បីជួយដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពដទៃទៀត" ត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់។

សមុទ្រ៖ សន្និសីទសមុទ្ររបស់អង្គការសហប្រជាជាតិអំពាវនាវឱ្យមានការធ្វើសកម្មភាព និងការបង្កើតនូវទសវត្សរ៍សហប្រជាជាតិស្តីពីវិទ្យាសាស្ត្រសមុទ្រ សម្រាប់ការអភិវឌ្ឍដោយចីរភាព (២០២១-២០៣០)

- *"ដើម្បីគាំទ្រដល់ផែនការលើកកម្ពស់ការអប់រំដែលពាក់ព័ន្ធនឹងសមុទ្រ បង្កើនការយល់ដឹងពីសមុទ្រនិងវប្បធម៌នៃការអភិរក្ស ការស្តារឡើងវិញ និងការប្រើប្រាស់សមុទ្ររបស់យើងប្រកបដោយចីរភាព"*។

២០១៩

សម័យប្រជុំលើកទី ៤០ នៃសន្និសីទរបស់យូណេស្កូ៖ ការអនុម័តលើក្របខ័ណ្ឌសម្រាប់អនុវត្ត ESD ក្រោយឆ្នាំ ២០១៩ ដែលមានឈ្មោះថា *"ESD សម្រាប់ឆ្នាំ ២០៣០"* (២០២០-២០៣០) ក្នុងលក្ខណៈជាប្រព័ន្ធទៅក្នុងវិស័យអប់រំ និងវិស័យពាក់ព័ន្ធដទៃទៀត

សេចក្តីសម្រេចលេខ ៧៤/២២៣ នៃមហាសន្និបាតអង្គការសហប្រជាជាតិ - *"លើកទឹកចិត្តឱ្យរដ្ឋាភិបាលបង្កើនកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចូលនឹងរៀបចំ ការអនុវត្តការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាព ជាផ្លូវការ និងក្នុងលក្ខណៈជាប្រព័ន្ធក្នុងវិស័យអប់រំ និងវិស័យពាក់ព័ន្ធដទៃទៀត"*។

unesco
United Nations
Educational, Scientific
and Cultural Organization

ការអប់រំ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ផែនទីបង្ហាញផ្លូវ

#ESDសម្រាប់ឆ្នាំ ២០៣០

ផែនទីបង្ហាញផ្លូវនេះបង្ហាញពីបញ្ហាប្រឈមបន្ទាន់ដែលផែនដីកំពុងជួបប្រទះ និងគូសបញ្ជាក់ពីការអនុវត្តក្របខ័ណ្ឌថ្មី ដែលមានឈ្មោះការអប់រំ សម្រាប់ការអភិវឌ្ឍដោយចីរភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព (ESD សម្រាប់ឆ្នាំ ២០៣០) ដែលត្រូវបានអនុម័តក្នុងគោលបំណងបង្កើនការរួមចំណែកនៃការអប់រំដល់ការកសាងពិភពលោកដែលកាន់តែយុត្តិធម៌ និងចីរភាព។ ESD សម្រាប់ឆ្នាំ ២០៣០ នឹងពន្លឿនសកម្មភាពជាអាទិភាពទាំង ៥ ដែលផ្តោតលើគោលនយោបាយ បរិស្ថាន អប់រំ ការកសាងសមត្ថភាពអ្នកអប់រំ យុវជន និងការធ្វើសកម្មភាពនៅក្នុងមូលដ្ឋាន ដោយបន្តគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ ESD ក្នុងការសម្រេចគោលដៅ SDG ទាំង ១៧ ប្រកបដោយជោគជ័យ ក៏ដូចជាការនាំមកនូវការផ្លាស់ប្តូរធំធេងនៅកម្រិតបុគ្គល និងកម្រិតសង្គមដែលចាំបាច់ ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមបន្ទាន់ដែលពាក់ព័ន្ធនឹងចីរភាព។ ផែនទីបង្ហាញផ្លូវនេះក៏បង្ហាញពីផ្នែកសំខាន់ៗសម្រាប់អនុវត្តក្របខ័ណ្ឌ ESD សម្រាប់ឆ្នាំ ២០៣០ ផងដែរ។ ESD ត្រូវបានទទួលស្គាល់ទូលំទូលាយថាជាសមាសភាគមួយដ៏សំខាន់នៃរបៀបវារៈឆ្នាំ ២០៣០ ជាពិសេសគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី ៤ (SDG ទី ៤) និងជាចលករដ៏សំខាន់សម្រេចគោលដៅ SDG ដទៃទៀតទាំងអស់។

9 789230 001575

4 QUALITY EDUCATION

Sustainable Development Goals